# ហត្ថាកសិករ លីមីតធីត

(ចុះបញ្ជីពាណិជ្ជកម្មលេខ No. 00005355)

# របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ
# គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

**ហត្ថាកសិករ លីមីតធីត**

**របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019**

**មាតិកា** **ទំព័រ**


| | |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 |
| របាយការណ៍ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ | 2 - 3 |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | 4 - 5 |
| របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ | 6 - 7 |
| របាយការណ៍បម្រែបម្រួលមូលធន | 8 |
| របាយការណ៍លំហូរសាច់ប្រាក់ | 9 - 10 |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 11 - 107 |

លេខ / N°:...............................

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយពីទំព័រទី4 ដល់ទី107 របស់ ហត្ថាកសិករ លីមីតធីត (ហៅកាត់ថា "ក្រុមហ៊ុន" ឬ "អេច ខេ អិល") បានបង្ហាញភាពត្រឹមត្រូវ នូវស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ និងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ 34 "របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"។ គិតត្រឹមកាលបរិច្ឆេទចេញផ្សាយរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលជឿជាក់ថា ក្រុមហ៊ុនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទូទាត់រាល់បំណុលនៅពេលដល់កំណត់សង។

*ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល:*

ហត្ថាកសិករ លីមីតធីត ការិយាល័យកណ្តាល HKL Head Office HATTHA KAKSEKAR LIMITED

លោក **ហ្វូត អៀងតុង**
*ប្រធានអគ្គនាយក*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី14 ខែសីហា ឆ្នាំ2019

Deloitte.

Deloitte (Cambodia) Co., Ltd.
Vattanac Capital Tower
Floor 8, Unit 8, #66
Preah Monivong Blvd
Sangkat Wat Phnom
Khan Duan Penh
Phnom Penh, Cambodia

Tel: +855 (0) 23 963 777
Fax: +855 (0) 23 963 778
www.deloitte.com/kh

# របាយការណ៍ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ជូនចំពោះភាគទុនិក ហត្ថាកសិករ លីមីតធីត

## សេចក្តីផ្តើម

យើងខ្ញុំបានធ្វើការត្រួតពិនិត្យរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ របស់ក្រុមហ៊ុន **ហត្ថាកសិករ លីមីតធីត** (ហៅកាត់ថា "ក្រុមហ៊ុន" ឬ "អេច ខេ អិល") គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 រួមទាំងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ព្រមទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ និងកំណត់សម្គាល់ពន្យល់ផ្សេងៗទៀត។ គណៈគ្រប់គ្រងទទួលខុសត្រូវ ក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ដោយស្របទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ 34 ស្តីពី "របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើសេចក្តីសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកទៅលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## ដែនកំណត់នៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យដោយអនុលោមទៅតាម ស្តង់ដាអន្តរជាតិនៃកម្ពុជាស្តីពីការត្រួតពិនិត្យ លេខ 2410 ស្តីពី "ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុដែលធ្វើឡើងដោយសវនករឯករាជរបស់អង្គភាព"។ ការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ រួមមានការចោទជាសំណួរទៅអ្នកទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ ការអនុវត្តលក្ខណៈវិភាគ និងនីតិវិធីត្រួតពិនិត្យផ្សេងៗទៀត។ ការត្រួតពិនិត្យ មានដែនកំណត់តូចជាងការធ្វើសវនកម្ម ដែលអនុលោមទៅតាមស្តង់ដាអន្តរជាតិនៃកម្ពុជាស្តីពីសវនកម្ម។ ជាលទ្ធផល ការត្រួតពិនិត្យនេះមិនអាចធ្វើឱ្យយើងខ្ញុំធ្វើការធានាអះអាងអំពីបញ្ហាសំខាន់ៗ ដូចដែលយើងខ្ញុំអាចដឹងក្នុងការធ្វើសវនកម្មនោះទេ។ ដូច្នេះយើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មទេ។

## សេចក្តីសន្និដ្ឋាន

យោងទៅតាមការត្រួតពិនិត្យរបស់យើងខ្ញុំ យើងខ្ញុំកត់សម្គាល់ឃើញថាមិនមានបញ្ហាណាមួយ ដែលធ្វើឱ្យយើងខ្ញុំជឿជាក់ថា របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ មិនបានរៀបចំនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយស្របទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ 34 ស្តីពី "របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល" នោះទេ។



Deloitte refers to one or more of Deloitte Touche Tohmatsu Limited, a UK private company limited by guarantee ("DTTL"), its network of member firms, and their related entities. DTTL and each of its member firms are legally separate and independent entities. DTTL (also referred to as "Deloitte Global") does not provide services to clients. Please see www.deloitte.com/kh/about to learn more about our global network of member firms.

Deloitte.

**បញ្ហាផ្សេងៗ**

យើងខ្ញុំសូមទាញចំណាប់អារម្មណ៍ថា ក្រុមហ៊ុនបានរៀបចំ និងបង្ហាញរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 របាយការណ៍បម្រែបម្រួលមូលធន និងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ក្នុងគោលបំណងដើម្បីធ្វើការប្រៀបធៀបតែប៉ុណ្ណោះ។ របាយការណ៍ទាំងនេះ រួមទាំងកំណត់សម្គាល់ដែលពាក់ព័ន្ធ មិនត្រូវបានធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មឡើយ។

តំណាងក្រុមហ៊ុន **ឌីឡូយធ៍ (ខេមបូឌា) ខូអិលធីឌី**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ឌីឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី
Deloitte (Cambodia) Co., Ltd.
KINGDOM OF CAMBODIA

អ៊ឹង គឹមសុភ័ក្រ្តា
នាយក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី14 ខែសីហា ឆ្នាំ2019

# ហត្ថាកសិករ លីមីតធីត
# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
# គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

| | កំណត់ | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | | ថ្ងៃទី1 ខែមករា ឆ្នាំ2018 | |
|---|---|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទ្រព្យសកម្ម | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | | 26,268,257 | 106,806,733 | 37,211,155 | 149,514,421 | 9,923,604 | 40,061,589 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 6 | 74,607,763 | 303,355,164 | 77,602,188 | 311,805,591 | 41,264,136 | 166,583,317 |
| សមតុល្យនៅធនាគារនានា | 7 | 65,121,823 | 264,785,332 | 39,594,315 | 159,089,958 | 57,035,505 | 230,252,334 |
| ឥណទានផ្តល់ដល់អតិថិជន | 8 | 865,400,890 | 3,518,720,019 | 741,839,028 | 2,980,709,215 | 564,202,315 | 2,277,684,746 |
| វិនិយោគលើមូលបត្រ | 9 | 20,000 | 81,320 | 20,000 | 80,360 | 20,000 | 80,740 |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | 10 | 3,720,122 | 15,126,016 | 4,148,634 | 16,669,211 | 3,958,984 | 15,982,418 |
| សិទ្ធិក្នុងការប្រើទ្រព្យសកម្ម | 11 | 12,258,007 | 49,841,056 | 12,788,265 | 51,383,249 | 13,225,717 | 53,392,220 |
| ទ្រព្យសកម្មអរូបី | 12 | 1,351,530 | 5,495,321 | 835,911 | 3,358,690 | 611,726 | 2,469,538 |
| ពន្ធពន្យារជាទ្រព្យសកម្ម-សុទ្ធ | 13(ក) | 3,519,597 | 14,310,681 | 3,100,212 | 12,456,652 | 1,876,639 | 7,575,992 |
| ទ្រព្យសកម្មផ្សេងៗ | 14 | 9,181,635 | 37,332,528 | 7,938,877 | 31,898,408 | 7,477,818 | 30,187,951 |
| **សរុបទ្រព្យសកម្ម** | | **1,061,449,624** | **4,315,854,170** | **925,078,585** | **3,716,965,755** | **699,596,444** | **2,824,270,845** |

# ហត្ថាកសិករ លីមីតធីត
# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ត)
# គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

| | កំណត់ | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | | ថ្ងៃទី1 ខែមករា ឆ្នាំ2018 | |
|---|---|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **បំណុល** | | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 15 | 574,045,523 | 2,334,069,097 | 491,353,390 | 1,974,257,921 | 375,822,867 | 1,517,196,914 |
| មូលបត្របំណុល | 16 | 29,122,787 | 118,413,252 | 29,325,252 | 117,828,863 | - | - |
| ប្រាក់កម្ចី | 17 | 241,369,509 | 981,408,424 | 191,725,158 | 770,351,685 | 175,448,992 | 708,287,581 |
| អនុបំណុល | 18 | 15,548,256 | 63,219,209 | 23,236,296 | 93,363,437 | 25,258,299 | 101,967,753 |
| និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | 19 | 902,068 | 3,667,808 | 27,794 | 111,676 | 358,020 | 1,445,327 |
| បំណុលពន្ធលើប្រាក់ចំណេញ | 13(ខ) | 2,971,742 | 12,083,103 | 4,862,542 | 19,537,694 | 3,510,009 | 14,169,906 |
| បំណុលភតិសន្យា | 20 | 12,817,656 | 52,116,589 | 13,172,448 | 52,926,896 | 13,101,606 | 52,891,183 |
| សំវិធានធន | 21 | 26,422 | 107,432 | 3,599 | 14,461 | 4,731 | 19,099 |
| បំណុលផ្សេងៗ | 22 | 6,050,583 | 24,601,670 | 5,127,753 | 20,603,312 | 3,841,293 | 15,507,300 |
| **សរុបបំណុល** | | **882,854,546** | **3,589,686,584** | **758,834,232** | **3,048,995,945** | **597,345,817** | **2,411,485,063** |
| **មូលធន** | | | | | | | |
| ដើមទុន | 23 | 75,000,000 | 304,950,000 | 75,000,000 | 301,350,000 | 30,000,000 | 121,110,000 |
| បុព្វលាភភាគហ៊ុន | | 19,082,502 | 77,589,453 | 19,082,502 | 76,673,493 | 19,082,502 | 77,036,061 |
| ទុនបម្រុង | 24 | 6,347,044 | 29,444,703 | 4,389,187 | 17,635,753 | 2,721,101 | 10,985,085 |
| ប្រាក់ចំណេញរក្សាទុក | | 78,165,532 | 314,183,430 | 67,772,664 | 272,310,564 | 50,447,024 | 203,654,636 |
| **សរុបមូលធន** | | **178,595,078** | **726,167,586** | **166,244,353** | **667,969,810** | **102,250,627** | **412,785,782** |
| **សរុបបំណុល និងមូលធន** | | **1,061,449,624** | **4,315,854,170** | **925,078,585** | **3,716,965,755** | **699,596,444** | **2,824,270,845** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី11 ដល់ទី107 គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**ហត្ថាកសិករ លីមីតធីត**
**របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ3ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019**

| | កំណត់ សម្គាល់ | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 ដុល្លារអាមេរិក | ពាន់រៀល | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|---|---|---|
| | | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណូលពីការប្រាក់ | 25 | 34,085,933 | 138,062,532 | 26,774,599 | 108,306,981 |
| ចំណាយលើការប្រាក់ | 25 | (14,674,605) | (59,434,932) | (11,498,688) | (46,502,876) |
| **ចំណូលសុទ្ធពីការប្រាក់** | | **19,411,328** | **78,627,600** | **15,275,911** | **61,804,105** |
| ចំណូលពីកម្រៃជើងសារ | 26 | 1,107,915 | 4,491,757 | 586,159 | 2,371,063 |
| ចំណាយលើកម្រៃជើងសារ | 26 | (188,748) | (764,653) | (183,580) | (742,767) |
| **ចំណូលសុទ្ធពីកម្រៃជើងសារ** | | **919,167** | **3,727,104** | **402,579** | **1,628,296** |
| ការ(ខាត)/ចំណេញសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL | 27 | (433,407) | (1,755,149) | 121,089 | 486,407 |
| ចំណូលផ្សេងៗ | 28 | 33,745 | 140,065 | (423,705) | (1,702,987) |
| ការខាតបង់សុទ្ធពីការធ្លាក់ចុះតម្លៃឧបករណ៍ហិរញ្ញវត្ថុ | 29 | (223,681) | (904,813) | (889,704) | (3,597,050) |
| ចំណាយបុគ្គលិក | 30 | (8,338,720) | (33,779,335) | (6,197,545) | (25,084,147) |
| ចំណាយរំលស់ | 31 | (1,334,945) | (5,408,625) | (1,272,901) | (5,149,235) |
| ចំណាយផ្សេងៗ | 32 | (2,105,981) | (8,528,984) | (2,032,340) | (8,221,264) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | **7,927,506** | **32,117,863** | **4,983,384** | **20,164,125** |
| ពន្ធលើប្រាក់ចំណេញ | 13(គ) | (1,592,514) | (6,455,816) | (1,011,180) | (4,091,604) |
| **ប្រាក់ចំណេញក្នុងគ្រា** | | **6,334,992** | **25,662,047** | **3,972,204** | **16,072,521** |
| ចំណូលលម្អិតផ្សេងៗ | | - | 3,795,197 | - | 3,444,977 |
| **សរុបប្រាក់ចំណេញក្នុងគ្រា** | | **6,334,992** | **29,457,244** | **3,972,204** | **19,517,498** |
| **ប្រាក់ចំណេញផ្ទាល់របស់ម្ចាស់ហ៊ុន** | | **6,334,992** | **25,662,047** | **3,972,204** | **16,072,521** |
| **សរុបប្រាក់ចំណេញផ្ទាល់របស់ម្ចាស់ហ៊ុន** | | **6,334,992** | **29,457,244** | **3,972,204** | **19,517,498** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី11 ដល់ទី107 គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ហត្ថាកសិករ លីមីតធីត
## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

| | កំណត់សម្គាល់ | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណូលពីការប្រាក់ | 25 | 65,838,464 | 265,263,171 | 52,193,528 | 210,287,724 |
| ចំណាយលើការប្រាក់ | 25 | (28,194,091) | (113,593,993) | (21,772,926) | (87,723,119) |
| **ចំណូលសុទ្ធពីការប្រាក់** | | **37,644,373** | **151,669,178** | **30,420,602** | **122,564,605** |
| ចំណូលពីកម្រៃជើងសារ | 26 | 2,323,894 | 9,362,969 | 1,140,751 | 4,596,086 |
| ចំណាយលើកម្រៃជើងសារ | 26 | (370,808) | (1,493,985) | (367,313) | (1,479,904) |
| **ចំណូលសុទ្ធពីកម្រៃជើងសារ** | | **1,953,086** | **7,868,984** | **773,438** | **3,116,182** |
| ការ(ខាត)/ចំណេញសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL | 27 | (822,660) | (3,314,497) | 35,177 | 141,728 |
| ចំណូលផ្សេងៗ | 28 | 212,260 | 855,196 | (181,358) | (730,691) |
| ការខាតបង់សុទ្ធពីការធ្លាក់ចុះតម្លៃឧបករណ៍ហិរញ្ញវត្ថុ | 29 | (380,306) | (1,532,253) | (1,621,079) | (6,531,327) |
| ចំណាយបុគ្គលិក | 30 | (16,279,255) | (65,589,118) | (12,917,407) | (52,044,233) |
| ចំណាយរំលស់ | 31 | (2,645,034) | (10,656,842) | (2,491,560) | (10,038,495) |
| ចំណាយផ្សេងៗ | 32 | (4,018,449) | (16,190,331) | (3,971,511) | (16,001,218) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | **15,664,015** | **63,110,317** | **10,046,302** | **40,476,551** |
| ពន្ធលើប្រាក់ចំណេញ | 13(គ) | (3,313,290) | (13,349,245) | (2,044,143) | (8,235,852) |
| **ប្រាក់ចំណេញក្នុងគ្រា** | | **12,350,725** | **49,761,072** | **8,002,159** | **32,240,699** |
| ចំណូលលម្អិតផ្សេងៗ | | - | 3,637,622 | - | 1,542,237 |
| **សរុបប្រាក់ចំណេញក្នុងគ្រា** | | **12,350,725** | **53,398,694** | **8,002,159** | **33,782,936** |
| **ប្រាក់ចំណេញផ្ទាល់របស់ម្ចាស់ហ៊ុន** | | **12,350,725** | **49,761,072** | **8,002,159** | **32,240,699** |
| **សរុបប្រាក់ចំណេញផ្ទាល់របស់ម្ចាស់ហ៊ុន** | | **12,350,725** | **53,398,694** | **8,002,159** | **33,782,936** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី11 ដល់ទី107 គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**ហត្ថាកសិករ លីមីតធីត**

**របាយការណ៍បម្រែបម្រួលមូលធន**

**សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019**

| | មូលធនផ្ទាល់របស់ម្ចាស់ហ៊ុន | | | | |
|---|---|---|---|---|---|
| | ដើមទុន | បុព្វលាភភាគហ៊ុន | ទុនបម្រុង | ប្រាក់ចំណេញរក្សាទុក | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | | | | | |
| (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | | | | | |
| **ថ្ងៃទី1 ខែមករា ឆ្នាំ2018** | 30,000,000 | 19,082,502 | 2,721,101 | 50,447,024 | 102,250,627 |
| ប្រាក់ចំណេញក្នុងគ្រា | - | - | - | 8,002,159 | 8,002,159 |
| ចំណូលលម្អិតផ្សេងៗ | - | - | - | - | - |
| **សរុបប្រាក់ចំណេញក្នុងគ្រា** | **-** | **-** | **-** | **8,002,159** | **8,002,159** |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | 1,219,372 | (1,219,372) | - |
| **ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018** | **30,000,000** | **19,082,502** | **3,940,473** | **57,229,811** | **110,252,786** |
| **សមមូលជាពាន់រៀល** | **121,890,000** | **77,532,206** | **17,552,379** | **230,982,485** | **447,957,070** |
| សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | | | | |
| **ថ្ងៃទី1 ខែមករា ឆ្នាំ2019** | 75,000,000 | 19,082,502 | 4,389,187 | 67,772,664 | 166,244,353 |
| ប្រាក់ចំណេញក្នុងគ្រា | - | - | - | 12,350,725 | 12,350,725 |
| ចំណូលលម្អិតផ្សេងៗ | - | - | - | - | - |
| **សរុបប្រាក់ចំណេញក្នុងគ្រា** | **-** | **-** | **-** | **12,350,725** | **12,350,725** |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | 1,957,857 | (1,957,857) | - |
| **ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019** | **75,000,000** | **19,082,502** | **6,347,044** | **78,165,532** | **178,595,078** |
| **សមមូលជាពាន់រៀល** | **304,950,000** | **77,589,453** | **29,444,703** | **314,183,430** | **726,167,586** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ ចាប់ពីទំព័រទី11 ដល់ទី107 គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ហត្ថាកសិករ លីមីតធីត

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៦ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

| | កំណត់ | ដំណាច់ការិយបរិច្ឆេទ ៦ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ ៦ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញក្នុងគ្រា | | 12,350,725 | 49,761,072 | 8,002,159 | 32,240,699 |
| *និយ័តភាព៖* | | | | | |
| ចំណូលពីការប្រាក់សុទ្ធ | 25 | (37,644,373) | (151,669,178) | (30,420,602) | (122,564,605) |
| ចំណូលសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុនានាវាស់វែងតាម FVTPL | | 822,660 | 3,314,497 | (35,177) | (141,728) |
| ការខាតបង់សុទ្ធពីការធ្លាក់ចុះតម្លៃឧបករណ៍ហិរញ្ញវត្ថុ | | 380,306 | 1,532,253 | 1,621,079 | 6,531,327 |
| ចំណាយរំលស់ | | 2,645,034 | 10,656,842 | 2,491,560 | 10,038,495 |
| ចំណាយបុគ្គលិកផ្សេងៗ | | 634,658 | 2,557,037 | 613,652 | 2,472,404 |
| ខាត/(ចំណេញ)ពីការលក់ទ្រព្យសម្បត្តិនិងបរិក្ខារ | | 450 | 1,813 | (181) | (729) |
| ចំណាយពន្ធលើប្រាក់ចំណេញ | | 3,313,290 | 13,349,245 | 2,044,143 | 8,235,852 |
| លម្អៀងពីការប្តូររូបិយប័ណ្ណធាតុជារូបិយវត្ថុ | | (11,588) | (46,688) | (143,220) | (581,903) |
| | | **(17,508,838)** | **(70,543,107)** | **(15,826,587)** | **(63,770,188)** |
| *បម្រែបម្រួល:* | | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | | (10,971,462) | (44,204,020) | (4,150,000) | (16,720,350) |
| ឥណទានផ្តល់ដល់អតិថិជន | | (125,465,320) | (505,499,774) | (86,550,154) | (348,710,570) |
| ទ្រព្យសកម្មផ្សេងៗ | | (669,759) | (2,698,459) | (555,333) | (2,237,437) |
| ប្រាក់បញ្ញើរបស់អតិថិជន | | 82,256,481 | 331,411,362 | 41,406,458 | 166,826,619 |
| បំណុលផ្សេងៗ | | 922,830 | 3,718,082 | 1,039,976 | 4,190,063 |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | | (71,436,068) | (287,815,916) | (64,635,640) | (260,421,863) |
| | | | | | |
| ការប្រាក់បានទទួល | | 66,273,358 | 267,015,359 | 53,348,004 | 214,939,108 |
| ការប្រាក់បានបង់ | | (27,222,024) | (109,677,535) | (23,044,367) | (92,845,755) |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (5,623,475) | (22,656,981) | (3,981,910) | (16,043,115) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | | **(38,008,209)** | **(153,135,073)** | **(38,313,913)** | **(154,371,625)** |

## ហត្ថាភសិករ លីមីតធីត

## របាយការណ៍លំហូរសាច់ប្រាក់ (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

| | កំណត់សម្គាល់ | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 ដុល្លារអាមេរិក | ពាន់រៀល | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|---|---|---|
| | | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | | (684,696) | (2,758,640) | (855,517) | (3,446,878) |
| ការទិញទ្រព្យសកម្មអរូបី | | (618,068) | (2,490,196) | (28,875) | (116,337) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | 732 | 2,949 | 183 | 737 |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(1,302,032)** | **(5,245,887)** | **(884,209)** | **(3,562,478)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | 85,326,978 | 343,782,394 | 103,915,971 | 418,677,447 |
| ការទូទាត់សងប្រាក់កម្ចី | | (36,095,564) | (145,429,027) | (39,490,459) | (159,107,059) |
| ការទូទាត់សងអនុបំណុល | | (7,500,000) | (30,217,500) | (1,000,000) | (4,029,000) |
| ការទូទាត់សងប្រាក់ដើមភតិសន្យា | | (1,735,890) | (6,993,901) | (1,466,653) | (5,909,145) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | **39,995,524** | **161,141,966** | **61,958,859** | **249,632,243** |
| **ការកើនឡើងសុទ្ធនូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | 685,283 | 2,761,006 | 22,760,737 | 91,698,140 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមគ្រា | | 106,976,320 | 429,830,854 | 75,177,800 | 303,492,778 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 5,160,218 | - | 2,733,358 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងគ្រា** | 33 | **107,661,603** | **437,752,078** | **97,938,537** | **397,924,276** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ ចាប់ពីទំព័រទី11 ដល់ទី107 គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ហត្ថាកសិករ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

## 1. អំពីក្រុមហ៊ុន

ហត្ថាកសិករ គឺជាអង្គការក្រៅរដ្ឋាភិបាល (ហៅកាត់ថា "អង្គការក្រៅរដ្ឋាភិបាល") ដែលបានបង្កើតឡើងនៅខែវិច្ឆិកា ឆ្នាំ1996 និងបានប្រែក្លាយទៅជាក្រុមហ៊ុន **ហត្ថាកសិករ លីមីតធីត** (ហៅកាត់ថា "អេច ខេ អិល" ឬ "ក្រុមហ៊ុន") ដើម្បីឱ្យស្របតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា តាមប្រកាសលេខ B7-00-06 ប្រ.ក ចុះថ្ងៃទី11 ខែមករា ឆ្នាំ2000 ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ការបង្កើត អេច ខេ អិល បានប្រែក្លាយប្រតិបត្តិការលើសកម្មភាពផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុរបស់អង្គការក្រៅរដ្ឋាភិបាល ឱ្យទៅជាស្ថាប័នមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ។ គោលដៅរបស់ អេច ខេ អិល គឺធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ និងអាជីវកម្មធនាគារ ដោយអនុលោមទៅតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ អេច ខេ អិល បានធ្វើការផ្លាស់ប្តូរពីអង្គការក្រៅរដ្ឋាភិបាលទៅជា ហត្ថាកសិករ លីមីតធីត ជាផ្លូវការនៅថ្ងៃទី27 ខែមេសា ឆ្នាំ2001 ដោយបង្វែររាល់ទ្រព្យសកម្ម និងបំណុលទាំងឡាយដែលមានដូចជា កិច្ចសន្យាផ្តល់ជំនួយ និងទ្រព្យសកម្មត្រូវទទួលពីកិច្ចសន្យាទាំងនេះ លក្ខខណ្ឌនិងកាតព្វកិច្ចដែលទាក់ទងនឹងកម្ចី កិច្ចសន្យាការងារ លក្ខខណ្ឌអត្ថប្រយោជន៍និយោជិត កិច្ចសន្យាជួលអគារឬផ្ទះ សម្រាប់សាខា ឬទីស្នាក់ការកណ្តាល និងរាល់ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុរបស់អង្គការក្រៅរដ្ឋាភិបាលទៅឱ្យ អេច ខេ អិល។ ការផ្ទេរខាងលើនេះ ត្រូវបានធ្វើឡើងក្រោមកិច្ចព្រមព្រៀងស្តីពីការផ្ទេរទ្រព្យសកម្ម និងបំណុល និងកិច្ចព្រមព្រៀងស្តីពីអនុបំណុលរវាងអង្គការក្រៅរដ្ឋាភិបាល និង អេច ខេ អិល ចុះថ្ងៃទី27 ខែមេសា ឆ្នាំ2001។

នាថ្ងៃទី27 ខែមេសា ឆ្នាំ2001 ក្រសួងពាណិជ្ជកម្មបានផ្តល់អាជ្ញាប័ណ្ណអាជីវកម្ម ចុះថ្ងៃទី3 ខែមេសា ឆ្នាំ2001 ដល់ អេច ខេ អិល ក្នុងការប្រតិបត្តិជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ដើម្បីផ្តល់សេវាកម្មឥណទាន និងប្រាក់សន្សំដល់ចំណែកទីផ្សារថ្នាក់ទាប។ នាថ្ងៃទី19 ខែតុលា ឆ្នាំ2001 ក្រោមអាជ្ញាប័ណ្ណលេខ2 ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់ អេច ខេ អិល សម្រាប់ការប្រតិបត្តិជាស្ថាប័នមីក្រូហិរញ្ញវត្ថុ រយៈពេលបីឆ្នាំដែលផុតសុពលភាពនៅថ្ងៃទី19 ខែតុលា ឆ្នាំ2004។ នាថ្ងៃទី12 ខែកក្កដា ឆ្នាំ2004 អេច ខេ អិល ទទួលបានអាជ្ញាប័ណ្ណថ្មីមួយទៀត រយៈពេលបីឆ្នាំដែលផុតសុពលភាពនៅថ្ងៃទី19 ខែតុលា ឆ្នាំ2007។ ធនាគារជាតិនៃកម្ពុជាបានផ្តល់ក្រុមហ៊ុននូវ អាជ្ញាប័ណ្ណមិនកំណត់ចិរវេលា ដែលមានសុពលភាពចាប់ពីថ្ងៃទី8 ខែសីហា ឆ្នាំ2007 តទៅ។

នាថ្ងៃទី29 ខែមករា ឆ្នាំ2010 ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់ អេច ខេ អិល ដើម្បីប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីសាធារណជន។

នៅថ្ងៃទី9 ខែតុលា ឆ្នាំ2013 ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់ អេច ខេ អិល ដើម្បីធ្វើប្រតិបត្តិការធនាគារចល័ត រួមមានសេវាកម្មដូចជា (1) ពិនិត្យសមតុល្យគណនី (2) របាយការណ៍សង្ខេប (3) ស្វែងរកទីតាំងម៉ាស៊ីន ATM (4) ការផ្ទេរប្រាក់ពីគណនី (5) ការទិញកាតទូរស័ព្ទ (6) សងឥណទាន (7) ពិនិត្យអត្រា ការប្រាក់ (8) ពិនិត្យអត្រាប្តូរប្រាក់ (9) សាររំលឹកពីការសងឥណទាន (10) ការផ្សព្វផ្សាយតាមរយៈទូរស័ព្ទ ចល័ត និង (11) សារជូនដំណឹង។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់ អេច ខេ អិល ជាភ្នាក់ងារធានារ៉ាប់រង ដោយដើរតួជាអ្នកណែនាំសេវាធានារ៉ាប់រងដល់អតិថិជនឱ្យក្រុមហ៊ុន ប្រេវ៉រ (កម្ពុជា) ម៉ាយក្រូ ឡាយហ្វ៍ អ៊ិនសួរេន ភីអិលស៊ី នៅថ្ងៃទី19 ខែធ្នូ ឆ្នាំ2014 និងឱ្យក្រុមហ៊ុន សុវណ្ណាភូមិ ឡាយហ្វ៍ អាសួរេន ភីអិលស៊ី នៅថ្ងៃទី29 ខែធ្នូ ឆ្នាំ2017។

## ហត្ថាកសិករ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

## 1. អំពីក្រុមហ៊ុន (ត)

សកម្មភាពចម្បងរបស់ អេច ខេ អិល គឺការផ្តល់សេវាឥណទាន សេវាប្រាក់សន្សំ និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត ជាពិសេសផ្តល់ដល់ស្រ្តី និងគ្រួសារដែលមានចំណូលទាបតាមរយៈទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និង ការិយាល័យតាមបណ្តាខេត្តផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អេច ខេ អិល មានប្រតិបត្តិការនៅការិយាល័យចំនួន 178 (មិនរួមបញ្ចូលការិយាល័យកណ្តាល) ដែលមានទីតាំង នៅរាជធានីភ្នំពេញ និងគ្រប់ខេត្តក្រុង ដោយមានប្រភពចំណូលចម្បងពីការប្រាក់ទទួលបានពីការផ្តល់ឥណទានផ្តល់ដល់ អតិថិជន។

ក្រុមហ៊ុនមានទីស្នាក់ការកណ្តាល នៅផ្ទះលេខ 606 ផ្លូវលេខ 271 ភូមិសន្សំកុសល៣ សង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី14 ខែសីហា ឆ្នាំ2019។

## 2. មូលដ្ឋានគណនេយ្យ

### 2.1 មូលដ្ឋាននៃការរៀបចំ

នេះគឺជារបាយការណ៍ហិរញ្ញវត្ថុ ដែលរៀបចំជាលើកដំបូង ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ប្រកាសលេខ 068 សហវ-ប្រក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2009) និងដោយក្រុមប្រឹក្សាជាតិគណនេយ្យនៃកម្ពុជា (លិខិតចុះថ្ងៃទី24 ខែមីនា ឆ្នាំ2016)។

កាលបរិច្ឆេទអន្តរកាលគឺថ្ងៃទី1 ខែមករា ឆ្នាំ2018 ដែលនាំឱ្យមានការផ្លាស់ប្តូរនូវគោលនយោបាយ គណនេយ្យ និងនិយ័តភាពលើចំនួនដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុកាលពីពេលមុន។ ការផ្ទៀងផ្ទាត់ និងការពន្យល់ពីការប៉ះពាល់នៃអន្តរកាលទៅ CIFRS មានបង្ហាញនៅកំណត់សម្គាល់ទី3។

### 2.2 រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់ការបង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើរូបិយប័ណ្ណចំនួន3 គឺប្រាក់រៀល ប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ។ គណៈគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណគោល និងជារូបិយប័ណ្ណសម្រាប់ការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសមាសធាតុសេដ្ឋកិច្ច នៃព្រឹត្តិការណ៍ មូលដ្ឋាន និង កាលៈទេសៈរបស់ក្រុមហ៊ុន។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្រែសម្រួលទៅជា ប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។ ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុ នាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្រែសម្រួលទៅជាប្រាក់ដុល្លារ អាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនោះ។ ធាតុមិនមែនរូបិយវត្ថុ ដែលត្រូវបានវាស់វែងតាមតម្លៃ សមស្របនៅក្នុងរូបិយប័ណ្ណបរទេស ត្រូវបានប្រែសម្រួលដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទដែលតម្លៃសមស្រប ត្រូវបានកំណត់។ ធាតុមិនមែនរូបិយវត្ថុ ដែលត្រូវបានវាស់វែងនៅក្នុងលក្ខខណ្ឌថ្លៃដើមប្រវត្តិសាស្ត្រជារូបិយប័ណ្ណ បរទេស មិនត្រូវបានប្រែសម្រួលម្តងទៀតទេ។

ភាពលម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត។

## 2. មូលដ្ឋានគណនេយ្យ (ត)

### 2.3 ការបង្ហាញជារូបិយប័ណ្ណប្រាក់រៀល

អនុលោមតាមច្បាប់ស្តីពី គណនេយ្យនិងសវនកម្ម គណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ចុះថ្ងៃទី11 ខែមេសា ឆ្នាំ2016 ការកត់ត្រាប្តូរពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀលដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយប្រើប្រាស់អត្រាចុងការិយបរិច្ឆេទ និងអត្រាមធ្យម ដូចដែលបានប្រកាសដោយធនាគារជាតិនៃកម្ពុជា។

ទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗដែលបានបង្ហាញ ត្រូវបានប្តូរតាមអត្រាចុងការិយបរិច្ឆេទនាកាលបរិច្ឆេទនៃរបាយការណ៍ ដោយឡែកខ្ទង់ចំណូល និងចំណាយ នៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ និងខ្ទង់នៅក្នុងលំហូរសាច់ប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រាមធ្យម។ លទ្ធផលនៃភាពលម្អៀងដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានកត់ត្រាក្នុងចំណូលលម្អិតផ្សេងៗ (OCI)។

របាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញជាប្រាក់រៀល ត្រូវបានធ្វើឡើងដោយផ្អែកលើអត្រាប្តូរប្រាក់ក្នុងមួយដុល្លារអាមេរិកដូចខាងក្រោម៖

| | អត្រាចុងការិយបរិច្ឆេទ | អត្រាមធ្យម |
|---|---|---|
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | 4,066 | 4,029 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | 4,018 | 4,045 |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | 4,063 | 4,029 |
| ថ្ងៃទី1 ខែមករា ឆ្នាំ2018 | 4,037 | 4,045 |

### 2.4 មូលដ្ឋាននៃការសរុបរួម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ទីស្នាក់ការកណ្តាល និងបណ្តាសាខាតាមខេត្តក្រុងនានារបស់ខ្លួន។ រាល់សមតុល្យ និងប្រតិបត្តិការអន្តរសាខាទាំងអស់ ត្រូវបានលុបបំបាត់ចោល។

### 2.5 ការបង្គត់លេខ

តួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្គត់សម្រាប់ប្រាក់ដុល្លារអាមេរិក និងខ្ទង់ពាន់សម្រាប់ប្រាក់រៀល។

## 3. ការប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា

នៅក្នុងគ្រាបច្ចុប្បន្ននេះ អេច ខេ អិល បានប្រើស្តង់ដា CIFRS ជាលើកដំបូង។

CIFRS នាំមកនូវស្តង់ដាគណនេយ្យថ្មីៗ ដែលនៅក្នុងនោះ មានស្តង់ដាថ្មីចំនួនពីរ (CIFRS 9 និង CIFRS 16) ដែលមានផលប៉ះពាល់ជាសារវន្តដល់របាយការណ៍ហិរញ្ញវត្ថុរបស់ អេច ខេ អិល។ ស្តង់ដាថ្មីផ្សេងៗទៀត ក៏ត្រូវយកមកប្រើដែរ ប៉ុន្តែស្តង់ដាទាំងនោះមិនមានផលប៉ះពាល់ខ្លាំងដល់របាយការណ៍ហិរញ្ញវត្ថុរបស់ អេច ខេ អិល នោះទេ។

យោងតាមលក្ខខណ្ឌរបស់ CIFRS 1 សម្រាប់អ្នកប្រើ CIFRS ជាលើកដំបូង ត្រូវធ្វើការកែតម្រូវនូវព័ត៌មានប្រៀបធៀប។

### 3.1 CIFRS 9 ឧបករណ៍ហិរញ្ញវត្ថុ

CIFRS 9 កំណត់លក្ខខណ្ឌសម្រាប់ការទទួលស្គាល់ និងការវាស់វែង ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ ស្តង់ដាថ្មីនេះនាំមកជាចម្បងនូវការផ្លាស់ប្តូរគណនេយ្យសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខខណ្ឌគណនេយ្យមួយចំនួនសម្រាប់បំណុលហិរញ្ញវត្ថុ។ ការផ្លាស់ប្តូរសំខាន់ៗនៃគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនដោយសារការប្រើ CIFRS 9 មានសង្ខេបដូចខាងក្រោម៖

**ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ**

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ CIFRS 9 មានបីចំណាត់ថ្នាក់សំខាន់ៗគឺ ការវាស់វែងតាមតម្លៃដករំលស់ការវាស់វែងតាមតម្លៃសមស្របតាមរយៈប្រតិបត្តិការចំណូលលម្អិតផ្សេងៗ (FVOCI) និងការវាស់វែងតាមតម្លៃសមស្របតាមរយៈប្រតិបត្តិការចំណេញ-ខាត (FVTPL)។ ការធ្វើចំណាត់ថ្នាក់របស់ CIFRS 9 ជាទូទៅគឺផ្អែកទៅលើម៉ូឌែលអាជីវកម្មសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់តាមកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ស្តង់ដានេះ បានលុបចោលចំណាត់ថ្នាក់របស់ CFRS7 ដែលពីមុនបានចាត់ថ្នាក់ដូចជា រក្សាទុកដល់កាលកំណត់ឥណទាន និងគណនីត្រូវទទួល និងសម្រាប់ការលក់។

ចំពោះបំណុលហិរញ្ញវត្ថុ CIFRS 9 ភាគច្រើនរក្សានូវលក្ខខណ្ឌដែលមានស្រាប់ក្នុង CFRS7 លើកលែងតែការផ្លាស់ប្តូរតម្លៃសមស្របរបស់បំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាម FVTPL ដោយការផ្លាស់ប្តូរដែលកើតចេញពីការផ្លាស់ប្តូរហានិភ័យឥណទានរបស់ឧបករណ៍ហិរញ្ញវត្ថុ ត្រូវបង្ហាញនៅក្នុងចំណូលលម្អិតផ្សេងៗ។

**ការធ្លាក់ចុះតម្លៃរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ**

CIFRS 9 ជំនួសម៉ូឌែល "ការខាតបង់ដែលបានកើតឡើង" ដែលមានក្នុង CFRS 7 ដោយម៉ូឌែល "ការខាតបង់ឥណទានដែលរំពឹងទុក"។ ម៉ូឌែលការធ្លាក់ចុះតម្លៃថ្មីនេះ ក៏ត្រូវអនុវត្តផងដែរចំពោះកិច្ចសន្យាឥណទាន ប៉ុន្តែមិនត្រូវអនុវត្តនោះទេ ចំពោះការវិនិយោគក្នុងឧបករណ៍ហិរញ្ញវត្ថុទ្រព្យម្ចាស់។

តាមស្តង់ដា CIFRS 9 ការខាតបង់ឥណទាន ត្រូវទទួលស្គាល់លឿនជាង តាមស្តង់ដា CFRS 7។

## 3. ការប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ត)

### 3.1 CIFRS 9 ឧបករណ៍ហិរញ្ញវត្ថុ (ត)

**អន្តរកាល**

នាកាលបរិច្ឆេទអន្តរកាលទៅ CIFRS (ថ្ងៃទី1 ខែមករា ឆ្នាំ 2018) ក្រុមហ៊ុនបាន៖

- ចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុដោយវាស់វែងតាមតម្លៃដករំលស់ ដោយផ្អែកលើទិដ្ឋភាព និងភាពជាក់ស្តែងដែលមាននៅកាលបរិច្ឆេទអន្តរកាល ដែលបានបំពេញនូវលក្ខខណ្ឌខាងក្រោម ៖
  - ទ្រព្យសកម្មដែលមាននៅក្នុងម៉ូឌែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកសម្រាប់ការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា
  - លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (SPPI) តាមចំនួនប្រាក់ដើមដែលនៅជំពាក់តែប៉ុណ្ណោះ។
- ចាត់ថ្នាក់ការវិនិយោគក្នុងឧបករណ៍ហិរញ្ញវត្ថុទ្រព្យម្ចាស់ ដោយវាស់វែងតាម FVOCI ព្រោះការវិនិយោគនេះមិនមែនរក្សាទុកសម្រាប់ការជួញដូរ។
- ចាត់ថ្នាក់បំណុលហិរញ្ញវត្ថុដោយវាស់វែងតាមតម្លៃដករំលស់ ដោយសារតែបំណុលទាំងនោះ ពុំស្ថិតក្នុងចំណាត់ថ្នាក់វាស់វែងតាម FVTPL។
- អនុវត្តជាប្រតិសកម្មនូវវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់។
- អនុវត្តជាប្រតិសកម្មនូវលក្ខខណ្ឌនៃការធ្លាក់ចុះតម្លៃ ដោយប្រើព័ត៌មានដែលអាចជឿជាក់បាន និងមានស្រាប់ ដោយពុំចាំបាច់ធ្វើការចំណាយ ឬប្រឹងប្រែងណាមួយ ក្នុងការកំណត់នូវហានិភ័យឥណទាននៅកាលបរិច្ឆេទដែលឧបករណ៍ហិរញ្ញវត្ថុត្រូវទទួលស្គាល់ជាលើកដំបូង (ចំពោះកិច្ចសន្យាឥណទាន គឺនៅកាលបរិច្ឆេទដែលក្រុមហ៊ុនក្លាយជាគូភាគីនៃកិច្ចសន្យាដែលមិនអាចកែប្រែបាន) និងដោយធ្វើការប្រៀបធៀបហានិភ័យនោះ ជាមួយហានិភ័យឥណទាននៅកាលបរិច្ឆេទអន្តរកាលទៅ CIFRS ដើម្បីវាយតម្លៃថាតើមានការកើនឡើងនូវហានិភ័យឥណទានជាសារវន្តដែរឬទេចាប់តាំងពីការទទួលស្គាល់ជាលើកដំបូងមក។ ដើម្បីកំណត់ថាតើមានការកើនឡើងនូវហានិភ័យឥណទានជាសារវន្តដែរឬទេ ចាប់តាំងពីការទទួលស្គាល់ជាលើកដំបូងមក ក្រុមហ៊ុនត្រូវអនុវត្តនូវ (1) ការលើកលែងនូវហានិភ័យឥណទានកម្រិតទាប និង (2) ការសន្មតដែលអាចបដិសេធបានចំពោះការទូទាត់សងតាមកិច្ចសន្យា ដែលបានខកខានសងលើសពី 30ថ្ងៃ។

### 3.2 CIFRS 16 ភតិសន្យា

CIFRS 16 នាំមកនូវលក្ខខណ្ឌតម្រូវថ្មីពាក់ព័ន្ធនឹងគណនេយ្យភតិសន្យា។ ស្តង់ដានេះ បង្ហាញនូវការផ្លាស់ប្តូរជាសារវន្តចំពោះគណនេយ្យសម្រាប់ភតិក: ដោយលុបបំបាត់ចោលនូវភាពខុសគ្នារវាង ភតិសន្យាប្រតិបត្តិការ និងភតិសន្យាហិរញ្ញវត្ថុ និងតម្រូវឱ្យមានការទទួលស្គាល់សិទ្ធិក្នុងការប្រើទ្រព្យសកម្ម និងបំណុលភតិសន្យា នៅពេលចាប់ផ្តើមគ្រប់ភតិសន្យាទាំងអស់ លើកលែងតែភតិសន្យារយៈពេលខ្លី និងភតិសន្យារបស់ទ្រព្យសកម្មដែលមានតម្លៃទាប។

ការផ្លាស់ប្តូរសំខាន់ៗនៃគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ដោយសារការប្រើ CIFRS 16 មានសង្ខេបដូចខាងក្រោម៖

## 3. ការប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ត)

### 3.2 CIFRS 16 ភតិសន្យា (ត)

**គណនេយ្យសម្រាប់ភតិសន្យា**

CIFRS16 ផ្លាស់ប្តូររបៀបដែលក្រុមហ៊ុនទទួលស្គាល់ភតិសន្យា ដែលកាលពីមុន CAS 17 បានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ និងកត់ត្រានៅខ្ទង់ក្រៅតារាងតុល្យការ។

នៅពេលប្រើ CIFRS 16 ក្រុមហ៊ុនត្រូវ៖

- ទទួលស្គាល់សិទ្ធិក្នុងការប្រើទ្រព្យសកម្ម និងបំណុលភតិសន្យានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដោយវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យានាពេលអនាគត
- ទទួលស្គាល់ការរំលស់សិទ្ធិក្នុងការប្រើទ្រព្យសកម្ម និងការប្រាក់លើបំណុលភតិសន្យា នៅក្នុងចំណេញ-ខាត
- បំបែកទឹកប្រាក់បានបង់ជាប្រាក់ដើម (បង្ហាញនៅក្នុងសកម្មភាពហិរញ្ញប្បទាន) និងការប្រាក់ (បង្ហាញនៅក្នុងសកម្មភាពប្រតិបត្តិការ) នៅក្នុងចំណេញ-ខាត។

ផ្អែកទៅតាម CIFRS 16 សិទ្ធិក្នុងការប្រើទ្រព្យសកម្ម តម្រូវឱ្យមានការធ្វើតេស្តដើម្បីកំណត់ពីការធ្លាក់ចុះតម្លៃ ដោយអនុលោមតាម CIAS 36 ការធ្លាក់ចុះនៃតម្លៃទ្រព្យសកម្ម។

ចំពោះភតិសន្យារបស់ទ្រព្យសកម្មដែលមានតម្លៃទាប (ដូចជា ម៉ាស៊ីនហ្វូតូកូពី និងម៉ូតូ) ក្រុមហ៊ុនជ្រើសរើសយកការទទួលស្គាល់ចំណាយភតិសន្យាតាមមូលដ្ឋានថេរ ដូចដែលបានអនុញ្ញាតដោយ CIFRS 16។ ការចំណាយនេះ ត្រូវបានបង្ហាញជាចំណាយផ្សេងៗនៅក្នុងចំណេញ-ខាត។

**អន្តរកាល**

នាកាលបរិច្ឆេទអន្តរកាលទៅ CIFRS (ថ្ងៃទី1 ខែមករា ឆ្នាំ 2018) ក្រុមហ៊ុនបានជ្រើសយកការលើកលែងដូចខាងក្រោម៖

- វាយតម្លៃឡើងវិញនូវរាល់កិច្ចសន្យាទាំងអស់ដែលមាននៅថ្ងៃអន្តរកាល ថាតើកិច្ចសន្យាមានភតិសន្យាដែរឬទេ ដោយផ្អែកលើទិដ្ឋភាព និងភាពជាក់ស្តែងដែលមាននៅកាលបរិច្ឆេទអន្តរកាល។
- វាស់វែងបំណុលភតិសន្យាតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលនៅសល់ ដោយធ្វើអប្បហារតាមអត្រាកម្ចីបន្ថែម ដែលមានស្រាប់នៅកាលបរិច្ឆេទអន្តរកាល។
- វាស់វែងសិទ្ធិក្នុងការប្រើទ្រព្យសកម្ម តាមចំនួនដែលស្មើនឹងបំណុលភតិសន្យា ដោយកែតម្រូវនូវចំនួន ដែលបានបង់មុន ឬចំនួនដែលបានបង្គរពាក់ព័ន្ធនឹងភតិសន្យានោះ ដែលមាននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមុនកាលបរិច្ឆេទអន្តរកាល។
- ប្រើស្តង់ដា CIAS 36 ចំពោះ សិទ្ធិក្នុងការប្រើទ្រព្យសកម្ម នៅកាលបរិច្ឆេទអន្តរកាល។
- ប្រើអត្រាអប្បហារតែមួយ សម្រាប់បណ្តុំភតិសន្យា ដែលមានលក្ខណៈស្រដៀងគ្នា។
- ជ្រើសរើសមិនប្រើលក្ខខណ្ឌវាស់វែងចំពោះភតិសន្យាដែលមានកាលកំណត់ក្នុងរយៈពេល12ខែ ចាប់ពីកាលបរិច្ឆេទអន្តរកាល និងភតិសន្យារបស់ទ្រព្យសកម្មណាដែលមានតម្លៃទាប។ ផ្ទុយមកវិញ ក្រុមហ៊ុនទទួលស្គាល់ការទូទាត់ភតិសន្យាទាំងនោះ ជាចំណាយតាមមូលដ្ឋានថេរ ផ្អែកលើរយៈពេលភតិសន្យា។

## 3. ការប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ត)

### 3.3 ការប៉ះពាល់ហិរញ្ញវត្ថុដោយសារការប្រើ CIFRS លើកដំបូង

តារាងខាងក្រោមនេះ បង្ហាញពីចំនួនកែតម្រូវចំពោះធាតុរបាយការណ៍ហិរញ្ញវត្ថុ ដែលប៉ះពាល់ដោយសារការប្រើ CIFRS ក្នុងគ្រាបច្ចុប្បន្ន និងគ្រាមុនៗ។

(i) **ការប៉ះពាល់លើចំណេញ-ខាត**

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ថយចំណូលពីការប្រាក់ (ក) | (254,239) | (1,037,495) | (380,538) | (1,547,776) |
| កើនចំណាយលើការប្រាក់ (ឃ, ង) | (240,709) | (975,645) | (309,597) | (1,251,352) |
| កើនឬ(ថយ)ចំណូលពីកម្រៃជើងសារ (ញ) | (686) | (2,739) | 3,395 | 13,671 |
| ថយចំណាយលើកម្រៃជើងសារ (ញ) | (299) | (1,207) | (1,432) | (5,769) |
| កើនឬ(ថយ)ខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុ វាស់វែងតាម FVTPL (ច) | (473,116) | (1,915,006) | 315,569 | 1,272,678 |
| កើនឬ(ថយ)ចំណូលផ្សេងៗ(ញ) | 30,065 | 120,244 | (34,153) | (137,833) |
| ថយការខាតបង់ពីការធ្លាក់ចុះតម្លៃ របស់ឧបករណ៍ហិរញ្ញវត្ថុ (ក) | 979,519 | 3,967,293 | 169,150 | 694,338 |
| កើនចំណាយបុគ្គលិក (ក) | (326,985) | (1,324,442) | (241,805) | (980,688) |
| កើនចំណាយរំលស់ (ឃ) | (720,187) | (2,917,972) | (653,947) | (2,645,319) |
| ថយចំណាយផ្សេងៗ (ឃ) | 865,773 | 3,508,021 | 777,342 | 3,144,654 |
| ថយប្រាក់ចំណេញមុនដកពន្ធ | **(140,864)** | **(578,948)** | **(356,016)** | **(1,443,396)** |
| ថយពន្ធលើប្រាក់ចំណេញ (ជ) | 28,172 | 115,786 | 71,203 | 288,678 |
| **ថយប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **(112,692)** | **(463,162)** | **(284,813)** | **(1,154,718)** |

## 3. ការប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ត)

### 3.3 ការប៉ះពាល់ហិរញ្ញវត្ថុដោយសារការប្រើ CIFRS លើកដំបូង (ត)

#### (i) ការប៉ះពាល់លើចំណេញ-ខាត (ត)

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ថយចំណូលពីការប្រាក់ (ក) | (826,645) | (3,330,553) | (1,238,647) | (4,990,509) |
| កើនចំណាយលើការប្រាក់ (ឃ, ង) | (494,098) | (1,990,721) | (544,058) | (2,192,010) |
| កើនចំណូលពីកម្រៃជើងសារ (ញ) | 411 | 1,656 | 2,976 | 11,990 |
| ថយចំណាយលើកម្រៃជើងសារ (ញ) | (401) | (1,616) | (1,364) | (5,496) |
| កើនឬ(ថយ)ខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុ វាស់វែងតាម FVTPL (ច) | (856,672) | (3,451,531) | 389,140 | 1,567,845 |
| ថយចំណូលផ្សេងៗ (ញ) | (8,508) | (34,279) | (47,684) | (192,119) |
| ថយការខាតបង់ពីការធ្លាក់ចុះតម្លៃ របស់ឧបករណ៍ហិរញ្ញវត្ថុ (ក) | 1,884,360 | 7,592,086 | 924,001 | 3,722,800 |
| កើនចំណាយបុគ្គលិក (ក) | (632,170) | (2,547,013) | (621,539) | (2,504,181) |
| កើនចំណាយរំលស់ (ឃ) | (1,430,559) | (5,763,722) | (1,275,529) | (5,139,106) |
| ថយចំណាយផ្សេងៗ (ឃ) | 1,727,595 | 6,960,480 | 1,526,942 | 6,152,049 |
| ថយប្រាក់ចំណេញមុនដកពន្ធ | **(636,687)** | **(2,565,213)** | **(885,762)** | **(3,568,737)** |
| ថយពន្ធលើប្រាក់ចំណេញ (ជ) | 127,337 | 513,041 | 177,152 | 713,745 |
| **ថយប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **(509,350)** | **(2,052,172)** | **(708,610)** | **(2,854,992)** |

## 3. ការប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ត)

### 3.3 ការប៉ះពាល់ហិរញ្ញវត្ថុដោយសារការប្រើ CIFRS លើកដំបូង (ត)

### (ii) ការប៉ះពាល់លើទ្រព្យសកម្ម បំណុល និងមូលធន នាថ្ងៃទី1 ខែមករា ឆ្នាំ 2018

| | បង្ហាញតាម GAAP | កែតម្រូវ CIFRS | ថ្ងៃទី1 ខែមករា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា (ក) | 41,260,115 | 4,021 | 41,264,136 | 166,583,317 |
| សមតុល្យនៅធនាគារនានា (ក) | 57,097,552 | (62,047) | 57,035,505 | 230,252,334 |
| ឥណទានផ្តល់ដល់អតិថិជន (ក) | 567,536,202 | (3,333,887) | 564,202,315 | 2,277,684,746 |
| វិនិយោគលើមូលបត្រ (គ) | - | 20,000 | 20,000 | 80,740 |
| សិទ្ធិក្នុងការប្រើទ្រព្យសកម្ម (ឃ) | - | 13,225,717 | 13,225,717 | 53,392,220 |
| ពន្ធពន្យារជាទ្រព្យសកម្ម (ជ) | 1,269,418 | 607,221 | 1,876,639 | 7,575,992 |
| ទ្រព្យសកម្មផ្សេងៗ (ក,ខ,គ,ង) | 9,349,971 | (1,872,153) | 7,477,818 | 30,187,951 |
| ការប៉ះពាល់លើទ្រព្យសកម្មសរុប | | **8,588,872** | | |
| ប្រាក់បញ្ញើរបស់អតិថិជន (ង) | 367,421,079 | 8,401,788 | 375,822,867 | 1,517,196,914 |
| ប្រាក់កម្ចី (ង) | 156,384,184 | 19,064,808 | 175,448,992 | 708,287,581 |
| អនុបំណុល (ង) | 24,729,319 | 528,980 | 25,258,299 | 101,967,753 |
| និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ (ច) | - | 358,020 | 358,020 | 1,445,327 |
| បំណុលភតិសន្យា (ឃ) | - | 13,101,606 | 13,101,606 | 52,891,183 |
| សំវិធានធន (ឆ) | - | 4,731 | 4,731 | 19,099 |
| ទឹកប្រាក់ជំពាក់សម្ព័ន្ធញាតិ (ខ) | 19,203,772 | (19,203,772) | - | - |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ (ខ) | 132,601 | (132,601) | - | - |
| បំណុលផ្សេងៗ (ខ,ង,ច) | 14,235,922 | (10,394,629) | 3,841,293 | 15,507,300 |
| ការប៉ះពាល់លើបំណុលសរុប | | **11,728,931** | | |
| ទុនបម្រុង (ឈ) | 1,828,172 | 892,929 | 2,721,101 | 10,985,085 |
| ប្រាក់ចំណេញរក្សាទុក (ឈ) | 54,480,012 | (4,032,988) | 50,447,024 | 203,654,636 |
| ការប៉ះពាល់លើមូលធន | | **(3,140,059)** | | |
| ការប៉ះពាល់លើបំណុលនិងមូលធន | | **8,588,872** | | |

## 3. ការប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ត)

### 3.3 ការប៉ះពាល់ហិរញ្ញវត្ថុដោយសារការប្រើ CIFRS លើកដំបូង (ត)

### (iii) ការប៉ះពាល់លើទ្រព្យសកម្ម បំណុល និងមូលធន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ 2018

| | បង្ហាញតាម GAAP | កែតម្រូវ CIFRS | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា (ក) | 77,541,774 | 60,414 | 77,602,188 | 311,805,591 |
| សមតុល្យនៅធនាគារនានា (ក) | 39,210,636 | 383,679 | 39,594,315 | 159,089,958 |
| ឥណទានផ្តល់ដល់អតិថិជន (ក) | 747,005,064 | (5,166,036) | 741,839,028 | 2,980,709,215 |
| ទឹកប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ (ខ) | 14,692 | (14,692) | - | - |
| វិនិយោគលើមូលបត្រ (គ) | - | 20,000 | 20,000 | 80,360 |
| សិទ្ធិក្នុងការប្រើទ្រព្យសកម្ម (ឃ) | - | 12,788,265 | 12,788,265 | 51,383,249 |
| ពន្ធពន្យារជាទ្រព្យសកម្ម (ជ) | 1,871,271 | 1,228,941 | 3,100,212 | 12,456,652 |
| ទ្រព្យសកម្មផ្សេងៗ (ក,ខ,គ,ង) | 11,914,372 | (3,975,495) | 7,938,877 | 31,898,408 |
| ការប៉ះពាល់លើទ្រព្យសកម្មសរុប | | **5,325,076** | | |
| ប្រាក់បញ្ញើរបស់អតិថិជន (ង) | 480,093,541 | 11,259,849 | 491,353,390 | 1,974,257,921 |
| មូលបត្របំណុល (ង) | 29,865,605 | (540,353) | 29,325,252 | 117,828,863 |
| ប្រាក់កម្ចី (ង) | 192,384,932 | (659,774) | 191,725,158 | 770,351,685 |
| អនុបំណុល (ង) | 22,729,319 | 506,977 | 23,236,296 | 93,363,437 |
| និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ (ច) | - | 27,794 | 27,794 | 111,676 |
| បំណុលភតិសន្យា (ឃ) | - | 13,172,448 | 13,172,448 | 52,926,896 |
| សំវិធានធន (ឆ) | 11,298 | (7,699) | 3,599 | 14,461 |
| ទឹកប្រាក់ជំពាក់សម្ព័ន្ធញាតិ (ខ) | 135,322 | (135,322) | - | - |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ (ខ) | 12,580 | (12,580) | - | - |
| បំណុលផ្សេងៗ (ខ,ង,ច) | 18,498,255 | (13,370,502) | 5,127,753 | 20,603,312 |
| ការប៉ះពាល់លើបំណុលសរុប | | **10,240,838** | | |
| ទុនបម្រុង (ឈ) | 1,975,214 | 2,413,973 | 4,389,187 | 17,635,753 |
| ប្រាក់ចំណេញរក្សាទុក (ឈ) | 75,102,399 | (7,329,735) | 67,772,664 | 272,310,564 |
| ការប៉ះពាល់លើមូលធន | | **(4,915,762)** | | |
| ការប៉ះពាល់លើបំណុលនិងមូលធន | | **5,325,076** | | |

## 3. ការប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ត)

### 3.3 ការប៉ះពាល់ហិរញ្ញវត្ថុដោយសារការប្រើ CIFRS លើកដំបូង (ត)

### (iv) ការប៉ះពាល់លើទ្រព្យសកម្ម បំណុល និងមូលធន នាថ្ងៃទី30 ខែមិថុនា ឆ្នាំ 2019

| | បង្ហាញតាម GAAP | កែតម្រូវ CIFRS | ថ្ងៃទី30 ខែមិថុនា ឆ្នាំ 2019 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា (ក) | 74,562,206 | 45,557 | 74,607,763 | 303,355,164 |
| សមតុល្យនៅធនាគារនានា (ក) | 64,534,055 | 587,768 | 65,121,823 | 264,785,332 |
| ឥណទានផ្តល់ដល់អតិថិជន (ក) | 870,443,670 | (5,042,780) | 865,400,890 | 3,518,720,019 |
| ទឹកប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ (ខ) | 2,769 | (2,769) | - | - |
| វិនិយោគលើមូលបត្រ (គ) | - | 20,000 | 20,000 | 81,320 |
| សិទ្ធិក្នុងការប្រើទ្រព្យសកម្ម (ឃ) | - | 12,258,007 | 12,258,007 | 49,841,056 |
| ពន្ធពន្យារជាទ្រព្យសកម្ម (ជ) | 2,163,319 | 1,356,278 | 3,519,597 | 14,310,681 |
| ទ្រព្យសកម្មផ្សេងៗ (ក,ខ,គ,ង) | 12,878,392 | (3,696,757) | 9,181,635 | 37,332,528 |
| ការប៉ះពាល់លើទ្រព្យសកម្មសរុប | | **5,525,304** | | |
| ប្រាក់បញ្ញើរបស់អតិថិជន (ង) | 562,350,022 | 11,695,501 | 574,045,523 | 2,334,069,097 |
| មូលបត្របំណុល (ង) | 29,513,035 | (390,248) | 29,122,787 | 118,413,252 |
| ប្រាក់កម្ចី (ង) | 241,935,731 | (566,222) | 241,369,509 | 981,408,424 |
| អនុបំណុល (ង) | 15,229,319 | 318,937 | 15,548,256 | 63,219,209 |
| និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ (ច) | - | 902,068 | 902,068 | 3,667,808 |
| បំណុលភតិសន្យា (ឃ) | - | 12,817,656 | 12,817,656 | 52,116,589 |
| សំវិធានធន (ឆ) | 12,391 | 14,031 | 26,422 | 107,432 |
| ទឹកប្រាក់ជំពាក់សម្ព័ន្ធញាតិ (ខ) | 107,480 | (107,480) | - | - |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ (ខ) | 614,592 | (614,592) | - | - |
| បំណុលផ្សេងៗ (ខ,ង,ច) | 19,169,817 | (13,119,234) | 6,050,583 | 24,601,670 |
| ការប៉ះពាល់លើបំណុលសរុប | | **10,950,417** | | |
| ទុនបម្រុង (ឈ) | 1,975,214 | 4,371,830 | 6,347,044 | 29,444,703 |
| ប្រាក់ចំណេញរក្សាទុក (ឈ) | 87,962,475 | (9,796,943) | 78,165,532 | 314,183,430 |
| ការប៉ះពាល់លើមូលធន | | **(5,425,113)** | | |
| ការប៉ះពាល់លើបំណុលនិងមូលធន | | **5,525,304** | | |

## 3. ការប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ត)

### 3.3 ការប៉ះពាល់ហិរញ្ញវត្ថុដោយសារការប្រើ CIFRS លើកដំបូង (ត)

#### (iv) ការប៉ះពាល់លើទ្រព្យសកម្ម បំណុល និងមូលធន នាថ្ងៃទី30 ខែមិថុនា ឆ្នាំ 2019 (ត)

(ក) CIFRS 9 តម្រូវឱ្យមានការទទួលស្គាល់នូវទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវវាស់វែងតាមតម្លៃដករំលស់។ ការទទួលស្គាល់នេះ ធ្វើឱ្យមានការថយចុះនូវទ្រព្យសកម្មផ្សេងៗ និងការខាតបង់ពីការធ្លាក់ចុះតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ។ ចំពោះឥណទានផ្តល់ដល់អតិថិជនដែលត្រូវវាស់វែងតាមតម្លៃដករំលស់ គឺធ្វើឱ្យមានការថយចុះនូវចំណូលការប្រាក់ (កម្រៃ ឥណទានដែលពីមុនទទួលស្គាល់ជាផ្នែកនៃចំណូលការប្រាក់ទាំងស្រុង តាមស្តង់ដា CAS)។ ឥណទានបុគ្គលិកតាមអត្រា ទាបជាងទីផ្សារ គឺធ្វើឱ្យកើនឡើងនូវទ្រព្យសកម្មផ្សេងៗ ចំណូលការប្រាក់ និងចំណាយបុគ្គលិក។

(ខ) ទឹកប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ ត្រូវបង្ហាញដោយរួមបញ្ចូលជាមួយនឹងទ្រព្យសកម្មផ្សេងៗ។ ទឹកប្រាក់ជំពាក់សម្ព័ន្ធញាតិ និងអត្ថប្រយោជន៍ក្រោយឈប់ពីការងារ ត្រូវបង្ហាញដោយរួមបញ្ចូលជាមួយនឹងបំណុលផ្សេងៗ។

(គ) CIFRS 9 តម្រូវឱ្យមានការទទួលស្គាល់នូវទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវវាស់វែងតាម FVOCI។ ការទទួលស្គាល់នេះ ធ្វើឱ្យមានការថយចុះនូវទ្រព្យសកម្មផ្សេងៗ។

(ឃ) ការប្រើស្តង់ដា CIFRS 16 ចំពោះភតិសន្យា ដែលពីមុនបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការតាមស្តង់ដា CAS 17 តម្រូវឱ្យមានការទទួលស្គាល់សិទ្ធិក្នុងការប្រើទ្រព្យសកម្ម និងបំណុលភតិសន្យា។ ការទទួលស្គាល់នេះ ធ្វើឱ្យមានការថយចុះនូវចំណាយផ្សេងៗ និងកើនឡើងនូវចំណាយរំលស់ និងចំណាយការប្រាក់។

(ង) CIFRS 9 តម្រូវឱ្យមានការទទួលស្គាល់នូវបំណុលហិរញ្ញវត្ថុដែលត្រូវវាស់វែងតាមតម្លៃដករំលស់។ ការទទួលស្គាល់នេះ បានធ្វើឱ្យមានការថយចុះនូវទ្រព្យសកម្មផ្សេងៗ បំណុលផ្សេងៗ និងចំណាយការប្រាក់។

(ច) CIFRS 9 តម្រូវឱ្យមានការទទួលស្គាល់នូវនិស្សន្ទដែលវាស់វែងតាម FVTPL ដោយការប្រែប្រួលតម្លៃសមស្រប ត្រូវទទួលស្គាល់ជាចំណេញសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL។ ការទទួលស្គាល់នេះ ធ្វើឲ្យមានការថយចុះនូវបំណុលផ្សេងៗ។

(ឆ) CIFRS 9 តម្រូវឱ្យមានការទទួលស្គាល់នូវការខាតបង់ឥណទានដែលរំពឹងទុកចំពោះកិច្ចសន្យាឥណទាន។ ការទទួលស្គាល់នេះ ធ្វើឱ្យមានការកើនឡើងនូវការខាតបង់ពីការធ្លាក់ចុះតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ។

(ជ) ការប្រើស្តង់ដា CIAS 12 តម្រូវឱ្យមានការទទួលស្គាល់នូវពន្ធពន្យារ និងថយចុះនូវចំណាយពន្ធលើប្រាក់ចំណេញ។

(ឈ) យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ B7-017-344 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមតែរមិន ចំនួនលើសនៃសំវិធានធនដែលបានមកពីការគណនាស្របតាមបទប្បញ្ញត្តិ ប្រៀបធៀបទៅនឹង ការគណនាតាម CIFRS នឹងត្រូវផ្ទេរពីគណនីប្រាក់ចំណេញរក្សាទុក ទៅក្នុងគណនីទុនបម្រុងតាមបទប្បញ្ញត្តិ ក្នុងខ្ទង់មូលធនរបស់ភាគទុនិក។ ការតម្រូវនេះ ធ្វើឱ្យកើនឡើងនូវទុនបម្រុង និងថយចុះនូវប្រាក់ចំណេញរក្សាទុក។

(ញ) ការប្រើស្តង់ដា CIAS 21 ធ្វើឱ្យមានការប្រែប្រួលនូវតម្លៃចំណូលកម្រៃជើងសារ ចំណាយកម្រៃជើងសារ និងចំណូលផ្សេងៗ។

# 3. ការប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ត)

## 3.3 ការប៉ះពាល់ហិរញ្ញវត្ថុដោយសារការប្រើ CIFRS លើកដំបូង (ត)

### (v) ការប៉ះពាល់លើរបាយការណ៍លំហូរសាច់ប្រាក់

តាមស្តង់ដា CIFRS 16 ភតិក: ត្រូវបង្ហាញ៖

- ការទូទាត់ភតិសន្យារយៈពេលខ្លី និងការទូទាត់ភតិសន្យារបស់ទ្រព្យសកម្មដែលមានតម្លៃទាប ដែលមិនត្រូវបានបញ្ចូលទៅក្នុងការវាស់វែងបំណុលហិរញ្ញវត្ថុ ជាផ្នែកនៃសកម្មភាពប្រតិបត្តិការ។
- ការបង់ការប្រាក់លើបំណុលភតិសន្យា ជាសកម្មភាពប្រតិបត្តិការ ឬជាសកម្មភាពហិរញ្ញប្បទាន ដែលត្រូវបានអនុញ្ញាតដោយស្តង់ដា CIAS 7 (ក្រុមហ៊ុនជ្រើសយកការបង្ហាញដោយបញ្ចូលការបង់ការប្រាក់ជាផ្នែកនៃសកម្មភាពប្រតិបត្តិការ។
- ការបង់ប្រាក់ដើមលើបំណុលភតិសន្យា ជាផ្នែកនៃសកម្មភាពហិរញ្ញប្បទាន។

តាមស្តង់ដា CAS 17 ការទូទាត់ទាំងអស់របស់ភតិសន្យាប្រតិបត្តិការ ត្រូវបង្ហាញក្នុងផ្នែកលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ។ ដូច្នេះ សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ មានការថយចុះចំនួន 1,735,890 ដុល្លារអាមេរិក (ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 ចំនួន 1,466,653 ដុល្លារអាមេរិក) ហើយសាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន មានការថយចុះតាមចំនួនដូចគ្នា។

ការប្រើ CIFRS ពុំមានការប៉ះពាល់ដល់លំហូរសាច់ប្រាក់សុទ្ធនោះទេ។

# 4. គោលនយោបាយគណនេយ្យសំខាន់ៗ

## 4.1 ការប្រាក់

### អត្រាការប្រាក់ប្រសិទ្ធភាព

ចំណូលការប្រាក់ និងចំណាយការប្រាក់ ត្រូវទទួលស្គាល់នៅក្នុងចំណេញ-ខាត ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។ អត្រាការប្រាក់ប្រសិទ្ធភាព គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុនោះ ឱ្យមកស្មើនឹង៖

- តម្លៃដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- តម្លៃដករំលស់របស់បំណុលហិរញ្ញវត្ថុ

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រុមហ៊ុនធ្វើការប៉ាន់ស្មានលើលំហូរសាច់ប្រាក់នាពេលអនាគត ដោយពិចារណាលើលក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទានដែលរំពឹងទុកនោះទេ (ECL)។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវកម្រៃទាំងអស់ដែលបានបង់ ឬត្រូវទទួល រវាងភាគីនៃកិច្ចសន្យា ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព និងថ្លៃដើមប្រតិបត្តិការ។ ថ្លៃដើមប្រតិបត្តិការ រួមមានការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.1 ការប្រាក់ (ត)

**តម្លៃដករំលស់ និងតម្លៃដុល**

តម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់លើកដំបូង ដកការបង់សងប្រាក់ដើម បូកឬដករំលស់បង្គរ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់លើកដំបូង និងចំនួននៅពេលដល់កាលកំណត់ និងត្រូវកែតម្រូវចំពោះសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ។

តម្លៃដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលកែតម្រូវសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក។

**ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់**

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ជាលើកដំបូង។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានប្រើផ្អែកលើតម្លៃដុលរបស់ទ្រព្យសកម្ម ឬតម្លៃដករំលស់របស់បំណុល។ អត្រាការប្រាក់ប្រសិទ្ធភាព ត្រូវធ្វើការកែប្រែឡើងវិញ ដោយធ្វើការប៉ាន់ស្មានឡើងវិញនូវលំហូរសាច់ប្រាក់របស់ឧបករណ៍ដែលមានអត្រាការប្រាក់ប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររបស់អត្រាការប្រាក់ទីផ្សារ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានចាត់ទុកថាមានការធ្លាក់ចុះតម្លៃ បន្ទាប់ពីបានទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ផ្អែកលើតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានការធ្លាក់ចុះតម្លៃ នោះការគណនាការប្រាក់ ត្រូវផ្អែកលើមូលដ្ឋានតម្លៃដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានចាត់ទុកថាមានការធ្លាក់ចុះតម្លៃ ចាប់តាំងពីទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលត្រូវបានកែតម្រូវនូវហានិភ័យ ផ្អែកលើតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ការគណនាការប្រាក់នេះ មិនត្រូវប្តូរទៅផ្អែកលើមូលដ្ឋានតម្លៃដុលវិញនោះទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ។

**ការបង្ហាញ**

ចំណូលការប្រាក់គណនាតាមអត្រាការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងចំណេញ-ខាត រួមបញ្ចូលការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់។

ចំណាយការប្រាក់ដែលត្រូវបានបង្ហាញនៅក្នុងចំណេញ-ខាត រួមបញ្ចូលការប្រាក់លើបំណុលហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.2 កម្រៃជើងសារ

ចំណូល និងចំណាយកម្រៃជើងសារ រួមមានកម្រៃទាំងឡាយណាដែលមិនមែនជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (សូមមើលកំណត់សម្គាល់លេខ 4.1)។

ចំណូលកម្រៃជើងសារផ្សេងៗទៀត រួមមានកម្រៃណែនាំ កម្រៃផ្ទេរប្រាក់ កម្រៃសេវាលើគណនីបញ្ញើ កម្រៃសេវាលើឥណទាន និងកម្រៃផ្សេងៗទៀត ត្រូវទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម។

ចំណាយកម្រៃជើងសារផ្សេងៗទៀត ភាគច្រើនពាក់ព័ន្ធនឹងកម្រៃសេវា និងត្រូវទទួលស្គាល់ជាចំណាយនៅពេលបានទទួលសេវាកម្ម។

### 4.3 ចំណេញ/ខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL

ចំណេញ/ខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL ពាក់ព័ន្ធនឹងនិស្សន្ទមិនមែនសម្រាប់ការជួញដូរ និងត្រូវបានរក្សាទុកសម្រាប់ទប់ស្កាត់ហានិភ័យ ហើយដែលពុំមានគុណវុឌ្ឍិសម្រាប់ទំនាក់ទំនងទប់ស្កាត់ហានិភ័យ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុវាស់វែងតាម FVTPL និងទ្រព្យសកម្មមិនសម្រាប់ការជួញដូរ ដែលវាស់វែងតាម FVTPL។ ធាតុទាំងនេះរួមមានការផ្លាស់ប្តូរតម្លៃសមស្រប អត្រាការប្រាក់ និងលម្អៀងពីការប្តូររូបិយប័ណ្ណ។

### 4.4 អត្ថប្រយោជន៍និយោជិត

**អត្ថប្រយោជន៍ក្រោយឈប់ពីការងារ**

ក្រុមហ៊ុនផ្តល់អត្ថប្រយោជន៍ក្រោយឈប់ពីការងារដល់និយោជិតរបស់ខ្លួន ដែលបានបញ្ចប់រយៈពេលសាកល្បង ដែលជាគំរោងបង់វិភាគទានកំណត់។ ក្រុមហ៊ុនផ្តល់មូលនិធិទៅឱ្យនិយោជិតនីមួយៗជារៀងរាល់ខែ ដោយផ្អែកលើភាគរយនៃប្រាក់បៀវត្សរ៍ប្រចាំខែ ទៅតាមចំនួនឆ្នាំធ្វើការដូចខាងក្រោម៖

| ចំនួនឆ្នាំធ្វើការ | ភាគរយប្រចាំខែ |
|---|---|
| រហូតដល់ 5 ឆ្នាំ | 6% |
| លើសពី 5 ឆ្នាំទៅ 10 ឆ្នាំ | 8% |
| លើសពី 10 ឆ្នាំ | 10% |

មូលនិធិក្រោយឈប់ពីការងារ ត្រូវបានរក្សាទុកក្នុងគណនីសន្សំក្រោមឈ្មោះរបស់និយោជិតម្នាក់ៗ ជាមួយនឹងក្រុមហ៊ុន ហើយនឹងត្រូវទូទាត់ជូននិយោជិតនៅពេលដែលនិយោជិតលាឈប់ពីការងារ ស្លាប់ ឬពេលចូលនិវត្តន៍។ នៅពេលលាឈប់ពីការងារ ឬចូលនិវត្តន៍ និយោជិតដែលបានធ្វើការឱ្យក្រុមហ៊ុន ចាប់ពីបីឆ្នាំឡើងទៅ ត្រូវបានផ្តល់ឱ្យនូវមូលនិធិក្រោយឈប់ពីការងារដែលបានបង្គរ រួមទាំងការប្រាក់ទទួលបានក្នុងគណនីសន្សំរបស់ខ្លួន។

កាតព្វកិច្ចក្នុងការបង់ក្នុងគម្រោងវិភាគទាននេះ ត្រូវកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មដែលពាក់ព័ន្ធត្រូវបានផ្តល់ឱ្យ និងត្រូវទទួលស្គាល់ជាចំណាយនិយោជិតនៅក្នុងចំណេញ-ខាត។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.4 អត្ថប្រយោជន៍និយោជិត (ត)

**អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី**

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ឱ្យ។ បំណុលត្រូវទទួលស្គាល់តាមចំនួនដែលរំពឹងថាត្រូវបង់ ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬដោយប្រយោល ដើម្បីទូទាត់នូវបំណុលនោះ ដោយសារតែសេវាកម្មផ្តល់ដោយនិយោជិតពីអតីតកាល ហើយកាតព្វកិច្ចនោះត្រូវបានប៉ាន់ស្មានដែលអាចជឿជាក់បាន។

### 4.5 ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត លើកលែងតែពន្ធនេះទាក់ទងទៅនឹងធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬចំណូលលម្អិតផ្សេងៗ។

ក្រុមហ៊ុនបានកំណត់ថា ការប្រាក់និងប្រាក់ពិន័យដែលទាក់ទងនឹងពន្ធលើប្រាក់ចំណេញ រួមទាំងពន្ធដែលមិនទាន់ដឹងច្បាស់លាស់ គឺមិនមែនជាពន្ធលើប្រាក់ចំណេញទេ ដូច្នេះវាត្រូវទទួលស្គាល់តាមស្តង់ដា CIAS 37 ស្តីពីសំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ និងត្រូវទទួលស្គាល់ជាចំណាយនៅក្នុងចំណាយផ្សេងៗ។

**ពន្ធប្រចាំឆ្នាំ**

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តមួយភាគធំនៅកាលបរិច្ឆេទតារាងតុល្យការ និងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។

**ពន្ធពន្យារ**

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ចំពោះឥណទានពន្ធដែលមិនទាន់បានប្រើ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ននៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធនៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារជាទ្រព្យសកម្ម ឆ្លុះបញ្ចាំងនូវពន្ធដែលក្រុមហ៊ុនរំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុល អាចកាត់កងបានតែក្នុងករណី វាបានបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.6 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

**ការទទួលស្គាល់ និងការវាស់វែងជាលើកដំបូង**

ក្រុមហ៊ុនបានទទួលស្គាល់ជាលើកដំបូងនូវសមតុល្យនៅធនាគារជាតិនៃកម្ពុជា សមតុល្យនៅធនាគារនានា ឥណទានផ្តល់ដល់អតិថិជន ប្រាក់បញ្ញើរបស់អតិថិជន មូលបត្របំណុល ប្រាក់កម្ចី អនុបំណុល និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ នៅកាលបរិច្ឆេទដែលកើតឡើង។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប រួមបញ្ចូលថ្លៃដើមប្រតិបត្តិការ ដែលកំណត់ថាជាប់ពាក់ព័ន្ធនឹងការទិញ ឬការចេញផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

**ការចាត់ថ្នាក់ និងការវាស់វែងជាបន្តបន្ទាប់**

ទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុមួយ ត្រូវបានវាស់វែងតាមតម្លៃដករំលស់ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុនោះ បំពេញលក្ខខណ្ឌពីរដូចខាងក្រោម៖

- ទ្រព្យសកម្មដែលមាននៅក្នុងម៉ូឌែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកសម្រាប់ការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (SPPI) តាមចំនួនប្រាក់ដើមដែលនៅជំពាក់តែប៉ុណ្ណោះ។

ទោះជាយ៉ាងណាក៏ដោយ នៅពេលទទួលស្គាល់លើកដំបូងនូវការវិនិយោគក្នុងឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់ដែលមិនមែនរក្សាទុកសម្រាប់ការជួញដូរ ក្រុមហ៊ុនបានអាចជ្រើសរើសយកការបង្ហាញជាបន្តបន្ទាប់នូវការប្រែប្រួលតម្លៃសមស្របរបស់វានៅក្នុងចំណូលលម្អិតផ្សេងៗ។

*ការវាយតម្លៃម៉ូឌែលអាជីវកម្ម៖* ក្រុមហ៊ុនវាយតម្លៃគោលបំណងម៉ូឌែលអាជីវកម្មសម្រាប់គ្រប់គ្រងទ្រព្យសកម្មជាបណ្តុំ ព្រោះវាបានឆ្លុះបញ្ចាំងយ៉ាងល្អបំផុតនូវវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មានដល់គណៈគ្រប់គ្រង។ ព័ត៌មានដែលត្រូវយកមកពិចារណារួមមាន៖

- គោលនយោបាយ និងគោលបំណងរបស់បណ្តុំទ្រព្យសកម្ម និងការអនុវត្តនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ផ្តោតទៅលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា ការរក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់ណាមួយ ការផ្គូរផ្គងចិរវេលារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនឹងចិរវេលារបស់បំណុលដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬក៏ការទទួលយកលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម។
- វិធីក្នុងការវាយតម្លៃ និងរាយការណ៍បណ្តុំទ្រព្យសកម្ម ជូនគណៈគ្រប់គ្រងក្រុមហ៊ុន។
- ហានិភ័យដែលប៉ះពាល់ដល់ម៉ូឌែលអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុនៅក្នុងម៉ូឌែលអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់ទប់ស្កាត់ហានិភ័យទាំងនោះ។
- វិធីសាស្ត្រតបស្នងដល់អ្នកគ្រប់គ្រងអាជីវកម្ម (ឧទាហរណ៍ ថាតើការតបស្នងដោយផ្អែកលើតម្លៃសមស្របរបស់ទ្រព្យសកម្មដែលបានគ្រប់គ្រង ឬក៏ផ្អែកលើលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលប្រមូលបាន)។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.6 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

**ការចាត់ថ្នាក់ និងការវាស់វែងជាបន្តបន្ទាប់** (ត)

_ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺសម្រាប់ទូទាត់តែប្រាក់ដើមនិងការប្រាក់៖_ ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" មានន័យថា ជាតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលទទួលស្គាល់ជាលើកដំបូង។ "ការប្រាក់" គឺជាការតបសងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ សម្រាប់រយៈពេលមួយ សម្រាប់ហានិភ័យឥណទានដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេល ជាក់លាក់មួយ និងសម្រាប់ការចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសន្ទនីយភាពនិងចំណាយរដ្ឋបាល) រួមទាំងប្រាក់ចំណេញ។ ដើម្បីវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ ក្រុមហ៊ុនត្រូវពិចារណាលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ រួមមានការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខខណ្ឌកិច្ចសន្យា ដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលអាចធ្វើឱ្យខុសពីលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់។

_បំណុលហិរញ្ញវត្ថុ_

ក្រុមហ៊ុនចាត់ថ្នាក់បំណុលហិរញ្ញវត្ថុដោយវាស់វែងតាមតម្លៃដករំលស់ លើកលែងតែនិស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យដែលត្រូវបានវាស់វែងតាម FVTPL។

**ការកែប្រែ និងការឈប់ទទួលស្គាល់**

_ទ្រព្យសកម្មហិរញ្ញវត្ថុ_

ក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិតាមកិច្ចសន្យាលើលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុនោះផុតកំណត់។ នៅពេលឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងការតបសងដែលបានទទួល ត្រូវទទួលស្គាល់នៅក្នុងចំណេញ-ខាត។

ប្រសិនបើលក្ខខណ្ឌរបស់ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ ក្រុមហ៊ុនត្រូវវាយតម្លៃថាតើលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មដែលត្រូវបានកែប្រែនេះ មានភាពខុសគ្នាខ្លាំងដែរឬទេ។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាដើម្បីទទួលបានលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដំបូង ត្រូវចាត់ទុកថាផុតកំណត់។ ក្នុងករណីនេះ ត្រូវបញ្ឈប់ការទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុដំបូងនេះ ហើយត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុថ្មីតាមតម្លៃសមស្រប បូកនឹងថ្លៃដើមប្រតិបត្តិការ។ កម្រៃផ្សេងៗដែលបានទទួលពីការកែប្រែនេះ ត្រូវគិតដូចខាងក្រោម៖

- កម្រៃដែលត្រូវយកមកកំណត់តម្លៃសមស្របរបស់ទ្រព្យសកម្មថ្មី ហើយកម្រៃដែលបានមកដោយសារការសងត្រឡប់នូវថ្លៃដើមប្រតិបត្តិការ ត្រូវបញ្ចូលទៅក្នុងការវាស់វែងជាលើកដំបូងរបស់ទ្រព្យសកម្មនោះ។
- កម្រៃផ្សេងៗទៀត ត្រូវបញ្ចូលទៅក្នុងចំណេញ-ខាត ដោយដាក់ជាចំណែកនៃការចំណេញ ឬខាតពីការកែប្រែ។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.6 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

**ការកែប្រែ និងការមិនទទួលស្គាល់** (ត)

ប្រសិនបើការប្រែទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់មិនមានគុណវុឌ្ឍិសម្រាប់ការឈប់ទទួលស្គាល់ទេ នោះក្រុមហ៊ុនត្រូវធ្វើការគណនាតម្លៃដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុនោះឡើងវិញ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពពីដំបូងរបស់ទ្រព្យសកម្មនោះ និងត្រូវទទួលស្គាល់ជាចំណេញឬខាតពីការកែប្រែ នៅក្នុងចំណេញ-ខាត។ រាល់ចំណាយ និងកម្រៃផ្សេងៗដែលបានកើតឡើង ត្រូវកែតម្រូវជាមួយតម្លៃដុល និងត្រូវដករំលស់តាមរយៈពេលនៅសល់របស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ។

ប្រសិនបើការកែប្រែនេះ ធ្វើឡើងដោយសារតែបញ្ហាស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី នោះចំណេញ ឬខាត ត្រូវបង្ហាញរួមជាមួយនឹងការខាតបង់លើការធ្លាក់ចុះតម្លៃ។ ករណីផ្សេងពីនេះ ត្រូវបង្ហាញជាចំណូលការប្រាក់ ដែលគណនាតាមវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

<u>បំណុលហិរញ្ញវត្ថុ</u>

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចបានចែងក្នុងកិច្ចសន្យាត្រូវបានលុបចោល ឬត្រូវបានបោះបង់ចោល ឬផុតកំណត់។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌត្រូវបានកែប្រែ ហើយលំហូរសាច់ប្រាក់របស់បំណុលដែលបានកែប្រែមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ ត្រូវទទួលស្គាល់បំណុលហិរញ្ញវត្ថុថ្មីតាមតម្លៃសមស្រប ដោយផ្អែកលើលក្ខខណ្ឌដែលបានកែប្រែ។ ភាពខុសគ្នារវាងតម្លៃយោងរបស់បំណុលហិរញ្ញវត្ថុដែលឈប់ទទួលស្គាល់ និងទឹកប្រាក់ដែលបានបង់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត។

ប្រសិនបើការប្រែបំណុលហិរញ្ញវត្ថុនេះមិនមានគុណវុឌ្ឍិសម្រាប់ការឈប់ទទួលស្គាល់ទេ នោះតម្លៃដករំលស់របស់បំណុល ត្រូវគណនាឡើងវិញដោយធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធភាពពីដំបូង ហើយចំណេញឬខាតពីការគណនានេះ ត្រូវទទួលស្គាល់នៅក្នុងចំណេញ-ខាត។ ចំពោះបំណុលហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ប្រែប្រួល អត្រាការប្រាក់ប្រសិទ្ធភាពពីដំបូង ដែលត្រូវបានយកមកប្រើដើម្បីធ្វើការគណនា ចំណេញ ឬខាតពីការកែប្រែ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារនៅពេលកែប្រែ។ រាល់ការចំណាយ និងកម្រៃផ្សេងៗដែលបានកើតឡើង ត្រូវទទួលស្គាល់ជាការកែតម្រូវចំពោះតម្លៃយោងរបស់បំណុល និងត្រូវដករំលស់ តាមរយៈពេលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែប្រែ ដោយធ្វើការគណនាឡើងវិញនូវអត្រាការប្រាក់ប្រសិទ្ធភាពនៃឧបករណ៍នោះ។

**ការកាត់កង**

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែក្រុមហ៊ុនមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.6 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

**ការកាត់កង** (ត)

ចំណូល និងចំណាយអាចត្រូវបានបង្ហាញដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធបាន លុះត្រាតែមានការអនុញ្ញាតពី CIFRS ឬអាចធ្វើទៅបាន ចំពោះចំណេញ ឬខាត ដែលកើតចេញពីក្រុមប្រតិបត្តិការដែលមានលក្ខណៈស្រដៀងគ្នា។

**ការវាស់វែងតម្លៃសមស្រប**

តម្លៃសមស្រប គឺជាថ្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬថ្លៃដែលបានសងចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអទិភាពបំផុត ដែលក្រុមហ៊ុនអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យដែលមិនពាក់ព័ន្ធនឹងលទ្ធផល។

ក្រុមហ៊ុនវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ។ ទីផ្សារមួយចាត់ទុកថាជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។ ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះក្រុមហ៊ុនត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចបង្កើននូវការប្រើប្រាស់ធាតុចូលដែលអាចអង្កេតបាន និងកាត់បន្ថយនូវការប្រើប្រាស់ធាតុចូលដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសយកមកប្រើប្រាស់ ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់ថ្លៃ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូងជាទូទៅគឺជាថ្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបសងបានផ្តល់ឱ្យ ឬបានទទួល។ ប្រសិនបើក្រុមហ៊ុនកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីថ្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះធាតុចូលដែលមិនអាចអង្កេតបានពាក់ព័ន្ធនឹងការវាស់វែង ត្រូវបានសន្មត់ថាមិនធំដុំ ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងថ្លៃប្រតិបត្តិការ។ ជាបន្តបន្ទាប់មកទៀត ភាពខុសគ្នានោះ គឺត្រូវទទួលស្គាល់នៅក្នុងចំណេញ-ខាត ផ្អែកលើមូលដ្ឋានអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឱ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលចប់ប្រតិបត្តិការនោះទេ។

**ការធ្លាក់ចុះតម្លៃ**

សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុក ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃដករំលស់៖ ត្រូវបង្ហាញជាការដកចេញពីតម្លៃដុលរបស់ទ្រព្យសកម្មនោះ។
- កិច្ចសន្យាឥណទាន៖ ជាទូទៅ ត្រូវបង្ហាញជាសំវិធានធន

ចំពោះគោលនយោបាយលម្អិតទាក់ទងនឹងការធ្លាក់ចុះតម្លៃ សូមមើលកំណត់សម្គាល់លេខ 36.1.4។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.6 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

**ការលុបចេញពីបញ្ជី**

ឥណទានត្រូវបានលុបចេញពីបញ្ជីទាំងស្រុង នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបាន មកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង។ ករណីនេះមានជាទូទៅ នៅពេលក្រុមហ៊ុនកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួន ដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្មនីមួយៗ។

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុងខ្ទង់ "ការខាតបង់សុទ្ធពីការធ្លាក់ចុះតម្លៃឧបករណ៍ហិរញ្ញវត្ថុ" នៅក្នុងចំណេញ-ខាត។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជី នៅតែតម្រូវឱ្យមានសកម្មភាពទាមទារសងមកវិញ ដើម្បីអនុលោមតាមនីតិវិធីរបស់ក្រុមហ៊ុនក្នុងការប្រមូលទឹកប្រាក់នៅជំពាក់។

### 4.7 ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យដែលមិនមានការកំហិតនៅធនាគារជាតិនៃកម្ពុជា និងការវិនិយោគរយៈពេលខ្លីដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល3ខែឬតិចជាង និងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ហើយដែលក្រុមហ៊ុនប្រើដើម្បីគ្រប់គ្រងកាតព្វកិច្ចសន្យារយៈពេលខ្លី។

សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបង្ហាញតាមតម្លៃដករំលស់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### 4.8 និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ

និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ រួមមានទ្រព្យសកម្ម និងបំណុលនិស្សន្ទទាំងអស់ ដែលមិនត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម ឬបំណុលសម្រាប់ការជួញដូរ និងមិនមានគុណវុឌ្ឍិសម្រាប់គណនេយ្យទប់ស្កាត់ហានិភ័យ។

និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ ត្រូវបានវាស់វែងតាមតម្លៃសមស្រប នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេលទទួលស្គាល់ជាលើកដំបូង។ រាល់ការប្រែប្រួលនូវតម្លៃសមស្របនេះ ត្រូវទទួលស្គាល់នៅក្នុងចំណេញ-ខាតជាធាតុមួយនៃ ចំណេញ/ខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL។

### 4.9 ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជនដែលបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺជាឥណទានដែលវាស់វែងតាមតម្លៃដករំលស់។ ឥណទានទាំងនោះ ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកនឹងថ្លៃដើមប្រតិបត្តិការផ្ទាល់បន្ថែម និងត្រូវបានវាស់វែងជាបន្តបន្ទាប់តាមតម្លៃដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.10 វិនិយោគលើមូលបត្រ

វិនិយោគលើមូលបត្រ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺជាការវិនិយោគក្នុងឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់ ដែលត្រូវបានវាស់វែងតាម FVOCI។ ការផ្លាស់ប្តូរតម្លៃសមស្របរបស់ការវិនិយោគមូលបត្រកម្មសិទ្ធិនេះ ត្រូវបង្ហាញនៅក្នុងចំណូលលម្អិតផ្សេងៗ។

ចំណេញ ឬខាតពីឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់នេះ គឺនឹងមិនត្រូវបានធ្វើការចាត់ថ្នាក់ឡើងវិញនៅក្នុងចំណេញ-ខាត និងពុំមានការទទួលស្គាល់នូវការធ្លាក់ចុះតម្លៃ នៅក្នុងចំណេញ-ខាតនោះឡើយ។ ភាគលាភត្រូវបានទទួលស្គាល់នៅក្នុង ចំណេញ-ខាត លុះត្រាណាវាបង្ហាញយ៉ាងច្បាស់ពីភាពដែលអាចប្រមូលមកវិញបាន នូវផ្នែកនៃថ្លៃដើមវិនិយោគ បើមិនដូច្នេះទេ ត្រូវបង្ហាញនៅក្នុងចំណូលលម្អិតផ្សេងៗ។ ចំណេញ ឬខាតបង្គរ ដែលបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗ ត្រូវផ្ទេរទៅប្រាក់ចំណេញរក្សាទុកនៅពេលលក់ចេញនូវការវិនិយោគនោះ។

### 4.11 ទ្រព្យសម្បត្តិ និងបរិក្ខារ

**ការទទួលស្គាល់ និងការវាស់វែង**

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់ពីការធ្លាក់ចុះតម្លៃបង្គរ ប្រសិនបើមាន។

នៅពេលដែលធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុទាំងនោះត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នារបស់សម្បត្តិ និងបរិក្ខារ។

**ចំណាយជាបន្តបន្ទាប់**

ចំណាយជាបន្តបន្ទាប់ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោង ប្រសិនបើមានភាពប្រាកដថា វាផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដាដើម។ ការជួសជុល និងថែទាំជាប្រចាំ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងគ្រាដែលបានកើតឡើង។

**រំលស់**

រំលស់ត្រូវបានគណនាដើម្បីលុបចេញនូវថ្លៃដើមរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ ដកតម្លៃនៅសល់ ដោយប្រើវិធីសាស្រ្តរំលស់ថេរ ផ្អែកលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងចំណេញ-ខាត។

អាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ មានដូចខាងក្រោម៖

| | អាយុកាលប្រើប្រាស់ |
|---|---|
| ការកែលម្អអគារជួល | 3 ឆ្នាំ |
| យានយន្ត | 3 - 5 ឆ្នាំ |
| កុំព្យូទ័រ | 3 ឆ្នាំ |
| បរិក្ខារ | 3 - 5 ឆ្នាំ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | 3 ឆ្នាំ |

## ហត្ថាកសិករ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

### 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.11 ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

ការងារកំពុងដំណើរការ មិនត្រូវបានគិតរំលស់ទេនៅក្នុងអំឡុងពេលសាងសង់ រហូតដល់ពេលដែលទ្រព្យសម្បត្តិ ដែលពាក់ព័ន្ធបានបញ្ចប់ និងដាក់ឱ្យប្រើប្រាស់។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃនៅសល់ ត្រូវពិនិត្យឡើងវិញ និងកែតម្រូវឱ្យបានសមស្របនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍។

ទ្រព្យសម្បត្តិ និងបរិក្ខារ ដែលបានដករំលស់អស់ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបបំបាត់ចោល។

### 4.12 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានអាជ្ញាប័ណ្ណ និងសូហ្វវែរ និងត្រូវបានបង្ហាញតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់ពីការធ្លាក់ចុះតម្លៃបង្គរប្រសិនបើមាន។

ចំណាយជាបន្តបន្ទាប់លើអាជ្ញាប័ណ្ណ និងសូហ្វវែរ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោង ប្រសិនបើប្រាកដថាវាផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដាដើម។ រាល់ការចំណាយជាបន្តបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងគ្រាដែលបានកើតឡើង។

អាជ្ញាប័ណ្ណ និងសូហ្វវែរ ត្រូវបានធ្វើរំលស់ទៅក្នុងចំណេញ-ខាត ដោយផ្អែកលើមូលដ្ឋានថេរ គិតចាប់ពីពេលដែលអាចប្រើប្រាស់បាន។ អាយុកាលប្រើប្រាស់របស់ទ្រព្យអរូបីសម្រាប់គ្រាបច្ចុប្បន្ន និងគ្រាប្រៀបធៀបគឺ 5ឆ្នាំ។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃនៅសល់ ត្រូវពិនិត្យឡើងវិញ និងកែតម្រូវឱ្យបានសមស្របនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍។

### 4.13 ភតិសន្យា

ក្រុមហ៊ុនត្រូវធ្វើការវាយតម្លៃ ថាតើកិច្ចសន្យាមានភតិសន្យាដែរឬទេ នៅពេលចាប់ផ្តើមកិច្ចសន្យា។

ក្រុមហ៊ុនទទួលស្គាល់សិទ្ធិក្នុងការប្រើទ្រព្យសកម្ម និងបំណុលភតិសន្យា ចំពោះគ្រប់កិច្ចសន្យាភតិសន្យាទាំងអស់ ដែលក្រុមហ៊ុនគឺជាភតិក: លើកលែងតែភតិសន្យារបស់ទ្រព្យសកម្មដែលមានតម្លៃទាប។ សម្រាប់ភតិសន្យារបស់ទ្រព្យសកម្មដែលមានតម្លៃទាប ក្រុមហ៊ុនទទួលស្គាល់ការទូទាត់ភតិសន្យាជាចំណាយប្រតិបត្តិការ តាមមូលដ្ឋានថេរដោយផ្អែកទៅតាមរយៈពេលភតិសន្យា។

#### បំណុលភតិសន្យា

បំណុលភតិសន្យា ត្រូវបានវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនទាន់បានបង់នៅពេលចាប់ផ្តើមភតិសន្យា និងត្រូវបានធ្វើអប្បហារដោយប្រើអត្រាកម្ចីបន្ថែម ដែលជាអត្រាការប្រាក់ក្រុមហ៊ុននឹងត្រូវបង់ដើម្បីខ្ចីប្រាក់ក្នុងការទទួលបានទ្រព្យសកម្មមួយ ដែលតម្លៃសិទ្ធិក្នុងការប្រើទ្រព្យសកម្មនៅក្នុងស្ថានភាពសេដ្ឋកិច្ចស្រដៀងគ្នា ដោយផ្អែកលើលក្ខខណ្ឌស្រដៀងគ្នា និងទ្រព្យដាក់ធានាស្រដៀងគ្នា។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.13 ភតិសន្យា (ត)

**បំណុលភតិសន្យា** (ត)

ការទូទាត់ភតិសន្យាដែលត្រូវបញ្ចូលទៅក្នុងការវាស់វែងបំណុលភតិសន្យា រួមមាន៖

- ការទូទាត់ភតិសន្យាថេរ ដកចេញនូវការតបស្នងភតិសន្យាប្រសិនបើមាន
- ការបង់ប្រាក់ពិន័យលើការបញ្ចប់ភតិសន្យា ប្រសិនបើលក្ខខណ្ឌភតិសន្យា បានឆ្លុះបញ្ចាំងពីការអនុវត្តជម្រើសក្នុងការបញ្ចប់ភតិសន្យា។

បំណុលភតិសន្យា ត្រូវបានបង្ហាញជាធាតុដាច់ដោយឡែកមួយ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

បំណុលភតិសន្យា ត្រូវបានវាស់វែងជាបន្តបន្ទាប់ ដោយការកើនឡើងនូវតម្លៃយោង ដើម្បីឆ្លុះបញ្ចាំងពីការប្រាក់លើបំណុលភតិសន្យា (ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់ប្រសិទ្ធភាព) និងដោយការថយចុះនូវតម្លៃយោង ដើម្បីឆ្លុះបញ្ចាំងពីការបង់សងភតិសន្យា។

ក្រុមហ៊ុនធ្វើការវាស់វែងបំណុលភតិសន្យាឡើងវិញ (និងធ្វើការកែតម្រូវជាមួយនឹងសិទ្ធិក្នុងការប្រើទ្រព្យសកម្មដែលពាក់ព័ន្ធ) នៅពេលដែល៖

- លក្ខខណ្ឌភតិសន្យាមានការផ្លាស់ប្តូរ ដែលក្នុងករណីនេះ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញ ដោយការធ្វើអប្បហារការទូទាត់ភតិសន្យាដែលបានកែប្រែ តាមអត្រាអប្បហារដែលបានកែប្រែ។
- កិច្ចសន្យាភតិសន្យាត្រូវបានកែប្រែ ហើយភតិសន្យាដែលបានកែប្រែនេះ មិនត្រូវបានគិតថាជាភតិសន្យាដាច់ដោយឡែកមួយទៀតនោះទេ ដែលក្នុងករណីនេះ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញ ដោយការធ្វើអប្បហារការទូទាត់ភតិសន្យាដែលបានកែប្រែ តាមអត្រាអប្បហារដែលបានកែប្រែ។

**សិទ្ធិក្នុងការប្រើទ្រព្យសកម្ម**

សិទ្ធិក្នុងការប្រើទ្រព្យសកម្ម រួមមាន ការវាស់វែងដំបូងរបស់បំណុលភតិសន្យាដែលពាក់ព័ន្ធ ការទូទាត់ភតិសន្យាដែលបានធ្វើឡើង នៅពេល ឬមុនពេលថ្ងៃចាប់ផ្តើម និងថ្លៃដើមដំបូងពាក់ព័ន្ធផ្ទាល់ប្រសិនបើមាន។ សិទ្ធិក្នុងការប្រើទ្រព្យសកម្ម ត្រូវបានវាស់វែងជាបន្តបន្ទាប់ តាមរយៈថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ពីការធ្លាក់ចុះតម្លៃបង្គរ។

សិទ្ធិក្នុងការប្រើទ្រព្យសកម្មត្រូវធ្វើរំលស់ដោយផ្អែកលើថិរវេលារបស់ភតិសន្យា ឬអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មដែលពាក់ព័ន្ធ មួយណាលឿនជាង។ រំលស់ត្រូវចាប់ផ្តើម នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។

សិទ្ធិក្នុងការប្រើទ្រព្យសកម្ម ត្រូវបានបង្ហាញជាធាតុដាច់ដោយឡែកមួយ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.14 ការធ្លាក់ចុះតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានការធ្លាក់ចុះតម្លៃ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានវិញរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។

សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើការធ្លាក់ចុះតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មដទៃទៀត (ហៅកាត់ថា "ឯកតាបង្កើតសាច់ប្រាក់")។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ សាច់ប្រាក់ រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ សម្រាប់ទ្រព្យសកម្មទាំងនោះ។

ការខាតបង់លើការធ្លាក់ចុះតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មមួយ ឬឯកតាបង្កើតសាច់ប្រាក់ មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ។

ការខាតបង់លើការធ្លាក់ចុះតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត។

ការខាតបង់លើការធ្លាក់ចុះតម្លៃ ត្រូវកត់ត្រាបញ្ច្រាសមកវិញ ត្រឹមកម្រិតមួយដែលមិនធ្វើឱ្យតម្លៃយោងរបស់ទ្រព្យសកម្មនេះ លើសពីតម្លៃយោងដករំលស់ ដែលត្រូវកំណត់ក្នុងករណីពុំមានការទទួលស្គាល់ការខាតបង់លើការធ្លាក់ចុះតម្លៃ។

### 4.15 ប្រាក់បញ្ញើ មូលបត្របំណុល ប្រាក់កម្ចី និងអនុបំណុល

ប្រាក់បញ្ញើ មូលបត្របំណុល ប្រាក់កម្ចី និងអនុបំណុល ជាប្រភពហិរញ្ញប្បទានរបស់ក្រុមហ៊ុន។

ប្រាក់បញ្ញើ មូលបត្របំណុល ប្រាក់កម្ចី និងអនុបំណុល ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដកថ្លៃដើមប្រតិបត្តិការផ្ទាល់បន្ថែម និងត្រូវបានវាស់វែងជាបន្តបន្ទាប់តាមតម្លៃដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

អនុបំណុល គឺជាបំណុលរយៈពេលវែង ដែលការបង់សងប្រាក់ដើម ត្រូវធ្វើឡើងបន្ទាប់ពីការបង់សងបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន។ អនុបំណុលដែលបានអនុម័តដោយធនាគារជាតិនៃកម្ពុជា ត្រូវបានចាត់ទៅក្នុងគណនីថ្នាក់ទីII ក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ក្រុមហ៊ុន ស្របតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.16 សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោល នាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈសារវន្ត សំវិធានធនត្រូវបានកំណត់ដោយការធ្វើអប្បហារលំហូរទឹកប្រាក់ដែលរំពឹងថានឹងត្រូវបង់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។

### 4.17 ទុនបម្រុង

**ទុនបម្រុងស្របច្បាប់**

មុនពេលក្រុមហ៊ុនត្រូវបានទិញដោយ Krungsri លក្ខន្តិកៈក្រុមហ៊ុនតម្រូវឱ្យបង្វែរចេញពីប្រាក់ចំណេញរក្សាទុកនូវចំនួនដែលស្មើនឹង 5% នៃប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទមុនចូលក្នុងទុនបម្រុង។ ការបង្វែរនេះនឹងបញ្ឈប់នៅពេលដែលទុនបម្រុងមានចំនួនស្មើនឹង 10% នៃដើមទុនបានចុះបញ្ជីរបស់ក្រុមហ៊ុន។ យោងតាមលក្ខន្តិកៈថ្មីដែលអនុម័តដោយក្រសួងពាណិជ្ជកម្មចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ ពុំមានការបង្វែរចូលទុនបម្រុងទៀតនោះទេបន្ទាប់ពីក្រុមហ៊ុនត្រូវបានកាន់កាប់ទាំងស្រុងដោយ Krungsri។

**សំវិធានធនតាមបទប្បញ្ញត្តិ និងទុនបម្រុងតាមបទប្បញ្ញត្តិ**

នៅថ្ងៃ1 ខែធ្នូ ឆ្នាំ2017 ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសលេខ B7-017-344 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ដើម្បីធានាបានភាពត្រឹមត្រូវនៃការទទួលស្គាល់ ការវាស់វែងការធ្វើសំវិធានធន និងការរាយការណ៍ចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន របស់ស្ថាប័ន។

ហ្វាស៊ីលីធី សំដៅដល់ឥណទាន និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ទាំងនៅក្នុង ឬក្រៅតារាងតុល្យការដែលគ្រឹះស្ថានបានផ្តល់ទៅឱ្យសមភាគី ហើយហ្វាស៊ីលីធីនេះអាចបង្កហានិភ័យឥណទានដល់គ្រឹះស្ថាន។

យោងតាមប្រកាសនេះ ក្រុមហ៊ុនត្រូវធ្វើសំវិធានធនសម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដោយអនុលោមតាមបទប្បញ្ញត្តិ ទន្ទឹមគ្នានឹងការគណនាសំវិធានធនដោយយោងតាមស្តង់ដា CIFRS។ សំវិធានធនដែលគណនាតាម CIFRS ត្រូវបានទទួលស្គាល់និងកត់ត្រា។ ចំនួនលើសនៃសំវិធានធនដែលបានមកពីការគណនាស្របតាមបទប្បញ្ញត្តិប្រៀបធៀបទៅនឹងការគណនាតាម CIFRS នឹងត្រូវផ្ទេរពីគណនីប្រាក់ចំណេញរក្សាទុក ទៅក្នុងគណនីទុនបម្រុងតាមបទប្បញ្ញត្តិ ក្នុងខ្ទង់មូលធនរបស់ភាគទុនិក។

នៅថ្ងៃ16 ខែកុម្ភៈ ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំលេខ B7-018-001 ដើម្បីបញ្ជាក់បន្ថែម លើការអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន។ យោងតាមសារាចរនេះ ក្រុមហ៊ុនត្រូវធ្វើការគណនាសំវិធានធនសម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដោយអនុលោមតាមបទប្បញ្ញត្តិ ដោយហ្វាស៊ីលីធីត្រូវបានចាត់ជា 5ថ្នាក់ ដែលមានអត្រាសំវិធានធន ដូចខាងក្រោម៖

## 4. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### 4.17 ទុនបម្រុង (ត)

**សំវិធានធនតាមបទប្បញ្ញត្តិ និងទុនបម្រុងតាមបទប្បញ្ញត្តិ (ត)**

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| *1. សំវិធានធនទូទៅ* | | |
| ហ្វាស៊ីលីធីរយៈពេលខ្លី (តិចជាងឬស្មើមួយឆ្នាំ) | | |
| ធម្មតា | ពី 0 ទៅ 14 ថ្ងៃ | 1% |
| ហ្វាស៊ីលីធីរយៈពេលវែង (លើសពីមួយឆ្នាំ) | | |
| ធម្មតា | ពី 0 ទៅ 29 ថ្ងៃ | 1% |
| *2. សំវិធានធនជាក់លាក់* | | |
| ហ្វាស៊ីលីធីរយៈពេលខ្លី (តិចជាងឬស្មើមួយឆ្នាំ) | | |
| ឃ្លាំមើល | ពី 15 ទៅ 30 ថ្ងៃ | 3% |
| ក្រោមស្តង់ដា | ពី 31 ទៅ 60 ថ្ងៃ | 20% |
| សង្ស័យ | ពី 61 ទៅ 90 ថ្ងៃ | 50% |
| បាត់បង់ | ពី 91 ថ្ងៃឡើងទៅ | 100% |
| ហ្វាស៊ីលីធីរយៈពេលវែង (លើសពីមួយឆ្នាំ) | | |
| ឃ្លាំមើល | ពី 30 ទៅ 89 ថ្ងៃ | 3% |
| ក្រោមស្តង់ដា | ពី 90 ទៅ 179 ថ្ងៃ | 20% |
| សង្ស័យ | ពី 180 ទៅ 359 ថ្ងៃ | 50% |
| បាត់បង់ | ពី 360 ថ្ងៃឡើងទៅ | 100% |

ចំពោះហ្វាស៊ីលីធីដែលមានការទូទាត់សងប្រចាំត្រីមាស ប្រចាំឆមាសឬយូរជាងនេះ នឹងត្រូវបានចាត់ថ្នាក់ជាក្រោមស្តង់ដា ប្រសិនបើមានការខកខានទូទាត់សងចាប់ពី 5 ថ្ងៃនៃថ្ងៃធ្វើការ។

សំវិធានធនត្រូវបានគណនាជាភាគរយនៃចំនួនសមតុល្យហ្វាស៊ីលីធីដែលនៅសល់ នៅពេលដែលហ្វាស៊ីលីធីនោះត្រូវបានចាត់ថ្នាក់ថាមិនដំណើរការ លើកលែងតែការប្រាក់បង្គរ។

**ទុនបម្រុងផ្សេងៗ**

ចាប់ពីថ្ងៃទី9 ខែធ្នូ ឆ្នាំ2010 ក្រុមហ៊ុនត្រូវបានតម្រូវឱ្យបង្កើតទុនបម្រុងដោយម្ចាស់កម្ចី Instituto de Credito Oficial (ហៅកាត់ថា "ICO") នៃព្រះរាជាណាចក្រអេស្បាញ ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងខ្ចីប្រាក់កម្ចី ស្ថិតនៅក្រោមគម្រោងមីក្រូហិរញ្ញវត្ថុអេស្បាញ (Spanish Microfinance Program)។ ទុនបម្រុងនេះ ត្រូវបានផ្ទេរពីប្រាក់ ចំណេញរក្សាទុកចំនួន 3.5% នៃប្រាក់កម្ចីដែលនៅជំពាក់ (ប្រាក់កម្ចីពី ICO) នៅរៀងរាល់ចុងឆ្នាំរហូតដល់ថ្ងៃ ទី9 ខែមីនា ឆ្នាំ2023។ ទុនបម្រុងផ្សេងទៀត គឺសម្រាប់ការពង្រឹងស្ថាប័ន និង ត្រូវរក្សាទុកនៅក្នុងគណនីបម្រុងផ្សេងៗទៅតាម អាយុកាលរបស់ប្រាក់កម្ចីនេះ ឬបើមិនដូច្នេះទេ ត្រូវមានការយល់ព្រមពី ICO និង Agencia Española de Cooperación Internacional para el Desarrollo (ហៅកាត់ថា "AECID")។ យោងតាមកិច្ចសន្យា "ទុនបម្រុងផ្សេង ៗ" ដែលបានពីប្រាក់កម្ចីនេះ មិនអាចយកទៅធ្វើការបែងចែកបានឡើយក្នុងរយៈពេលកម្ចីនេះ លើកលែងតែមានការអនុញ្ញាតពីម្ចាស់កម្ចី ដោយមានការ ស្នើសុំពីក្រុមហ៊ុនក្នុងការដកទុនបម្រុងនេះ។

## 5. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ និងប្រភពសំខាន់ៗនៃការប៉ាន់ស្មានភាពមិនប្រាកដ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឱ្យអ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត់ ដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួនទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មត់ដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែទៅលើការប៉ាន់ស្មានគណនេយ្យ ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងគ្រាដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែ និងការិយបរិច្ឆេទអនាគតដែលប៉ះពាល់ដោយការកែប្រែនេះ។

### 5.1 ការវិនិច្ឆ័យសំខាន់ៗក្នុងការអនុវត្តគោលការណ៍គណនេយ្យ

ព័ត៌មានអំពីការវិនិច្ឆ័យក្នុងការអនុវត្តគោលនយោបាយគណនេយ្យ ដែលមានការប៉ះពាល់ជាសារវន្ត លើចំនួនដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

**ការវាយតម្លៃម៉ូឌែលអាជីវកម្ម**

ការចាត់ថ្នាក់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ អាស្រ័យលើលទ្ធផលនៃការពិសោធន៍ SPPI និងម៉ូឌែលអាជីវកម្ម (សូមមើលកំណត់សម្គាល់លេខ 4.6)។ ក្រុមហ៊ុនធ្វើការកំណត់ម៉ូឌែលអាជីវកម្មនៅកម្រិតមួយ ដែលអាចឆ្លុះបញ្ចាំងពីវិធីសាស្ត្រក្នុងការគ្រប់គ្រងក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ដើម្បីសម្រេចបាននូវគោលដៅអាជីវកម្មជាក់លាក់មួយ។ ការវាយតម្លៃនេះ រួមមាន ការវិនិច្ឆ័យ ដែលឆ្លុះបញ្ចាំងនូវរាល់ភស្តុតាងពាក់ព័ន្ធទាំងអស់ រួមទាំងវិធីវាយតម្លៃនិងវាស់វែងលទ្ធផលរបស់ទ្រព្យសកម្ម ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលរបស់ទ្រព្យសកម្មនិងវិធីគ្រប់គ្រងហានិភ័យទាំងនេះ និងវិធីសាស្ត្រតបស្នងអ្នកគ្រប់គ្រងទ្រព្យសកម្មនេះ។ ក្រុមហ៊ុនធ្វើការតាមដានរាល់ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃដករំលស់ ដែលត្រូវបានឈប់ទទួលស្គាល់មុនកាលវសាន្តរបស់វា ដើម្បីស្វែងយល់ពីមូលហេតុក្នុងការបោះបង់ចោល និងថាតើមូលហេតុទាំងនោះ ស្របតាមគោលដៅអាជីវកម្មក្នុងការរក្សាទ្រព្យសកម្មដែរ ឬទេ។ ការតាមដាននេះគឺជាផ្នែកនៃការវាយតម្លៃជាបន្តបន្ទាប់របស់ក្រុមហ៊ុន ថាតើម៉ូឌែលអាជីវកម្មក្នុងការរក្សាទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះនៅបន្តសមប្រកបដែរ ឬទេ ហើយប្រសិនបើវាមិនសមប្រកបទេ ថាតើមានការផ្លាស់ប្តូរណាមួយនៅក្នុងម៉ូឌែលអាជីវកម្មដែរឬអត់ ហើយប្រសិនមានត្រូវធ្វើការផ្លាស់ប្តូរចំណាត់ថ្នាក់ទ្រព្យសកម្មទាំងនោះចាប់ពីពេលផ្លាស់ប្តូរម៉ូឌែលអាជីវកម្ម។

**ការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន**

ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ 36.1.14 ការខាតបង់ឥណទានដែលរំពឹងទុក (ECL) ត្រូវវាស់វែងជាសំវិធានធនស្មើនឹង 12ខែ ចំពោះទ្រព្យសកម្មដែលស្ថិតក្នុងចំណាត់ថ្នាក់ទី1 និងសំវិធានធនស្មើនឹងអាយុកាលរបស់ទ្រព្យសកម្ម ចំពោះទ្រព្យសកម្មដែលស្ថិតក្នុងចំណាត់ថ្នាក់ទី2 និងទី3។ ទ្រព្យសកម្មមួយ ត្រូវប្តូរទៅស្ថិតនៅក្នុងចំណាត់ថ្នាក់ទី2 នៅពេលដែលហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះមានការកើនឡើងជាសារវន្ត ចាប់តាំងពីពេលទទួលស្គាល់ជាលើកដំបូង។ ដើម្បីវាយតម្លៃថាតើ ហានិភ័យឥណទានរបស់ទ្រព្យសកម្មមួយ មានការកើនឡើងជាសារវន្តដែរឬទេ ក្រុមហ៊ុនត្រូវពិចារណានូវព័ត៌មានដែលរំពឹងទុកទៅថ្ងៃខាងមុខ ដែលព័ត៌មាននោះមានលក្ខណៈអាចទ្រទ្រង់បាន និងសមហេតុផលទាំងបរិមាណ និងគុណភាព។ សូមមើលកំណត់សម្គាល់លេខ 36 សម្រាប់ការពន្យល់លម្អិត។

## 5. ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ និងប្រភពសំខាន់ៗនៃការប៉ាន់ស្មានភាពមិនប្រាកដ (ត)

### 5.1 ការវិនិច្ឆ័យសំខាន់ៗក្នុងការអនុវត្តគោលការណ៍គណនេយ្យ (ត)

**ការបង្កើតក្រុមទ្រព្យសកម្មដែលមានចរិតលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា**

នៅពេលដែល ការខាតបង់ឥណទានដែលរំពឹងទុក ត្រូវវាស់វែងតាមមូលដ្ឋានជាក្រុម ឧបករណ៍ហិរញ្ញវត្ថុត្រូវបានប្រមូលផ្តុំតាមមូលដ្ឋានចរិតលក្ខណៈហានិភ័យ។ ក្រុមហ៊ុនធ្វើការតាមដានភាពសមស្របនៃចរិតលក្ខណៈហានិភ័យឥណទាន ដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ដើម្បីវាយតម្លៃថាតើហានិភ័យទាំងនោះ នៅតែបន្តលក្ខណៈស្រដៀងគ្នាទៀតដែរឬទេ។ កិច្ចការនេះ ត្រូវធ្វើដើម្បីធានាថា ប្រសិនបើចរិតលក្ខណៈហានិភ័យឥណទានមានការផ្លាស់ប្តូរ គឺត្រូវធ្វើការប្រមូលផ្តុំទ្រព្យសកម្មឱ្យបានសមស្របឡើងវិញ។ ការប្រមូលផ្តុំឡើងវិញនេះ អាចនាំឱ្យមាននូវការបង្កើតក្រុមទ្រព្យសកម្មថ្មី ឬក៏ទ្រព្យសកម្មត្រូវប្តូរទៅក្រុមទ្រព្យសកម្មដែលមានស្រាប់ផ្សេងទៀត ដែលអាចឆ្លុះបញ្ចាំងនូវចរិតលក្ខណៈហានិភ័យឥណទានស្រដៀងគ្នាទៅនឹងក្រុមទ្រព្យសកម្មនោះ។ ការប្រមូលផ្តុំទ្រព្យសកម្មឡើងវិញ និងការប្តូរពីក្រុមទ្រព្យសកម្មមួយទៅក្រុមទ្រព្យសកម្មមួយទៀតគឺជារឿងធម្មតា នៅពេលមានការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន (ឬក៏នៅពេលការកើនឡើងជាសារវន្តនោះ មានភាពបញ្ច្រាសមកវិញ) ដូច្នេះទ្រព្យសកម្ម ត្រូវប្តូរពីទ្រព្យសកម្មដែលត្រូវធ្វើសំវិធានធនស្មើ12ខែ ទៅជាទ្រព្យសកម្មដែលត្រូវធ្វើសំវិធានធនស្មើនឹងអាយុកាលរបស់ទ្រព្យសកម្មនោះ ឬក៏បញ្ច្រាសមកវិញ ប៉ុន្តែវាក៏អាចកើតឡើងផងដែរចំពោះក្រុមទ្រព្យសកម្មដែលនៅតែបន្តវាស់វែងតាមមូលដ្ឋានសំវិធានធនស្មើ 12ខែ ឬសំវិធានធនស្មើនឹងអាយុកាលរបស់ក្រុមទ្រព្យសកម្មនោះ គ្រាន់តែចំនួនសំវិធានធនត្រូវផ្លាស់ប្តូរ ដោយសារហានិភ័យឥណទានរបស់ក្រុមទ្រព្យសកម្មនោះ មានការប្រែប្រួល។

**ម៉ូឌែល និងការសន្មត់ដែលបានប្រើ**

ក្រុមហ៊ុនប្រើម៉ូឌែល និងការសន្មត់ផ្សេងៗ ដើម្បីវាស់វែងតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ព្រមទាំងការប៉ាន់ស្មាននូវ ការខាតបង់ឥណទានដែលរំពឹងទុក។ ត្រូវប្រើការវិនិច្ឆ័យ ដើម្បីកំណត់ម៉ូឌែល ដែលសាកសមបំផុតសម្រាប់ប្រភេទទ្រព្យសកម្មនីមួយៗ និងដើម្បីកំណត់នូវការសន្មត់ដែលត្រូវប្រើក្នុងម៉ូឌែលទាំងនេះ រួមទាំងការសន្មត់ពាក់ព័ន្ធនឹងចលករសំខាន់ៗរបស់ហានិភ័យ។

### 5.2 ប្រភពសំខាន់ៗនៃការប៉ាន់ស្មានភាពមិនប្រាកដ

ព័ត៌មានអំពីការសន្មត់ និងការប៉ាន់ស្មានភាពមិនប្រាកដ ដែលមានការប៉ះពាល់ជាសារវន្ត លើចំនួនដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

**ការបង្កើតនូវចំនួននិងទម្ងន់របស់សេណារីយ៉ូនៃការរំពឹងទុកទៅថ្ងៃខាងមុខ សម្រាប់ប្រភេទផលិតផលនីមួយៗ និងការកំណត់នូវព័ត៌មានដែលរំពឹងទុកទៅថ្ងៃខាងមុខពាក់ព័ន្ធនឹងសេណារីយ៉ូនីមួយៗ**

នៅពេលវាស់វែង ការខាតបង់ឥណទានដែលរំពឹងទុក ក្រុមហ៊ុនប្រើប្រាស់នូវព័ត៌មានដែលរំពឹងទុកទៅថ្ងៃខាងមុខ ដែលមានលក្ខណៈអាចទ្រទ្រង់បាន និងសមហេតុផល ដោយផ្អែកលើការសន្មត់ចំពោះការផ្លាស់ប្តូរនាពេលអនាគតនូវចលករសេដ្ឋកិច្ចផ្សេងៗគ្នា និងរបៀបដែលចលករទាំងនេះ មានការប៉ះពាល់គ្នាទៅវិញទៅមក។

## 5. ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ និងប្រភពសំខាន់ៗនៃការប៉ាន់ស្មានភាពមិនប្រាកដ (ត)

### 5.2 ការសន្មត់ក្នុងការប៉ាន់ស្មានភាពមិនប្រាកដ (ត)

**ភាពដែលអាចខកខានក្នុងការសង**

ភាពដែលអាចខកខានក្នុងការសង គឺជាធាតុចូលដ៏សំខាន់ក្នុងការវាស់វែង ការខាតបង់ឥណទានដែលរំពឹងទុក។ ភាពដែលអាចខកខានក្នុងការសង គឺជាការប៉ាន់ស្មាននូវ ភាពប្រហាក់ប្រហែលក្នុងការខកខានសងក្នុងរយៈពេលណាមួយ ដែលការគណនារបស់វា ត្រូវការនូវទិន្នន័យពីមុនៗ ការសន្មត់ និងការរំពឹងទុកនូវលក្ខខណ្ឌនាពេលអនាគត។

**ការខាតបង់ដោយសារខកខានក្នុងការសង**

ការខាតបង់ដោយសារខកខានក្នុងការសង គឺជាការប៉ាន់ស្មាននូវការខាតបង់កើតចេញមកពីការខកខានក្នុងការ បង់សង។ វាផ្អែកទៅលើភាពខុសគ្នារវាង លំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលដល់កាលកំណត់ត្រូវបង់សង និងលំហូរសាច់ប្រាក់ដែលម្ចាស់កម្ចីរំពឹងថានឹងទទួលបាន ដោយគិតទាំងលំហូរសាច់ប្រាក់ពីទ្រព្យដាក់ធានា និងការធ្វើឱ្យប្រសើរឡើងនូវឥណទានទាំងមូល។

**សំវិធានធនសម្រាប់ហ្វាស៊ីលីធីដែលមានការធ្លាក់ចុះតម្លៃ**

ក្រុមហ៊ុនត្រូវអនុវត្តតាមចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ស្របតាមប្រកាសលេខ B7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 របស់ធនាគារជាតិនៃកម្ពុជា និងសារាចរលេខ B7-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018។ ធនាគារជាតិនៃកម្ពុជា តម្រូវឱ្យស្ថាប័នមីក្រូហិរញ្ញវត្ថុត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីរបស់ខ្លួនជាប្រាំប្រភេទ និងចាំបាច់ត្រូវធ្វើសំវិធានធន ក្នុងកម្រិតអប្បបរមាទៅតាមចំណាត់ថ្នាក់របស់ហ្វាស៊ីលីធីនោះ។ ចំនួនពិតប្រាកដអាចនឹងមានភាពខុសគ្នាខ្លាំងពីចំនួនដែលបានគណនានៅក្នុងព្រឹត្តិការណ៍ ដែលមិនបានរំពឹងទុកជាមុន ឬនៅពេលដែលចំនួនសង្ស័យនេះអាចត្រូវបានទូទាត់ដោយទ្រព្យដាក់ធានា។

**ពន្ធលើប្រាក់ចំណេញ**

ប្រព័ន្ធពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈច្រើនប្រភេទ និងបញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ ដែលជាទូទៅមានភាពមិនច្បាស់លាស់ មានភាពផ្ទុយគ្នា និងអាស្រ័យទៅលើការបកស្រាយ។ ជាទូទៅ យុត្តាធិការ និងអាជ្ញាធរពន្ធភាគច្រើន តែងតែមានការបកស្រាយផ្សេងៗពីគ្នា។ ពន្ធ គឺត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការអង្កេតដោយអាជ្ញាធរ ដែលបានផ្តល់សិទ្ធិដោយច្បាប់ក្នុងការដាក់ពិន័យ ដាក់ទណ្ឌកម្ម និងបង់ការប្រាក់។

បញ្ហាទាំងនេះអាចបង្កើតឱ្យមានហានិភ័យពន្ធយ៉ាងខ្លាំងសម្រាប់ក្រុមហ៊ុន។ អ្នកគ្រប់គ្រងជឿជាក់ថា ពួកគេមានការយល់ដឹងពីបទប្បញ្ញត្តិពន្ធដែលពាក់ព័ន្ធ និងបានធ្វើសំវិធានធន ដែលមានលក្ខណៈគ្រប់គ្រាន់ដោយផ្អែកទៅលើការបកស្រាយនៃនីតិកម្មពន្ធ។ ក៏ប៉ុន្តែអាជ្ញាធរជាប់ពាក់ព័ន្ធ អាចនឹងមានបំណកស្រាយខុសគ្នា ហើយផលប៉ះពាល់អាចមានទំហំធំ។

## 6. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បញ្ញើតាមច្បាប់: | | | | |
| ប្រាក់តម្កល់ធានាលើដើមទុន | 11,526,778 | 46,867,879 | 7,521,072 | 30,219,667 |
| ទុនបម្រុងកាតព្វកិច្ច | 46,854,774 | 190,511,511 | 39,883,312 | 160,251,148 |
| | 58,381,552 | 237,379,390 | 47,404,384 | 190,470,815 |
| គណនីចរន្ត | 6,858,243 | 27,885,616 | 25,878,687 | 103,980,564 |
| មូលបត្រអាចជួញដូរបាន | 9,367,968 | 38,090,158 | 4,319,117 | 17,354,212 |
| | 74,607,763 | 303,355,164 | 77,602,188 | 311,805,591 |

## 7. សមតុល្យនៅធនាគារនានា

សមតុល្យនៅធនាគារនានាត្រូវបានវាស់វែងតាមតម្លៃដករំលស់ ដោយសារតែឧបករណ៍ទាំងនេះ បានបំពេញលក្ខខណ្ឌ SPPI និងត្រូវបានរក្សាទុកដើម្បីប្រមូលសាច់ប្រាក់តាមកិច្ចសន្យា។

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យនៅធនាគារនានា វាស់វែងតាមតម្លៃដករំលស់ | 65,194,289 | 265,079,979 | 39,632,860 | 159,244,832 |
| សំវិធានធនលើការខាតបង់ ពីការធ្លាក់ចុះតម្លៃ | (72,466) | (294,647) | (38,545) | (154,874) |
| | 65,121,823 | 264,785,332 | 39,594,315 | 159,089,958 |

សមតុល្យនៅធនាគារនានាត្រូវបានធ្វើការវិភាគដូចខាងក្រោម៖

| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | តម្លៃដុល | ECL សំវិធានធន | តម្លៃយោង | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| គណនីចរន្ត | 18,936,391 | (8,991) | 18,927,400 | 76,958,808 |
| គណនីសន្សំ | 46,257,898 | (63,475) | 46,194,423 | 187,826,524 |
| | 65,194,289 | (72,466) | 65,121,823 | 264,785,332 |

## 7. សមតុល្យនៅធនាគារនានា (ត)

| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | តម្លៃដុល | ECL សំវិធានធន | តម្លៃយោង | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| គណនីចរន្ត | 11,982,271 | (3,123) | 11,979,148 | 48,132,217 |
| គណនីសន្សំ | 19,669,518 | (34,624) | 19,634,894 | 78,893,004 |
| គណនីមានកាលកំណត់ | 7,981,071 | (798) | 7,980,273 | 32,064,737 |
| | 39,632,860 | (38,545) | 39,594,315 | 159,089,958 |

## 8. ឥណទានផ្តល់ដល់អតិថិជន

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានផ្តល់ដល់អតិថិជនវាស់វែងតាមតម្លៃដករំលស់ | 872,341,461 | 3,546,940,381 | 750,111,956 | 3,013,949,840 |
| សំវិធានធនលើការខាតបង់ពីការធ្លាក់ចុះតម្លៃ | (6,940,571) | (28,220,362) | (8,272,928) | (33,240,625) |
| | 865,400,890 | 3,518,720,019 | 741,839,028 | 2,980,709,215 |

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវិភាគដូចខាងក្រោម៖

| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | តម្លៃដុល | ECL សំវិធានធន | តម្លៃយោង | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានឯកត្តជន | | | | |
| អតិថិជនខាងក្រៅ | | | | |
| ឥណទានគេហដ្ឋាន | 71,107,096 | (469,185) | 70,637,911 | 287,213,746 |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | 795,928,194 | (6,460,801) | 789,467,393 | 3,209,974,420 |
| ឥណទានបុគ្គលិក | 5,306,171 | (10,585) | 5,295,586 | 21,531,853 |
| | 872,341,461 | (6,940,571) | 865,400,890 | 3,518,720,019 |

## 8. ឥណទានផ្ដល់ដល់អតិថិជន (ត)

| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | តម្លៃដុល | ECL សំវិធានធន | តម្លៃយោង | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានឯកត្តជន | | | | |
| អតិថិជនខាងក្រៅ | | | | |
| ឥណទានគេហដ្ឋាន | 71,236,709 | (399,158) | 70,837,551 | 284,625,280 |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | 674,077,142 | (7,864,504) | 666,212,638 | 2,676,842,379 |
| ឥណទានបុគ្គលិក | 4,798,105 | (9,266) | 4,788,839 | 19,241,556 |
| | 750,111,956 | (8,272,928) | 741,839,028 | 2,980,709,215 |

## 9. វិនិយោគលើមូលបត្រ

ក្រុមហ៊ុនបានកំណត់ការវិនិយោគនៅក្នុង CMA Investment ជាឧបករណ៍ទ្រព្យម្ចាស់វាស់វែងតាម FVOCI ព្រោះក្រុមហ៊ុនកាន់កាប់ការវិនិយោគនេះក្នុងរយៈពេលវែង។ តារាងខាងក្រោមបង្ហាញពីការវិនិយោគនេះ រួមទាំងចំណូលភាគលាភដែលបានទទួលស្គាល់ពីការវិនិយោគនេះ។

| តម្លៃសមស្រប | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ការវិនិយោគក្នុង CMA Investment | 20,000 | 81,320 | 20,000 | 80,360 |

| ចំណូលភាគលាភ | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ការវិនិយោគក្នុង CMA Investment | 7,915 | 32,070 | - | - |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ការវិនិយោគក្នុង CMA Investment | 15,750 | 63,457 | - | - |

ហត្ថាកសិករ លីមីតធីត
កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

## 10. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | កែលម្អអគារជួល | យានយន្ត | កុំព្យូទ័រ | បរិក្ខារ | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | ការងារ កំពុងដំណើរការ | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **តម្លៃដើម** | | | | | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2019 | 2,028,458 | 2,817,715 | 5,192,431 | 5,538,063 | 705,237 | 38,632 | 16,320,536 | 65,575,913 |
| ការទិញបន្ថែម | 74,246 | - | 339,585 | 26,455 | 25,930 | 218,480 | 684,696 | 2,758,640 |
| ការលក់ចេញ | (13,105) | - | (125,171) | (92,339) | (5,505) | - | (236,120) | (951,327) |
| ការផ្ទេរ | 9,432 | - | 216,829 | 17,270 | 4,459 | (247,990) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | 799,983 |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ 2019 | 2,099,031 | 2,817,715 | 5,623,674 | 5,489,449 | 730,121 | 9,122 | 16,769,112 | 68,183,209 |
| ដក: **រំលស់បង្គរ** | | | | | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2019 | 1,586,760 | 1,931,929 | 3,803,058 | 4,253,887 | 596,268 | - | 12,171,902 | 48,906,702 |
| រំលស់ក្នុងគ្រា | 139,872 | 192,839 | 379,460 | 368,213 | 31,642 | - | 1,112,026 | 4,480,353 |
| ការលក់ចេញ | (13,105) | - | (124,865) | (91,462) | (5,506) | - | (234,938) | (946,565) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | 616,703 |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ 2019 | 1,713,527 | 2,124,768 | 4,057,653 | 4,530,638 | 622,404 | - | 13,048,990 | 53,057,193 |
| **តម្លៃយោង** | | | | | | | | |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ 2019 | **385,504** | **692,947** | **1,566,021** | **958,811** | **107,717** | **9,122** | **3,720,122** | **15,126,016** |

## ហត្ថាកសិករ លីមីតធីត
## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

### 10. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

| | កែលម្អអគារជួល | យានយន្ត | កុំព្យូទ័រ | បរិក្ខារ | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | ការងារ កំពុងដំណើរការ | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **តម្លៃដើម** | | | | | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2018 | 1,705,553 | 2,579,695 | 3,984,311 | 5,072,632 | 593,527 | 85,491 | 14,021,209 | 56,603,621 |
| ការទិញបន្ថែម | | | | | | | | |
| ពីថ្ងៃទី1 ខែមករា ដល់ថ្ងៃទី30 ខែមិថុនា | 205,998 | 7,920 | 338,301 | 57,018 | 49,419 | 196,861 | 855,517 | 3,446,878 |
| ពីថ្ងៃទី1 ខែកក្កដា ដល់ថ្ងៃទី31 ខែធ្នូ | 85,594 | 230,100 | 221,499 | 197,174 | 36,247 | 738,175 | 1,508,789 | 6,116,740 |
| ការលក់ចេញ | (14,302) | - | (32,230) | (17,732) | (715) | - | (64,979) | (262,840) |
| ការផ្ទេរ | 45,615 | - | 680,550 | 228,971 | 26,759 | (981,895) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | (328,486) |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ 2018 | 2,028,458 | 2,817,715 | 5,192,431 | 5,538,063 | 705,237 | 38,632 | 16,320,536 | 65,575,913 |
| ដក: **រំលស់បង្គរ** | | | | | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2018 | 1,269,164 | 1,552,313 | 3,208,531 | 3,493,713 | 538,504 | - | 10,062,225 | 40,621,203 |
| រំលស់ក្នុងគ្រា | | | | | | | | |
| ពីថ្ងៃទី1 ខែមករា ដល់ថ្ងៃទី30 ខែមិថុនា | 171,266 | 183,423 | 355,828 | 396,208 | 30,764 | - | 1,137,489 | 4,582,943 |
| ពីថ្ងៃទី1 ខែកក្កដា ដល់ថ្ងៃទី31 ខែធ្នូ | 160,632 | 196,193 | 270,862 | 381,698 | 27,715 | - | 1,037,100 | 4,213,270 |
| ការលក់ចេញ | (14,302) | - | (32,163) | (17,732) | (715) | - | (64,912) | (262,569) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | (248,145) |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ 2018 | 1,586,760 | 1,931,929 | 3,803,058 | 4,253,887 | 596,268 | - | 12,171,902 | 48,906,702 |
| **តម្លៃយោង** | | | | | | | | |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | **441,698** | **885,786** | **1,389,373** | **1,284,176** | **108,969** | **38,632** | **4,148,634** | **16,669,211** |

## 11. សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម

ក្រុមហ៊ុនមានកិច្ចសន្យាលើការជួលការិយាល័យដែលមានទីស្នាក់ការកណ្តាល ការិយាល័យសាខា និងទីតាំងម៉ាស៊ីន អេ ធី អឹម តាមទីសាធារណៈ។

| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | អគារការិយាល័យ | ទីតាំងម៉ាស៊ីន អេ ធី អឹម | សរុប | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **តម្លៃដើម** | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2019 | 15,095,836 | 346,831 | 15,442,667 | 62,048,636 |
| ការទិញបន្ថែម | 807,885 | 110,777 | 918,662 | 3,701,289 |
| ការចុះបញ្ជោស់ | (18,728) | (9,917) | (28,645) | (115,411) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 774,179 |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | **15,884,993** | **447,691** | **16,332,684** | **66,408,693** |
| ដក: **រំលស់បង្គរ** | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2019 | 2,540,403 | 113,999 | 2,654,402 | 10,665,387 |
| ការចុះបញ្ជោស់ | (4,058) | (6,226) | (10,284) | (41,434) |
| រំលស់ | 1,343,247 | 87,312 | 1,430,559 | 5,763,722 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 179,962 |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | **3,879,592** | **195,085** | **4,074,677** | **16,567,637** |
| **តម្លៃយោង** | | | | |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | **12,005,401** | **252,606** | **12,258,007** | **49,841,056** |

## 11. សិទ្ធិក្នុងការប្រើទ្រព្យសកម្ម (ត)

| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | អគារការិយាល័យ | ទីតាំងម៉ាស៊ីន អេ ធី អឹម | សរុប | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **តម្លៃដើម** | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2018 | 13,047,433 | 178,284 | 13,225,717 | 53,392,220 |
| ការទិញបន្ថែម | | | | |
| ពីថ្ងៃទី1 ខែមករា ដល់ថ្ងៃទី30 ខែមិថុនា | 1,392,315 | 56,447 | 1,448,762 | 5,837,062 |
| ពីថ្ងៃទី1 ខែកក្កដា ដល់ថ្ងៃទី31 ខែធ្នូ | 656,088 | 112,100 | 768,188 | 3,130,501 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (311,147) |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | **15,095,836** | **346,831** | **15,442,667** | **62,048,636** |
| ដក: **រំលស់បង្គរ** | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2018 | - | - | - | - |
| រំលស់ | | | | |
| ពីថ្ងៃទី1 ខែមករា ដល់ថ្ងៃទី30 ខែមិថុនា | 1,230,620 | 44,909 | 1,275,529 | 5,139,106 |
| ពីថ្ងៃទី1 ខែកក្កដា ដល់ថ្ងៃទី31 ខែធ្នូ | 1,309,783 | 69,090 | 1,378,873 | 5,597,950 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (71,669) |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | **2,540,403** | **113,999** | **2,654,402** | **10,665,387** |
| **តម្លៃយោង** | | | | |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | **12,555,433** | **232,832** | **12,788,265** | **51,383,249** |

## ធនាគារកសិករ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

## 12. ទ្រព្យសកម្មអរូបី

| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | សូហ្វវែរ និង អាជ្ញាប័ណ្ណ | ការងារ កំពុងដំណើរការ | សរុប | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **តម្លៃដើម** | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2019 | 3,095,091 | 366,562 | 3,461,653 | 13,908,921 |
| ការទិញបន្ថែម | 78,390 | 539,678 | 618,068 | 2,490,196 |
| ការផ្ទេរ | 182,908 | (182,908) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 189,029 |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | **3,356,389** | **723,332** | **4,079,721** | **16,588,146** |
| ដក: **រំលស់បង្គរ** | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2019 | 2,625,742 | - | 2,625,742 | 10,550,231 |
| រំលស់ | 102,449 | | 102,449 | 412,767 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 129,827 |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | **2,728,191** | **-** | **2,728,191** | **11,092,825** |
| **តម្លៃយោង** | | | | |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | **628,198** | **723,332** | **1,351,530** | **5,495,321** |

## 12. ទ្រព្យសកម្មអរូបី (ត)

| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | សូហ្វវែរ និង អាជ្ញាប័ណ្ណ | ការងារ កំពុងដំណើរការ | សរុប | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **តម្លៃដើម** | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2018 | 2,982,037 | 93,727 | 3,075,764 | 12,416,859 |
| ការទិញបន្ថែម | | | | |
| ពីថ្ងៃទី1 ខែមករា ដល់ថ្ងៃទី30 ខែមិថុនា | - | 28,875 | 28,875 | 116,337 |
| ពីថ្ងៃទី1 ខែកក្កដា ដល់ថ្ងៃទី31 ខែធ្នូ | 54,630 | 302,384 | 357,014 | 1,444,584 |
| ការផ្ទេរ | 58,424 | (58,424) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (68,859) |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | **3,095,091** | **366,562** | **3,461,653** | **13,908,921** |
| ដក: **រំលស់បង្គរ** | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2018 | 2,464,038 | - | 2,464,038 | 9,947,321 |
| រំលស់ | | | | |
| ពីថ្ងៃទី1 ខែមករា ដល់ថ្ងៃទី30 ខែមិថុនា | 78,542 | - | 78,542 | 316,446 |
| ពីថ្ងៃទី1 ខែកក្កដា ដល់ថ្ងៃទី31 ខែធ្នូ | 83,162 | - | 83,162 | 337,647 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (51,183) |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | **2,625,742** | **-** | **2,625,742** | **10,550,231** |
| **តម្លៃយោង** | | | | |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | **469,349** | **366,562** | **835,911** | **3,358,690** |

## 13. ពន្ធលើប្រាក់ចំណេញ

### (ក) ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុល ត្រូវបានកាត់កងនៅពេលមានការអនុញ្ញាតដោយច្បាប់ ក្នុងការកាត់កងរវាងពន្ធបច្ចុប្បន្នជាទ្រព្យសកម្ម និងបំណុលពន្ធប្រាក់ចំណេញបច្ចុប្បន្ន និងពន្ធដែលស្ថិតក្រោមអាជ្ញាធរពន្ធតែមួយ។ ចំនួនដែលបានកាត់កងរួចហើយ មានដូចខាងក្រោម៖

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ពន្ធពន្យារជាទ្រព្យសកម្ម | 5,694,858 | 23,155,292 | 5,397,699 | 21,687,955 |
| ពន្ធពន្យារជាបំណុល | (2,175,261) | (8,844,611) | (2,297,487) | (9,231,303) |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | 3,519,597 | 14,310,681 | 3,100,212 | 12,456,652 |

## 13. ពន្ធលើប្រាក់ចំណេញ (ត)

### (គ) ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ (ត)

បម្រែបម្រួលពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ មានដូចខាងក្រោម៖

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាដើមគ្រា/ឆ្នាំ | 3,100,212 | 12,456,652 | 1,876,639 | 7,575,992 |
| បញ្ចូលក្នុងចំណេញ-ខាត | | | | |
| ពីថ្ងៃទី1 ខែមករា ដល់ថ្ងៃទី30 ខែមិថុនា | 419,385 | 1,689,703 | 719,952 | 2,900,687 |
| ពីថ្ងៃទី1 ខែកក្កដា ដល់ថ្ងៃទី31 ខែធ្នូ | - | - | 503,621 | 2,048,666 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 164,326 | - | (68,693) |
| នាចុងគ្រា/ឆ្នាំ | 3,519,597 | 14,310,681 | 3,100,212 | 12,456,652 |

ពន្ធពន្យារជាទ្រព្យសកម្ម/(បំណុល) បានមកពីសមាសធាតុដូចខាងក្រោម៖

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ | 121,438 | 493,767 | 1,762 | 7,080 |
| ប្រាក់រង្វាន់និងច្បាប់សម្រាកមិនទាន់ប្រើ | 42,056 | 171,000 | 42,569 | 171,040 |
| ចំណេញពីការប្តូរប្រាក់ដែលមិនទាន់ទទួលស្គាល់ | (66,341) | (269,743) | (15,744) | (63,259) |
| រំលស់ | (2,108,920) | (8,574,869) | (2,281,743) | (9,168,043) |
| សំវិធានធនសម្រាប់ការខាតបង់ពីការធ្លាក់ចុះ | | | | |
| តម្លៃ | 843,529 | 3,429,789 | 1,078,868 | 4,334,892 |
| ចំណូល/ចំណាយកម្រៃសេវាបានពន្យារ | 1,929,075 | 7,843,619 | 1,616,115 | 6,493,550 |
| ខាតលើតម្លៃសមស្រប | 179,642 | 730,424 | 8,308 | 33,382 |
| បំណុលភតិសន្យា | 2,563,531 | 10,423,317 | 2,634,490 | 10,585,381 |
| ឥណទានពន្ធមិនទាន់ប្រើប្រាស់ | 15,587 | 63,377 | 15,587 | 62,629 |
| | 3,519,597 | 14,310,681 | 3,100,212 | 12,456,652 |

## 13. ពន្ធលើប្រាក់ចំណេញ (ត)

### (ខ) ចំណុលពន្ធលើប្រាក់ចំណេញ

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យនាដើមគ្រា/ឆ្នាំ | 4,862,542 | 19,537,694 | 3,510,009 | 14,169,906 |
| ចំណាយពន្ធលើប្រាក់ចំណេញ | | | | |
| ពីថ្ងៃទី1 ខែមករា ដល់ថ្ងៃទី30 ខែមិថុនា | 3,732,675 | 15,038,948 | 2,764,095 | 11,136,539 |
| ពីថ្ងៃទី1 ខែកក្កដា ដល់ថ្ងៃទី31 ខែធ្នូ | - | - | 3,125,016 | 12,684,915 |
| ពន្ធបានបង់ | | | | |
| ពីថ្ងៃទី1 ខែមករា ដល់ថ្ងៃទី30 ខែមិថុនា | (5,623,475) | (22,656,981) | (3,981,910) | (16,043,115) |
| ពីថ្ងៃទី1 ខែកក្កដា ដល់ថ្ងៃទី31 ខែធ្នូ | - | - | (554,668) | (2,234,758) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 163,442 | - | (175,793) |
| សមតុល្យនាចុងគ្រា/ឆ្នាំ | 2,971,742 | 12,083,103 | 4,862,542 | 19,537,694 |

### (គ) ចំណាយពន្ធលើប្រាក់ចំណេញ

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | 1,780,774 | 7,219,632 | 1,337,785 | 5,414,183 |
| ពន្ធពន្យារ | (188,260) | (763,816) | (326,605) | (1,322,579) |
| ចំណាយពន្ធលើប្រាក់ចំណេញ | 1,592,514 | 6,455,816 | 1,011,180 | 4,091,604 |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | 3,732,675 | 15,038,948 | 2,764,095 | 11,136,539 |
| ពន្ធពន្យារ | (419,385) | (1,689,703) | (719,952) | (2,900,687) |
| ចំណាយពន្ធលើប្រាក់ចំណេញ | 3,313,290 | 13,349,245 | 2,044,143 | 8,235,852 |

## 13. ពន្ធលើប្រាក់ចំណេញ (ត)

### (គ) ចំណាយពន្ធលើប្រាក់ចំណេញ (ត)

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញដែលគណនាតាមអត្រាពន្ធផ្លូវការ20% ធៀបទៅនឹងពន្ធលើប្រាក់ចំណេញដែលបង្ហាញក្នុងរបាយការណ៍លទ្ធផលមានដូចខាងក្រោមៈ

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ប្រាក់ចំណេញមុនដកពន្ធ | 7,927,506 | 32,117,863 | 4,983,384 | 20,164,125 |
| ពន្ធលើប្រាក់ចំណេញផ្អែកតាមអត្រាពន្ធជាផ្លូវការ 20% | 1,585,501 | 6,423,573 | 996,677 | 4,032,825 |
| ចំណាយមិនអាចកាត់កងបាន | 7,013 | 32,243 | 14,504 | 58,779 |
| សំវិធានធនខ្វះពីឆ្នាំមុន | - | - | - | - |
| ចំណាយពន្ធលើប្រាក់ចំណេញ តាមអត្រា 20% | 1,592,514 | 6,455,816 | 1,011,180 | 4,091,604 |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ប្រាក់ចំណេញមុនដកពន្ធ | 15,664,015 | 63,110,317 | 10,046,302 | 40,476,551 |
| ពន្ធលើប្រាក់ចំណេញផ្អែកតាមអត្រាពន្ធជាផ្លូវការ 20% | 3,132,803 | 12,622,063 | 2,009,260 | 8,095,309 |
| ចំណាយមិនអាចកាត់កងបាន | 15,693 | 63,227 | 33,385 | 134,508 |
| សំវិធានធនខ្វះពីឆ្នាំមុន | 164,794 | 663,955 | 1,498 | 6,035 |
| ចំណាយពន្ធលើប្រាក់ចំណេញ តាមអត្រា 20% | 3,313,290 | 13,349,245 | 2,044,143 | 8,235,852 |

អនុលោមទៅតាមច្បាប់ពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ ដោយគណនាតាមអត្រា 20% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមាដោយគណនាតាមអត្រា 1% នៃប្រាក់ចំណូលសរុប ដោយកំណត់យកចំនួនពន្ធ ត្រូវបង់ណាដែលធំជាង។

## 14. ទ្រព្យសកម្មផ្សេងៗ

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយនិយោជិតបានពន្យារ | 6,302,782 | 25,627,112 | 5,729,783 | 23,022,268 |
| សេវាកម្មលើការថែទាំបង់មុន | 422,161 | 1,716,507 | 428,852 | 1,723,127 |
| ប្រាក់កក់លើការជួលការិយាល័យ និងទីតាំង អេ ធី អឹម | 1,337,179 | 5,436,970 | 1,298,844 | 5,218,755 |
| ទឹកប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ (*) | 1,890 | 7,685 | 945 | 3,797 |
| ទ្រព្យត្រូវទទួលផ្សេងៗទៀត | 1,117,623 | 4,544,254 | 480,453 | 1,930,461 |
| | 9,181,635 | 37,332,528 | 7,938,877 | 31,898,408 |

(*) ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ ដែលនាំឱ្យនូវមានទឹកប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ ដែលបានរៀបរាប់ខាងលើ ត្រូវបានធ្វើឡើងស្របតាមលក្ខខណ្ឌពាណិជ្ជកម្មដែលបានចរចារ។

## 15. ប្រាក់បញ្ញើរបស់អតិថិជន

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| វាស់វែងតាមតម្លៃដករំលស់ | | | | |
| ប្រាក់បញ្ញើសន្សំ | 123,129,750 | 500,645,564 | 89,038,151 | 357,755,291 |
| ប្រាក់បញ្ញើមានកាលកំណត់ | 450,915,773 | 1,833,423,533 | 402,315,239 | 1,616,502,630 |
| | 574,045,523 | 2,334,069,097 | 491,353,390 | 1,974,257,921 |

## 16. មូលបត្របំណុល

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| មូលបត្របំណុល | | | | |
| វាស់វែងតាមតម្លៃដករំលស់ | 29,122,787 | 118,413,252 | 29,325,252 | 117,828,863 |

នៅថ្ងៃទី1 ខែសីហា ឆ្នាំ2018 អេច ខេ អិល ទទួលបានលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ក្នុងការបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្ម។

## 16. មូលបត្របំណុល (ត)

នៅថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2018 អេច ខេ អិល បានទទួលការអនុញ្ញាត និងចុះបញ្ជីជាស្ថាពរ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) លើទម្រង់ពាក្យស្នើសុំរួម និងឯកសារផ្តល់ព័ត៌មាន សម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្មជាសារធារណៈ។ សញ្ញាបណ្ណត្រូវបានផ្សាយលក់ទៅឱ្យវិនិយោគិន នាថ្ងៃទី14 ខែវិច្ឆិកា ឆ្នាំ2018។

នៅថ្ងៃទី5 ខែធ្នូ ឆ្នាំ2018 អេច ខេ អិល បានចុះបញ្ជីជាស្ថាពរក្នុងផ្សារមូលបត្រកម្ពុជា ("CSX")។ នេះគឺជាក្រុមហ៊ុនមុនដំបូងគេ ដែលបានចុះបញ្ជីសញ្ញាបណ្ណសាជីវកម្មរបស់ខ្លួន នៅទីផ្សារមូលបត្រកម្ពុជា។

សញ្ញាបណ្ណសាជីវកម្មទីមួយ ត្រូវបានបោះចេញដោយ អេច ខេ អិល ក្នុងតម្លៃសរុប 120 ពាន់លានរៀល។ មូលបត្របំណុលនេះមានរយៈកាល 3 ឆ្នាំ និងផ្តល់អត្រាការប្រាក់ 8.50% ក្នុងមួយឆ្នាំ។

អេច ខេ អិល មិនបានខកខានក្នុងការទូទាត់សងប្រាក់ដើម ឬការប្រាក់ ហើយក៏មិនមានការបំពានណាមួយពាក់ព័ន្ធនឹងមូលបត្របំណុលក្នុងគ្រានេះទេ។

## 17. ប្រាក់កម្ចី

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| វាស់វែងតាមតម្លៃដករំលស់ | | | | |
| អត្រាការប្រាក់ប្រែប្រួល | 57,999,915 | 235,827,654 | 74,434,122 | 299,076,302 |
| អត្រាការប្រាក់ថេរ | 183,369,594 | 745,580,770 | 117,291,036 | 471,275,383 |
| | 241,369,509 | 981,408,424 | 191,725,158 | 770,351,685 |

អេច ខេ អិល មិនបានខកខានក្នុងការទូទាត់សងប្រាក់ដើម ឬការប្រាក់ ហើយក៏មិនមានការបំពានណាមួយពាក់ព័ន្ធនឹងមូលបត្របំណុលក្នុងគ្រានេះទេ។

## 18. អនុបំណុល

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| វាស់វែងតាមតម្លៃដករំលស់ | | | | |
| អត្រាការប្រាក់ប្រែប្រួល | 7,576,493 | 30,806,021 | 10,104,516 | 40,599,945 |
| អត្រាការប្រាក់ថេរ | 7,971,763 | 32,413,188 | 13,131,780 | 52,763,492 |
| | 15,548,256 | 63,219,209 | 23,236,296 | 93,363,437 |

ការទូទាត់សងអនុបំណុល គឺអាចធ្វើបាន បន្ទាប់ពីការទូទាត់កាតព្វកិច្ចបំណុលផ្សេងៗ របស់ក្រុមហ៊ុន និងត្រូវអនុម័តដោយធនាគារជាតិនៃកម្ពុជា ជាមុនសិន។

## 19. និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| តម្លៃសមស្រប | | | | |
| អត្រាការប្រាក់ | 907,996 | 3,691,912 | 27,794 | 111,676 |
| អត្រារូបិយប័ណ្ណ | (5,928) | (24,104) | - | - |
| | 902,068 | 3,667,808 | 27,794 | 111,676 |

អេច ខេ អិល ប្រើនិស្សន្ទខាងលើ ដើម្បីទប់ស្កាត់ហានិភ័យអត្រាការប្រាក់ និងហានិភ័យរូបិយប័ណ្ណ។ ឧបករណ៍ដែលប្រើជាចម្បង រួមមាន ការប្តូរអត្រាការប្រាក់ និងការប្តូររូបិយប័ណ្ណ។

## 20. បំណុលភតិសន្យា

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ត្រឹម 1 ឆ្នាំ | 2,412,996 | 9,811,242 | 2,354,436 | 9,460,124 |
| លើសពី 1 ឆ្នាំ និងត្រឹម 5 ឆ្នាំ | 7,354,768 | 29,904,487 | 7,305,029 | 29,351,607 |
| លើសពី 5 ឆ្នាំ | 3,049,892 | 12,400,860 | 3,512,983 | 14,115,165 |
| | 12,817,656 | 52,116,589 | 13,172,448 | 52,926,896 |

## 21. សំវិធានធន

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| កិច្ចសន្យាឥណទាន | 26,422 | 107,432 | 3,599 | 14,461 |

ចំនួនដែលពាក់ព័ន្ធនឹងកិច្ចសន្យាឥណទាន តំណាងឱ្យសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុក។

## 22. ចំណូលផ្សេងៗ

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ | 614,592 | 2,498,931 | 12,580 | 50,546 |
| ទឹកប្រាក់ជំពាក់សម្ព័ន្ធញាតិ (*) | 96,816 | 393,654 | 135,322 | 543,724 |
| អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី | 3,599,374 | 14,635,055 | 3,165,403 | 12,718,589 |
| អ្នកផ្គត់ផ្គង់ និងការបង្គរ | 462,037 | 1,878,642 | 674,450 | 2,709,940 |
| ផ្សេងៗ | 1,277,764 | 5,195,388 | 1,139,998 | 4,580,513 |
| | 6,050,583 | 24,601,670 | 5,127,753 | 20,603,312 |

(*) ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ ដែលនាំឱ្យមានទឹកប្រាក់ជំពាក់សម្ព័ន្ធញាតិ បានរៀបរាប់ខាងលើ ត្រូវបានធ្វើឡើងស្របតាមលក្ខខណ្ឌពាណិជ្ជកម្មដែលបានចរចារ។

## 23. ដើមទុន

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ភាគហ៊ុនបានចុះបញ្ជីបែងចែកនិងបង់គ្រប់ចំនួន មានតម្លៃ1ដុល្លារអាមេរិកក្នុង1ហ៊ុន | 75,000,000 | 304,950,000 | 75,000,000 | 301,350,000 |

ក្រុមហ៊ុនត្រូវបានកាន់កាប់ទាំងស្រុងដោយធនាគារ Ayudhya PCL ("Krungsri") ដែលជាក្រុមហ៊ុនចុះបញ្ជីនៅប្រទេសថៃ ដែលមានសុពលភាពពីថ្ងៃទី12 ខែកញ្ញា ឆ្នាំ2016។

នៅថ្ងៃទី10 ខែឧសភា ឆ្នាំ2019 អេច ខេ អិល បានដាក់សំណើសុំការអនុម័តពីធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនដើមទុនចំនួន 40 លានដុល្លារអាមេរិក ពី 75 លានដុល្លារអាមេរិកដល់ 115 លានដុល្លារអាមេរិក ដោយធ្វើការផ្ទេរពីប្រាក់ចំណេញរក្សាទុក។ សំណើនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី19 ខែមិថុនា ឆ្នាំ2019។

## 24. ទុនបម្រុង

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទុនបម្រុងស្របច្បាប់ | 682,459 | 2,774,878 | 682,459 | 2,742,120 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 4,371,830 | 17,775,861 | 2,413,973 | 9,699,344 |
| ទុនបម្រុងផ្សេងៗ | 1,292,755 | 5,256,342 | 1,292,755 | 5,194,289 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 3,637,622 | - | - |
| | 6,347,044 | 29,444,703 | 4,389,187 | 17,635,753 |

## 25. ចំណូលពីការប្រាក់សុទ្ធ

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| **ចំណូលពីការប្រាក់** | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 36,111 | 146,185 | 24,316 | 98,094 |
| សមតុល្យនៅធនាគារនានា | 17,867 | 73,215 | 10,356 | 42,146 |
| ឥណទានផ្តល់ដល់អតិថិជន | 34,031,955 | 137,843,132 | 26,739,927 | 108,166,741 |
| | 34,085,933 | 138,062,532 | 26,774,599 | 108,306,981 |
| **ចំណាយលើការប្រាក់** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 8,930,338 | 36,169,345 | 6,429,454 | 26,001,968 |
| មូលបត្របំណុល | 685,962 | 2,779,944 | - | - |
| ប្រាក់កម្ចី | 4,330,589 | 17,532,704 | 4,148,235 | 16,774,528 |
| អនុបំណុល | 488,353 | 1,982,993 | 674,443 | 2,728,885 |
| បំណុលភតិសន្យា | 239,363 | 969,946 | 246,556 | 997,495 |
| | 14,674,605 | 59,434,932 | 11,498,688 | 46,502,876 |
| **ចំណូលពីការប្រាក់សុទ្ធ** | 19,411,328 | 78,627,600 | 15,275,911 | 61,804,105 |

## 25. ចំណូលពីការប្រាក់សុទ្ធ (ត)

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| **ចំណូលពីការប្រាក់** | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 66,274 | 267,018 | 31,653 | 127,530 |
| សមតុល្យនៅធនាគារនានា | 71,306 | 287,292 | 35,062 | 141,265 |
| ឥណទានផ្តល់ដល់អតិថិជន | 65,700,884 | 264,708,861 | 52,126,813 | 210,018,929 |
| | 65,838,464 | 265,263,171 | 52,193,528 | 210,287,724 |
| **ចំណាយលើការប្រាក់** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 17,148,302 | 69,090,509 | 12,176,392 | 49,058,683 |
| មូលបត្របំណុល | 1,390,434 | 5,602,059 | - | - |
| ប្រាក់កម្ចី | 8,015,845 | 32,295,840 | 7,753,499 | 31,238,847 |
| អនុបំណុល | 1,158,712 | 4,668,451 | 1,354,060 | 5,455,508 |
| បំណុលភតិសន្យា | 480,798 | 1,937,134 | 488,975 | 1,970,081 |
| | 28,194,091 | 113,593,993 | 21,772,926 | 87,723,119 |
| **ចំណូលពីការប្រាក់សុទ្ធ** | 37,644,373 | 151,669,178 | 30,420,602 | 122,564,605 |

ទឹកប្រាក់បង្ហាញខាងលើ គឺជាចំណូលការប្រាក់ និងចំណាយការប្រាក់ ដែលត្រូវបានគណនាតាមវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ដែលពាក់ព័ន្ធនឹងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ វាស់វែងតាមតម្លៃដករំលស់។

## ហត្ថាកសិករ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

### 26. ចំណូលពីកម្រៃជើងសារសុទ្ធ

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| **ចំណូលពីកម្រៃជើងសារ** | | | | |
| កម្រៃណែនាំ | 309,179 | 1,253,896 | 35,598 | 143,424 |
| កម្រៃផ្ទេរប្រាក់ | 32,688 | 132,487 | 28,690 | 116,057 |
| កម្រៃសេវាលើគណនីបញ្ញើ | 59,779 | 242,285 | 74,277 | 300,746 |
| កម្រៃជើងសារផ្សេងៗលើឥណទាន | 673,256 | 2,729,278 | 380,772 | 1,540,620 |
| ចំណូលពីកម្រៃផ្សេងៗ | 33,013 | 133,811 | 66,822 | 270,216 |
| | 1,107,915 | 4,491,757 | 586,159 | 2,371,063 |
| **ចំណាយលើកម្រៃជើងសារ** | | | | |
| កម្រៃជើងសារលើប្រាក់កម្ចី | 106,627 | 432,042 | 98,038 | 396,844 |
| កម្រៃជើងសារលើមូលបត្របំណុល | 4,503 | 18,245 | - | - |
| កម្រៃជើងសារលើអនុបំណុល | 1,306 | 5,291 | 1,306 | 5,284 |
| កម្រៃណែនាំ | 13,803 | 55,953 | 10,659 | 43,163 |
| សោហ៊ុយធនាគារ | 62,509 | 253,122 | 73,577 | 297,476 |
| | 188,748 | 764,653 | 183,580 | 742,767 |
| **ចំណូចំណូលពីកម្រៃជើងសារសុទ្ធ** | 919,167 | 3,727,104 | 402,579 | 1,628,296 |

## 26. ចំណូលពីកម្រៃជើងសារសុទ្ធ (ត)

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| **ចំណូលពីកម្រៃជើងសារ** | | | | |
| កម្រៃណែនាំ | 666,307 | 2,684,551 | 35,598 | 143,424 |
| កម្រៃផ្ទេរប្រាក់ | 66,912 | 269,588 | 56,051 | 225,829 |
| កម្រៃសេវាលើគណនីបញ្ញើ | 122,180 | 492,263 | 161,569 | 650,962 |
| កម្រៃជើងសារផ្សេងៗលើឥណទាន | 1,400,606 | 5,643,042 | 762,565 | 3,072,374 |
| ចំណូលពីកម្រៃផ្សេងៗ | 67,889 | 273,525 | 124,968 | 503,497 |
| | 2,323,894 | 9,362,969 | 1,140,751 | 4,596,086 |
| **ចំណាយលើកម្រៃជើងសារ** | | | | |
| កម្រៃជើងសារលើប្រាក់កម្ចី | 212,780 | 857,291 | 206,835 | 833,338 |
| កម្រៃជើងសារលើមូលបត្របំណុល | 8,957 | 36,088 | - | - |
| កម្រៃជើងសារលើអនុបំណុល | 2,598 | 10,467 | 2,570 | 10,355 |
| កម្រៃណែនាំ | 28,605 | 115,250 | 23,493 | 94,653 |
| សោហ៊ុយធនាគារ | 117,868 | 474,889 | 134,415 | 541,558 |
| | 370,808 | 1,493,985 | 367,313 | 1,479,904 |
| **ចំណូលពីកម្រៃជើងសារសុទ្ធ** | 1,953,086 | 7,868,984 | 773,438 | 3,116,182 |

ចំណូលពីកម្រៃជើងសារសុទ្ធ រួមមានចំណាយចំនួន 224,335 ដុល្លារអាមេរិក ពាក់ព័ន្ធនឹងបំណុលហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់។ តួលេខនេះ មិនរួមបញ្ចូលនូវចំនួនដែលត្រូវយកមកគណនាអត្រាការប្រាក់ប្រសិទ្ធភាព សម្រាប់បំណុលហិរញ្ញវត្ថុទាំងនោះទេ។

## 27. ចំណេញ/(ខាត)សុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| អត្រាការប្រាក់ | 471,438 | 1,907,638 | (121,089) | (486,407) |
| អត្រាប្តូរប្រាក់ | (38,031) | (152,489) | - | - |
| | 433,407 | 1,755,149 | (121,089) | (486,407) |

## 27. ចំណេញ/(ខាត)សុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL (ត)

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| អត្រាការប្រាក់ | 828,588 | 3,338,381 | (35,177) | (141,728) |
| អត្រាប្តូរប្រាក់ | (5,928) | (23,884) | - | - |
| | 822,660 | 3,314,497 | (35,177) | (141,728) |

## 28. ចំណូលផ្សេងៗ

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ភាគលាភពីមូលបត្រកម្មសិទ្ធិ វាស់វែងតាម FVOCI | 7,915 | 32,070 | - | - |
| ចំណេញ/(ខាត)ពីការប្តូររូបិយប័ណ្ណ | 7,249 | 32,651 | (443,184) | (1,781,764) |
| ចំណូលផ្សេងៗទៀត | 18,581 | 75,344 | 19,479 | 78,777 |
| | 33,745 | 140,065 | (423,705) | (1,702,987) |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ភាគលាភពីមូលបត្រកម្មសិទ្ធិ វាស់វែងតាម FVOCI | 15,750 | 63,457 | - | - |
| ចំណេញ/(ខាត)ពីការប្តូររូបិយប័ណ្ណ | 156,997 | 632,541 | (218,231) | (879,253) |
| ចំណូលផ្សេងៗទៀត | 39,513 | 159,198 | 36,873 | 148,562 |
| | 212,260 | 855,196 | (181,358) | (730,691) |

## 29. ការខាតបង់ពីការធ្លាក់ចុះតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| សមតុល្យនៅធនាគារនានា | 4,350 | 18,204 | 5,114 | 20,750 |
| ឥណទានផ្តល់ដល់អតិថិជន (*) | 196,650 | 795,224 | 888,354 | 3,591,448 |
| កិច្ចសន្យាឥណទាន | 22,681 | 91,385 | (3,764) | (15,148) |
| | 223,681 | 904,813 | 889,704 | 3,597,050 |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| សមតុល្យនៅធនាគារនានា | 33,819 | 136,257 | 13,691 | 55,161 |
| ឥណទានផ្តល់ដល់អតិថិជន (*) | 323,665 | 1,304,046 | 1,610,062 | 6,486,940 |
| កិច្ចសន្យាឥណទាន | 22,822 | 91,950 | (2,674) | (10,774) |
| | 380,306 | 1,532,253 | 1,621,079 | 6,531,327 |

តម្លៃនេះរួមបញ្ចូលការទទួលបានមកវិញនូវឥណទានដែលបានលុបចោលពីបញ្ជី ចំនួន 359,824 ដុល្លារអាមេរិក (ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018: 122,219 ដុល្លារអាមេរិក)។

## 30. ចំណាយបុគ្គលិក

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ប្រាក់បៀវត្សរ៍ និងបុព្វលាភ | 7,003,316 | 28,368,379 | 5,390,925 | 21,817,742 |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ | 311,106 | 1,260,313 | 226,955 | 918,114 |
| ប្រាក់ចំណាច់អតីតភាពការងារ | 324,799 | 1,317,215 | - | - |
| ចំណាយបុគ្គលិកផ្សេងៗ | 699,499 | 2,833,428 | 579,665 | 2,348,291 |
| | 8,338,720 | 33,779,335 | 6,197,545 | 25,084,147 |

## 30. ចំណាយបុគ្គលិក (ត)

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ប្រាក់បៀវត្សរ៍ និងបុព្វលាភ | 13,612,839 | 54,846,128 | 11,138,260 | 44,876,050 |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ | 609,704 | 2,456,497 | 445,355 | 1,794,335 |
| ប្រាក់ចំណាច់អតីតភាពការងារ | 698,739 | 2,815,219 | - | - |
| ចំណាយបុគ្គលិកផ្សេងៗ | 1,357,973 | 5,471,274 | 1,333,792 | 5,373,848 |
| | 16,279,255 | 65,589,118 | 12,917,407 | 52,044,233 |

## 31. ចំណាយរំលស់

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | 561,019 | 2,273,019 | 579,466 | 2,344,155 |
| សិទ្ធិក្នុងការប្រើទ្រព្យសកម្ម | 720,187 | 2,917,972 | 653,947 | 2,645,319 |
| ទ្រព្យសកម្មអរូបី | 53,739 | 217,634 | 39,488 | 159,761 |
| | 1,334,945 | 5,408,625 | 1,272,901 | 5,149,235 |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | 1,112,026 | 4,480,353 | 1,137,489 | 4,582,943 |
| សិទ្ធិក្នុងការប្រើទ្រព្យសកម្ម | 1,430,559 | 5,763,722 | 1,275,529 | 5,139,106 |
| ទ្រព្យសកម្មអរូបី | 102,449 | 412,767 | 78,542 | 316,446 |
| | 2,645,034 | 10,656,842 | 2,491,560 | 10,038,495 |

## 32. ចំណាយផ្សេងៗ

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ការធ្វើដំណើរនិងយានយន្ត | 507,136 | 2,054,422 | 443,205 | 1,792,925 |
| ការជួសជុស និងថែទាំ | 315,419 | 1,277,240 | 257,591 | 1,043,038 |
| ការផ្សព្វផ្សាយពាណិជ្ជកម្ម និងទីផ្សារ | 186,841 | 755,580 | 174,724 | 706,289 |
| ការរក្សាសន្តិសុខ | 173,826 | 704,349 | 172,602 | 698,268 |
| ទឹក-ភ្លើង | 177,207 | 718,026 | 174,985 | 707,574 |
| កម្រៃអាជ្ញាប័ណ្ណ ពន្ធប៉ាតង់ និងពន្ធផ្សេងៗ | 173,130 | 701,088 | 183,813 | 743,340 |
| សម្ភារៈការិយាល័យ និងបរិក្ខារ | 170,855 | 691,422 | 164,744 | 666,218 |
| ការទំនាក់ទំនង | 161,191 | 653,087 | 129,206 | 522,769 |
| សេវាវិជ្ជាជីវៈ | 57,092 | 231,293 | 62,595 | 252,840 |
| ការជួល និងភតិសន្យា | 105,996 | 429,317 | 152,414 | 616,974 |
| ថ្លៃឈ្នួល និងការប្រជុំក្រុមប្រឹក្សាភិបាល | 31,651 | 127,905 | 25,729 | 103,933 |
| ផ្សេងៗ | 45,637 | 185,255 | 90,732 | 367,096 |
| | 2,105,981 | 8,528,984 | 2,032,340 | 8,221,264 |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ការធ្វើដំណើរនិងយានយន្ត | 992,812 | 4,000,040 | 869,831 | 3,504,549 |
| ការជួសជុស និងថែទាំ | 594,423 | 2,394,930 | 563,731 | 2,271,272 |
| ការផ្សព្វផ្សាយពាណិជ្ជកម្ម និងទីផ្សារ | 308,490 | 1,242,906 | 311,506 | 1,255,058 |
| ការរក្សាសន្តិសុខ | 347,900 | 1,401,689 | 340,522 | 1,371,963 |
| ទឹក-ភ្លើង | 353,674 | 1,424,953 | 325,547 | 1,311,629 |
| កម្រៃអាជ្ញាប័ណ្ណ ពន្ធប៉ាតង់ និងពន្ធផ្សេងៗ | 327,394 | 1,319,070 | 346,026 | 1,394,139 |
| សម្ភារៈការិយាល័យ និងបរិក្ខារ | 303,350 | 1,222,197 | 309,675 | 1,247,681 |
| ការទំនាក់ទំនង | 319,833 | 1,288,607 | 258,496 | 1,041,480 |
| សេវាវិជ្ជាជីវៈ | 112,277 | 452,364 | 100,507 | 404,943 |
| ការជួល និងភតិសន្យា | 204,199 | 822,718 | 322,891 | 1,300,928 |
| ថ្លៃឈ្នួល និងការប្រជុំក្រុមប្រឹក្សាភិបាល | 48,303 | 194,613 | 41,693 | 167,981 |
| ផ្សេងៗ | 105,794 | 426,244 | 181,086 | 729,595 |
| | 4,018,449 | 16,190,331 | 3,971,511 | 16,001,218 |

## 33. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន៖

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| សាច់ប្រាក់ក្នុងដៃ | 26,268,257 | 106,806,733 | 13,356,106 | 54,265,859 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 16,207,431 | 65,899,414 | 25,986,636 | 105,583,702 |
| សមតុល្យនៅធនាគារនានា | 65,185,915 | 265,045,931 | 58,595,795 | 238,074,715 |
| | 107,661,603 | 437,752,078 | 97,938,537 | 397,924,276 |

## 34. ប្រតិបត្តិការ និងសមតុល្យជាមួយសម្ព័ន្ធញាតិ

### (ក) សម្ព័ន្ធញាតិ និងទំនាក់ទំនង

សម្ព័ន្ធញាតិរបស់ក្រុមហ៊ុន និងទំនាក់ទំនងសម្ព័ន្ធញាតិជាមួយក្រុមហ៊ុន មានដូចខាងក្រោម៖

| សម្ព័ន្ធញាតិ | ទំនាក់ទំនង |
|---|---|
| Mitsubishi UFJ Financial Group, Inc., | ក្រុមហ៊ុនមេធំ |
| Bank of Ayudhya Public Company Limited ("Krungsri") | ក្រុមហ៊ុនមេផ្ទាល់/ ភាគទុនិក |
| សម្ព័ន្ធ | ក្រុមហ៊ុនទាំងអស់ដែលស្ថិតនៅក្រោមក្រុមហ៊ុនមេធំតែមួយ |
| ក្រុមប្រឹក្សាភិបាល | សមាជិកក្រុមប្រឹក្សាភិបាល គឺជារូបវន្តបុគ្គលដែលគ្រប់គ្រងសកម្មភាពរបស់ក្រុមហ៊ុន។ |
| អ្នកគ្រប់គ្រងសំខាន់ៗ | អ្នកគ្រប់គ្រងសំខាន់ៗគឺជារូបវន្តបុគ្គលដែលចូលរួមក្នុងការគ្រប់គ្រង ដឹកនាំ ផ្តួចផ្តើម ឬអនុវត្តគោលនយោបាយរបស់ក្រុមហ៊ុន។ អ្នកគ្រប់គ្រងសំខាន់ៗរបស់ក្រុមហ៊ុន រួមមានសមាជិក EXCOM ទាំងអស់ដែលបានតែងតាំងដោយក្រុមប្រឹក្សាភិបាល។ |

## 34. ប្រតិបត្តិការ និងសមតុល្យជាមួយសម្ព័ន្ធញាតិ (ត)

### (ខ) ការទូទាត់ជូនអ្នកគ្រប់គ្រងសំខាន់ៗ និងក្រុមប្រឹក្សាភិបាល

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ក្រុមប្រឹក្សាភិបាល | | | | |
| ថ្លៃឈ្នួលនិងចំណាយពាក់ព័ន្ធផ្សេងៗ | 31,651 | 127,905 | 25,729 | 103,933 |
| អ្នកគ្រប់គ្រងសំខាន់ៗ | | | | |
| ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍រយៈ | | | | |
| ពេលខ្លី | 429,139 | 1,745,408 | 440,319 | 1,787,170 |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ | 24,567 | 99,516 | 20,944 | 84,717 |
| | 453,706 | 1,844,924 | 461,263 | 1,871,887 |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ក្រុមប្រឹក្សាភិបាល | | | | |
| ថ្លៃឈ្នួលនិងចំណាយពាក់ព័ន្ធផ្សេងៗ | 48,303 | 194,613 | 41,693 | 167,981 |
| អ្នកគ្រប់គ្រងសំខាន់ៗ | | | | |
| ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍រយៈ | | | | |
| ពេលខ្លី | 1,142,486 | 4,603,076 | 1,212,358 | 4,884,590 |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ | 47,813 | 192,639 | 40,586 | 163,521 |
| | 1,190,299 | 4,795,715 | 1,252,944 | 5,048,111 |

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ | | | | |
| ត្រូវបង់ | 47,813 | 192,639 | - | - |

## 34. ប្រតិបត្តិការ និងសមតុល្យជាមួយសម្ព័ន្ធញាតិ (ត)

### (គ) ឥណទានផ្តល់ដល់អ្នកគ្រប់គ្រងសំខាន់ៗ និងចំណូលការប្រាក់

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានផ្តល់ដល់អ្នកគ្រប់គ្រងសំខាន់ៗ | 566,203 | 2,302,181 | 678,673 | 2,726,908 |

ឥណទានផ្តល់ដល់អ្នកគ្រប់គ្រងសំខាន់ៗ មានអត្រាការប្រាក់ 8%ក្នុងមួយឆ្នាំ(2018: 8% ក្នុងមួយឆ្នាំ)។

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណូលការប្រាក់ពីអ្នកគ្រប់គ្រងសំខាន់ៗ | 10,566 | 42,771 | 11,662 | 47,201 |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណូលការប្រាក់ពីអ្នកគ្រប់គ្រងសំខាន់ៗ | 19,288 | 77,711 | 24,261 | 97,748 |

### (ឃ) ប្រាក់បញ្ញើរបស់អ្នកគ្រប់គ្រងសំខាន់ៗ និងចំណាយការប្រាក់

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បញ្ញើរបស់អ្នកគ្រប់គ្រងសំខាន់ៗ | 1,006,374 | 4,091,917 | 1,193,205 | 4,794,298 |

ប្រាក់បញ្ញើរបស់អ្នកគ្រប់គ្រងសំខាន់ៗ ទទួលបានអត្រាការប្រាក់ចាប់ពី 2.5% ទៅ 10% ក្នុងមួយឆ្នាំ (2018: ចាប់ ពី 2.5% ទៅ 10% ក្នុងមួយឆ្នាំ) អាស្រ័យលើរយៈពេល និងរូបិយប័ណ្ណរបស់ប្រាក់បញ្ញើ។

## 34. ប្រតិបត្តិការ និងសមតុល្យជាមួយសម្ព័ន្ធញាតិ (ត)

### (ឃ) ប្រាក់បញ្ញើរបស់អ្នកគ្រប់គ្រងសំខាន់ៗ និងចំណាយការប្រាក់ (ត)

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណាយលើការប្រាក់ផ្តល់ដល់អ្នកគ្រប់គ្រងសំខាន់ៗ | 18,505 | 74,919 | 30,747 | 124,334 |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណាយលើការប្រាក់ផ្តល់ដល់អ្នកគ្រប់គ្រងសំខាន់ៗ | 34,259 | 138,030 | 57,447 | 231,454 |

### (ង) ប្រាក់បញ្ញើរបស់ក្រុមប្រឹក្សាភិបាល និងចំណាយការប្រាក់

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បញ្ញើរបស់ក្រុមប្រឹក្សាភិបាល | 3,759,246 | 15,285,094 | 1,600,485 | 6,430,749 |

ប្រាក់បញ្ញើរបស់ក្រុមប្រឹក្សាភិបាល ទទួលបានអត្រាការប្រាក់ចាប់ពី 2.5% ទៅ 9.7% ក្នុងមួយឆ្នាំ (2018: ចាប់ពី 2.5% ទៅ 9.7% ក្នុងមួយឆ្នាំ) អាស្រ័យលើរយៈពេល និងរូបិយប័ណ្ណរបស់ប្រាក់បញ្ញើ។

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណាយលើការប្រាក់ផ្តល់ដល់ក្រុមប្រឹក្សាភិបាល | 53,903 | 218,307 | 46,531 | 188,209 |

## 34. ប្រតិបត្តិការ និងសមតុល្យជាមួយសម្ព័ន្ធញាតិ (ត)

### (ខ) ប្រាក់បញ្ញើរបស់ក្រុមប្រឹក្សាភិបាល និងចំណាយការប្រាក់ (ត)

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណាយលើការប្រាក់ផ្តល់ដល់ ក្រុមប្រឹក្សាភិបាល | 103,104 | 415,406 | 89,837 | 361,953 |

### (ច) ការជួលការិយាល័យពីអ្នកគ្រប់គ្រងសំខាន់ៗ

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណាយលើការជួលការិយាល័យ | 16,980 | 68,803 | 7,980 | 32,287 |

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| ចំណាយលើការជួលការិយាល័យ | 33,960 | 136,825 | 15,960 | 64,303 |

### (ឆ) ប្រតិបត្តិការ និងសមតុល្យជាមួយនឹងភាគទុនិក និងសម្ព័ន្ធ

#### (i) ប្រតិបត្តិការជាមួយនឹងភាគទុនិក និងសម្ព័ន្ធ

| | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 3ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| <u>ភាគទុនិក</u> | | | | |
| ការទូទាត់សងកម្ចីពីក្រុមហ៊ុនមេ | (2,857,143) | (11,511,429) | (2,857,143) | (11,511,429) |
| សាច់ប្រាក់ទទួលបានពីកម្ចីពីក្រុមហ៊ុនមេ | - | - | 8,000,000 | 32,232,000 |
| ការទូទាត់សងប្រាក់កម្ចីពីក្រុមហ៊ុនមេ | - | - | (10,000,000) | (40,443,000) |
| ចំណាយលើការប្រាក់ និងកម្រៃសេវា | 407,997 | 1,652,416 | 681,139 | 2,758,375 |

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

### 34. ប្រតិបត្តិការ និងសមតុល្យជាមួយសម្ព័ន្ធញាតិ (ត)

### (ឆ) ប្រតិបត្តិការ និងសមតុល្យជាមួយនឹងភាគទុនិក និងសម្ព័ន្ធ (ត)

#### (i) ប្រតិបត្តិការជាមួយនឹងភាគទុនិក និងសម្ព័ន្ធ (ត)

| | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ដំណាច់ការិយបរិច្ឆេទ 6ខែ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (មិនបានត្រួតពិនិត្យ និងធ្វើសវនកម្ម) | |
| **ភាគទុនិក** | | | | |
| ការទូទាត់សងកម្ចីពីក្រុមហ៊ុនមេ | (2,857,143) | (11,511,429) | (2,857,143) | (11,511,429) |
| សាច់ប្រាក់ទទួលបានពីកម្ចីពីក្រុមហ៊ុនមេ | - | - | 8,000,000 | 32,232,000 |
| ការទូទាត់សងប្រាក់កម្ចីពីក្រុមហ៊ុនមេ | - | - | (19,000,000) | (76,551,000) |
| ចំណាយលើការប្រាក់ និងកម្រៃសេវា | 781,727 | 3,149,578 | 1,508,547 | 6,077,936 |

#### (ii) សមតុល្យជាមួយនឹងភាគទុនិក និងសម្ព័ន្ធ

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ភាគទុនិក** | | | | |
| ការប្រាក់ត្រូវទទួលលើអត្រាការប្រាក់ SWAP | 10,663 | 43,356 | 13,747 | 55,235 |
| ទឹកប្រាក់ជំពាក់ចំពោះការទូទាត់របស់ Krungsri ជំនួសឱ្យ អេច ខេ អិល | 879 | 3,574 | 81,380 | 326,985 |
| កម្ចីតាមរយៈ IFC (*) | 41,060 | 166,950 | 14,285,714 | 57,399,999 |
| ការប្រាក់ត្រូវទូទាត់លើកម្ចីតាមរយៈ IFC | 11,428,572 | 46,468,574 | 155,827 | 626,113 |
| កិច្ចសន្យាចំណាយអត្រាការប្រាក់ SWAP (**) | 120,678 | 490,677 | 85,285,714 | 342,677,999 |
| កិច្ចសន្យាទទួលអត្រាការប្រាក់ SWAP (**) | 73,928,571 | 300,593,570 | (85,285,714) | (342,677,999) |
| ការប្រាក់ និងកម្រៃសេវាត្រូវទូទាត់លើកម្ចី | 2,917 | 11,861 | 3,889 | 15,626 |
| ទឹកប្រាក់ត្រូវទទួលចំពោះចំណាយរបស់ Krungsri ដែលអេច ខេ អិល បានទូទាត់ជំនួស | 1,890 | 7,685 | 945 | 3,797 |

## 34. ប្រតិបត្តិការ និងសមតុល្យជាមួយសម្ព័ន្ធញាតិ (ត)

### (ឆ) ប្រតិបត្តិការ និងសមតុល្យជាមួយនឹងភាគទុនិក និងសម្ព័ន្ធ (ត)

### (ii) សមតុល្យជាមួយនឹងភាគទុនិក និងសម្ព័ន្ធ (ត)

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| <u>សម្ព័ន្ធ</u> | | | | |
| ទឹកប្រាក់ជំពាក់ចំពោះការទូទាត់របស់ Ngern Tid Lor Co., Ltd ជំនួសឱ្យ អេច ខេ អិល | 52,840 | 214,847 | 50,054 | 201,117 |

(*) តំណាងឱ្យពហុគណទាន ពី IFC ដែល Krungsri គឺជាម្ចាស់បំណុល ដែលផ្តល់មូនិធិទៅឱ្យ IFC។

(**) នៅថ្ងៃទី12 ខែមករា ឆ្នាំ2017 ក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយ Krungsri សម្រាប់អត្រាការប្រាក់ SWAP ចំនួន 54 លានដុល្លារអាមេរិក មានសុពលភាពចាប់ពីថ្ងៃទី15 ខែឧសភា ឆ្នាំ2017។ នាថ្ងៃទី7 ខែកុម្ភៈ ឆ្នាំ2018 ក្រុមហ៊ុនបានចុះកិច្ចសន្យាមួយទៀតជាមួយ Krungsri សម្រាប់អត្រាការប្រាក់ SWAP ចំនួន 55 លានដុល្លារអាមេរិក មានសុពលភាពចាប់ពីថ្ងៃទី23 ខែកុម្ភៈ ឆ្នាំ2018 ដើម្បីទប់ស្កាត់ហានិភ័យរបស់ក្រុមហ៊ុន ទៅលើអត្រាការប្រាក់ ចំពោះកម្ចីដែលមានអត្រាការប្រាក់ប្រែប្រួល។

## 35. យថាភាព

នៅថ្ងៃទី19 ខែមីនា ឆ្នាំ2019 អគ្គនាយកដ្ឋានពន្ធដារ បានចេញលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ ដែលតម្រូវឱ្យក្រុមហ៊ុនបង់ពន្ធសរុបចំនួន 31,255,677,651 រៀល (ប្រហែល 7.7 លានដុល្លារអាមេរិក) សម្រាប់ឆ្នាំសារពើពន្ធ 2016។

នៅថ្ងៃទី11 ខែមេសា ឆ្នាំ2019 ក្រុមហ៊ុនបានដាក់លិខិតតវ៉ាទៅអគ្គនាយកដ្ឋានពន្ធដារ ដើម្បីជំទាស់ទៅនឹងចំនួនពន្ធដែលបានកំណត់ឡើងវិញ។ ជាលទ្ធផល ក្រុមហ៊ុនបានទទួលលិខិតជូនដំណឹងជាលើកទីពីរស្តីពីការកំណត់ពន្ធ ឡើងវិញ ពីអគ្គនាយកដ្ឋានពន្ធដារនៅថ្ងៃទី9 ខែកក្កដា ឆ្នាំ2019។ អគ្គនាយកដ្ឋានពន្ធដារ បានកំណត់ពន្ធសារជាថ្មី ដែលមានចំនួនសរុប 30,958,899,567 រៀល (ប្រហែល 7.6 លានដុល្លារ អាមេរិក)។ នៅក្នុងដំណាក់កាលនេះ ក្រុមហ៊ុន មិនទាន់បានកត់ត្រាជាសំវិធានធននៅឡើយទេ ពីព្រោះក្រុមហ៊ុនជឿជាក់ថាមានហេតុផលសមរម្យដើម្បីតវ៉ាទៅលើ ការវាយតម្លៃពន្ធនេះ ដោយផ្អែកលើច្បាប់ពន្ធ និងបទប្បញ្ញត្តិផ្សេងៗដូចបានបង្ហាញនៅក្នុងលិខិតតវ៉ា។

នាកាលបរិច្ឆេទរាយការណ៍នេះ ក្រុមហ៊ុនបានជួលអ្នកប្រឹក្សាផ្នែកពន្ធដារ ដើម្បីជួយតវ៉ាជាមួយអគ្គនាយកដ្ឋានពន្ធដារចំពោះបញ្ហាពន្ធនេះ។ លទ្ធផលនៃបំណុលពន្ធចុងក្រោយ មិនទាន់អាចកំណត់បាននៅឡើយទេ។

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមានការទទួលខុសត្រូវជារួម ក្នុងការបង្កើត និងការត្រួតពិនិត្យលើក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការគ្រប់គ្រង ទ្រព្យសកម្ម បំណុល និងហានិភ័យ (ARBC) ដែលទទួលខុសត្រូវក្នុងការអនុម័ត និងត្រួតពិនិត្យ លើគោលនយោបាយគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន។

គោលនយោបាយគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន ត្រូវបានបង្កើតឡើងដើម្បីកំណត់អត្តសញ្ញាណ និងវិភាគហានិភ័យដែលក្រុមហ៊ុនបានជួបប្រទះដើម្បីកំណត់កម្រិតហានិភ័យ និងការត្រួតពិនិត្យឱ្យបានសមស្រប និងដើម្បីតាមដានហានិភ័យ និងការប្រកាន់ខ្ជាប់ទៅនឹងកម្រិតហានិភ័យដែលបានកំណត់។ គោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យត្រូវបានត្រួតពិនិត្យយ៉ាងទៀងទាត់ដើម្បីឆ្លុះបញ្ចាំងការផ្លាស់ប្តូរស្ថានភាពទីផ្សារ និងសកម្មភាពរបស់ក្រុមហ៊ុន។

គោលនយោបាយ និងនីតិវិធីអនុម័តដោយក្រុមហ៊ុន ដើម្បីគ្រប់គ្រងហានិភ័យដែលអាចកើតមានឡើងក្នុងសកម្មភាពអាជីវកម្មក្រុមហ៊ុន មានដូចខាងក្រោម៖

### 36.1 ហានិភ័យឥណទាន

ហានិភ័យឥណទាន សំដៅទៅលើហានិភ័យដែលក្រុមហ៊ុនរងការខាតបង់ផ្នែកហិរញ្ញវត្ថុ ប្រសិនបើសមភាគីខកខានក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា និងការខាតបង់ដែលកើតឡើងពីប្រាក់បញ្ញើជាមួយធនាគារផ្សេងទៀត និងឥណទានផ្តល់ដល់អតិថិជន (រួមទាំងកិច្ចសន្យាឥណទាន)។ ដើម្បីគ្រប់គ្រងហានិភ័យ ក្រុមហ៊ុនបានពិចារណាគ្រប់ផ្នែកទាំងអស់នៃហានិភ័យឥណទាន រួមមានហានិភ័យដែលមិនមានលទ្ធភាពសងហានិភ័យភូមិសាស្ត្រ ហានិភ័យផលិតផល និងហានិភ័យអាជីវកម្ម។

#### 36.1.1 ការគ្រប់គ្រងហានិភ័យឥណទាន

នាយកដ្ឋានហានិភ័យឥណទាន និងហានិភ័យទីផ្សារ ទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យឥណទានដោយ៖

- ការបង្កើតគោលនយោបាយឥណទានដោយមានការពិគ្រោះយោបល់ជាមួយផ្នែកអាជីវកម្ម គ្របដណ្តប់លើតម្រូវការទ្រព្យដាក់ធានា ការវាយតម្លៃឥណទាន ការដាក់ពិន្ទុហានិភ័យ និងការរៀបចំឯកសារ និងនីតិវិធីច្បាប់ដោយស្របទៅតាម CIFRS និងការណែនាំពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា។
- ការបង្កើតរចនាសម្ព័ន្ធក្នុងការអនុម័ត និងការបន្តផ្តល់ឥណទាន។ អ្នកដែលមានសិទ្ធិក្នុងការអនុម័តឥណទានមានដូចជា គណៈកម្មាធិការក្រុមប្រឹក្សាភិបាលឥណទាន គណៈកម្មាធិការគ្រប់គ្រងឥណទាន នាយកដ្ឋានអនុម័តឥណទាន និងប្រធានសាខា មានទំនួលខុសត្រូវក្នុងការអនុម័តឥណទានផ្តល់ដល់អតិថិជន។
- ការពិនិត្យឡើងវិញ និងវាយតម្លៃហានិភ័យឥណទាន ដោយការកំណត់កម្រិតហានិភ័យ និងការប៉ះពាល់ពីហានិភ័យឥណទានទាំងអស់។
- កំណត់ការប៉ះពាល់នៃហានិភ័យឥណទាន ដែលកើតឡើងពីសមភាគី ទីតាំងភូមិសាស្ត្រ ឧស្សាហកម្ម គោលបំណង និងវិស័យផ្សេងៗ (សម្រាប់ឥណទានផ្តល់ដល់អតិថិជននិង ហានិភ័យឥណទានផ្សេងទៀតដែលមានភាពស្រដៀងគ្នា)។

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.1 ហានិភ័យឥណទាន (ត)

#### 36.1.1 ការគ្រប់គ្រងហានិភ័យឥណទាន (ត)

- ការអភិវឌ្ឍន៍ និងការរក្សាបាននូវដំណើរការរបស់ក្រុមហ៊ុនសម្រាប់វាស់វែង ECL ដោយរួមបញ្ចូលទាំងដំណើរការសម្រាប់៖
  - ការអនុម័តលើកដំបូង និងសុពលភាពទៀងទាត់នៃការត្រួតពិនិត្យ និងការវិភាគត្រលប់មកវិញ (back-testing) នៃម៉ូឌែលដែលបានប្រើ
  - ការកំណត់ និងតាមដានការកើនឡើងជាសំខាន់នូវហានិភ័យឥណទាន និង
  - ការរួមបញ្ចូលព័ត៌មានព្យាករណ៍នាពេលអនាគត (forward-looking information)
- ការពិនិត្យឡើងវិញនូវការអនុលោមរបស់សាខានីមួយៗ ទៅតាមការប៉ះពាល់ដែលបានព្រមព្រៀង រួមទាំងកម្រិតហានិភ័យឥណទាន ដែលកើតឡើងពីប្រភេទឧស្សាហកម្ម និងប្រភេទផលិតផល។ របាយការណ៍ដែលបានរៀបចំឡើងជាទៀងទាត់ ស្តីពីគុណភាពឥណទាន អាចតម្រូវឱ្យមានសកម្មភាពកែតម្រូវដ៏សមរម្យ និងរួមបញ្ចូលរបាយការណ៍ពីការប៉ាន់ស្មានលើសំវិធានធន ECL។
- ការផ្តល់អនុសាសន៍ ការណែនាំ និងការផ្តល់ជំនាញឯកទេសដល់សាខា ដើម្បីលើកកម្ពស់ការអនុវត្តកិច្ចការទូទាំងក្រុមហ៊ុន ក្នុងគ្រប់គ្រងហានិភ័យឥណទាន។

សាខានីមួយៗត្រូវអនុវត្តគោលនយោបាយ និងនីតិវិធីឥណទាន ផ្អែកទៅតាមសិទ្ធិអនុម័តឥណទាន ដែលផ្តល់ដោយគណៈកម្មាធិការឥណទាន។ សាខាខ្លះមានអ្នកជំនាញការហានិភ័យឯករាជ្យ ដែលទទួលខុសត្រូវរាយការណ៍មកកាន់ការិយាល័យកណ្តាល លើបញ្ហាពាក់ព័ន្ធនឹងហានិភ័យទាំងអស់។ សាខានីមួយៗទទួលខុសត្រូវចំពោះគុណភាព និងការអនុវត្តសំពៀតឥណទាន និងចំពោះការតាមដាន និងត្រួតពិនិត្យហានិភ័យលើសំពៀតឥណទានទាំងអស់របស់ខ្លួន រួមទាំងឥណទានដែលបានអនុម័តដោយការិយាល័យកណ្តាល។

សវនកម្មផ្ទៃក្នុងបានធ្វើសវនកម្មជាទៀងទាត់ ដើម្បីធានាថាការត្រួតពិនិត្យ និងនីតិវិធីដែលបានបង្កើតឡើងបានរៀបចំ និងអនុវត្តតាមបានគ្រប់គ្រាន់។

#### 36.1.2 ការវិភាគគុណភាពឥណទាន

តារាងខាងក្រោមនេះបង្ហាញព័ត៌មានអំពីគុណភាពឥណទាន នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃដករំលស់។ លុះត្រាតែបានបញ្ជាក់ច្បាស់លាស់ ចំនួនទឹកប្រាក់នៃទ្រព្យសម្បត្តិហិរញ្ញវត្ថុទាំងអស់ នៅក្នុងតារាងតំណាងខាងក្រោមបង្ហាញជាតម្លៃដុល។ សម្រាប់កិច្ចសន្យាឥណទាន ចំនួនទឹកប្រាក់ក្នុងតារាងជាចំនួនទឹកប្រាក់ដែលបានសន្យា។

# 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 36.1 ហានិភ័យឥណទាន (ត)

### 36.1.2 ការវិភាគគុណភាពឥណទាន (ត)

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | | | |
|---|---|---|---|---|---|
| | ដំណាក់កាលទី1 | ដំណាក់កាលទី2 | ដំណាក់កាលទី3 | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **សមតុល្យជាមួយធនាគារផ្សេងទៀត** | | | | | |
| ធម្មតា | 65,194,289 | - | - | 65,194,289 | 265,079,979 |
| សំវិធានធនលើការខាតបង់ | (72,466) | - | - | (72,466) | (294,647) |
| តម្លៃយោង | 65,121,823 | - | - | 65,121,823 | 264,785,332 |
| **ឥណទានផ្តល់ដល់អតិថិជន** | | | | | |
| ធម្មតា | 867,656,136 | - | 14,640 | 867,670,776 | 3,527,949,375 |
| ឃ្លាំមើល | - | 1,019,719 | - | 1,019,719 | 4,146,179 |
| ក្រោមស្តង់ដា | - | - | 1,052,126 | 1,052,126 | 4,277,944 |
| សង្ស័យ | - | - | 1,407,885 | 1,407,885 | 5,724,460 |
| បាត់បង់ | - | - | 1,190,955 | 1,190,955 | 4,842,423 |
| | 867,656,136 | 1,019,719 | 3,665,606 | 872,341,461 | 3,546,940,381 |
| សំវិធានធនលើការខាតបង់ | (2,707,871) | (567,094) | (3,665,606) | (6,940,571) | (28,220,362) |
| **តម្លៃយោង** | 864,948,265 | 452,625 | - | 865,400,890 | 3,518,720,019 |
| **កិច្ចសន្យាឥណទាន** | | | | | |
| ធម្មតា | 1,199,052 | - | - | 1,199,052 | 4,875,345 |
| ឃ្លាំមើល | - | - | - | - | - |
| ក្រោមស្តង់ដា | - | - | - | - | - |
| សង្ស័យ | - | - | 800 | 800 | 3,253 |
| បាត់បង់ | - | - | - | - | - |
| | 1,199,052 | - | 800 | 1,199,852 | 4,878,598 |
| សំវិធានធនលើការខាតបង់ | (25,622) | - | (800) | (26,422) | (107,432) |
| **តម្លៃយោង** | 1,173,430 | - | - | 1,173,430 | 4,771,166 |

# 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 36.1 ហានិភ័យឥណទាន (ត)

### 36.1.2 ការវិភាគគុណភាពឥណទាន (ត)

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | | | | |
|---|---|---|---|---|---|
| | ដំណាក់កាលទី1 | ដំណាក់កាលទី2 | ដំណាក់កាលទី3 | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យជាមួយធនាគារផ្សេងទៀត | | | | | |
| ធម្មតា | 39,632,860 | - | - | 39,632,860 | 159,244,832 |
| សំវិធានធនលើការខាតបង់ | (38,545) | - | - | (38,545) | (154,874) |
| តម្លៃយោង | 39,594,315 | - | - | 39,594,315 | 159,089,958 |
| ឥណទានផ្តល់ដល់អតិថិជន | | | | | |
| ធម្មតា | 743,625,752 | - | 15,247 | 743,640,999 | 2,987,949,534 |
| ឃ្លាំមើល | - | 1,095,277 | - | 1,095,277 | 4,400,824 |
| ក្រោមស្តង់ដា | - | - | 1,540,099 | 1,540,099 | 6,188,118 |
| សង្ស័យ | - | - | 2,329,353 | 2,329,353 | 9,359,340 |
| បាត់បង់ | - | - | 1,506,228 | 1,506,228 | 6,052,024 |
| | 743,625,752 | 1,095,277 | 5,390,927 | 750,111,956 | 3,013,949,840 |
| សំវិធានធនលើការខាតបង់ | (2,264,386) | (617,615) | (5,390,927) | (8,272,928) | (33,240,625) |
| **តម្លៃយោង** | 741,361,366 | 477,662 | - | 741,839,028 | 2,980,709,215 |
| កិច្ចសន្យាឥណទាន | | | | | |
| ធម្មតា | 1,113,830 | - | - | 1,113,830 | 4,475,369 |
| ឃ្លាំមើល | - | - | - | - | - |
| ក្រោមស្តង់ដា | - | - | 800 | 800 | 3,214 |
| សង្ស័យ | - | - | - | - | - |
| បាត់បង់ | - | - | - | - | - |
| | 1,113,830 | - | 800 | 1,114,630 | 4,478,583 |
| សំវិធានធនលើការខាតបង់ | (2,799) | - | (800) | (3,599) | (14,461) |
| **តម្លៃយោង** | 1,111,031 | - | - | 1,111,031 | 4,464,122 |

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.1 ហានិភ័យឥណទាន (ត)

### 36.1.2 ការវិភាគគុណភាពឥណទាន (ត)

តារាងខាងក្រោមនេះបង្ហាញព័ត៌មានអំពីស្ថានភាពការហួសកាលកំណត់សង នៃឥណទានផ្តល់ដល់អតិថិជននៅដំណាក់កាលទី1 ទី2 និងទី3។

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | | | |
|---|---|---|---|---|---|
| | ដំណាក់កាលទី1 | ដំណាក់កាលទី2 | ដំណាក់កាលទី3 | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **ឥណទានផ្តល់ដល់អតិថិជន** | | | | | |
| ពេលបច្ចុប្បន្ន | 866,215,299 | 323,634 | 175,753 | 866,714,686 | 3,524,061,912 |
| ហួសកំណត់ ≤ 30ថ្ងៃ | 1,440,837 | 26,868 | 23,427 | 1,491,132 | 6,062,943 |
| ហួសកំណត់ > 30ថ្ងៃ | - | 669,217 | 3,466,426 | 4,135,643 | 16,815,526 |
| **សរុប** | 867,656,136 | 1,019,719 | 3,665,606 | 872,341,461 | 3,546,940,381 |

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | | | | |
|---|---|---|---|---|---|
| | ដំណាក់កាលទី1 | ដំណាក់កាលទី2 | ដំណាក់កាលទី3 | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **ឥណទានផ្តល់ដល់អតិថិជន** | | | | | |
| ពេលបច្ចុប្បន្ន | 743,309,047 | 724,925 | 561,895 | 744,595,867 | 2,991,786,194 |
| ហួសកំណត់ ≤ 30ថ្ងៃ | 316,705 | 5,089 | 7,326 | 329,120 | 1,322,405 |
| ហួសកំណត់ > 30ថ្ងៃ | - | 365,263 | 4,821,706 | 5,186,969 | 20,841,241 |
| **សរុប** | 743,625,752 | 1,095,277 | 5,390,927 | 750,111,956 | 3,013,949,840 |

### 36.1.3 ទ្រព្យដាក់ធានា

**ឥណទានលក់រាយសហគ្រាសខ្នាតតូច និងមធ្យម និងឥណទានគេហដ្ឋាន (ឥណទានមានសុវត្ថិភាព)**

ក្រុមហ៊ុនទទួលបានប្លង់លំនៅដ្ឋានជាទ្រព្យដាក់ធានាសម្រាប់ឥណទានភាគច្រើន។ ទ្រព្យដាក់ធានា រួមមាន ដី ផ្ទះ អគារ និងទ្រព្យសកម្មចល័តផ្សេងៗទៀត។ ក្រុមហ៊ុនកំណត់អនុបាតឥណទានធៀបតម្លៃទ្រព្យដាក់ធានា LTV > 67% ជាអនុបាតអប្បបរមា ក្នុងការផ្តល់ឥណទានដល់អតិថិជន។

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.1 ហានិភ័យឥណទាន (ត)

### 36.1.4 ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL

(ក) សមាសធាតុ ការសន្មត់ និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃការថយចុះតម្លៃ

ក្រុមហ៊ុនបានទទួលស្គាល់សំវិធានធនលើការបាត់បង់ ECL ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- សមតុល្យជាមួយធនាគារនានា
- ឧបករណ៍ហិរញ្ញវត្ថុជាបំណុល
- កិច្ចសន្យាឥណទាន

ចំពោះការវិនិយោគក្នុងឧបករណ៍ហិរញ្ញវត្ថុជាទ្រព្យម្ចាស់ គឺមិនត្រូវបានធ្វើការវាយតម្លៃលើការបាត់បង់នោះទេ។

ក្រុមហ៊ុនវាស់វែងសំវិធានធនលើការបាត់បង់ តាមចំនួនដែលស្មើនឹង ECL លើកលែងតែការវាស់វែងតាម ECL 12 ខែ (12-month ECL) ដូចខាងក្រោម៖

- សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា ដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាបនាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលហានិភ័យឥណទានមិនបានកើនឡើងខ្លាំង ចាប់តាំងពីការទទួលស្គាល់លើកដំបូង។

ក្រុមហ៊ុនមិនបានអនុវត្តការលើកលែងឥណទានមានហានិភ័យទាប ចំពោះឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតទេ។

ECL 12ខែ គឺជាផ្នែកនៃ ECL ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល 12ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ELC 12ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី1"។

ECL មួយអាយុកាល (Lifetime ECL) គឺជា ECL ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ ក្នុងរយៈពេលនៃអាយុកាលរំពឹងទុក (expected life) នៃឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ECL ពេញមួយអាយុកាល ប៉ុន្តែមិនមែនជាឥណទានថយចុះ (credit-impaired) ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី2"។

<u>ទ្រព្យសកម្មហិរញ្ញវត្ថុមានការថយចុះតម្លៃ</u>

តាមកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកត់ត្រាតាមតម្លៃដករំលស់ (amortised cost) ហើយមានការថយចុះតម្លៃ ត្រូវបានចាត់ទុកជា "ទ្រព្យសកម្មហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី3"។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាមាន "ការថយចុះតម្លៃ" នៅពេលមានព្រឹត្តិការណ៍មួយ ឬច្រើន បានកើតឡើង ដែលនាំឱ្យមានផលប៉ះពាល់អវិជ្ជមានដល់លំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុក នៃទ្រព្យសម្បត្តិហិរញ្ញវត្ថុ។

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.1 ហានិភ័យឥណទាន (ត)

### 36.1.4 ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL (ត)

<u>ទ្រព្យសកម្មហិរញ្ញវត្ថុមានការថយចុះតម្លៃ</u> (ត)

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសម្បត្តិហិរញ្ញវត្ថុមានការថយចុះតម្លៃ រួមបញ្ចូលនូវទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទានដល់អតិថិជន ដែលក្រុមហ៊ុនមិនយល់ព្រម
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី

ឥណទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អតិថិជន ត្រូវបានចាត់ទុកជាឥណទានមានការថយចុះតម្លៃ លុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យា បានថយចុះជាសំខាន់ និងមិនមានសូចនាករផ្សេងទៀតដែលនាំឱ្យមានការថយចុះតម្លៃ។ ផ្អែកទៅតាមការសន្មត់ដែលអាចបដិសេធបាន នៃស្តង់ដា CIFRS ឥណទានដែលហួសកាលកំណត់សង 90ថ្ងៃ ត្រូវបានចាត់ទុកជាឥណទានមានការថយចុះតម្លៃ ទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ។

ផ្អែកតាមប្រព័ន្ធចាត់ថ្នាក់ហានិភ័យឥណទានរបស់ក្រុមហ៊ុន ឥណទានផ្តល់ដល់អតិថិជនដែលចាត់ទុកថាមានការថយចុះតម្លៃ ជាឥណទានទាំងឡាយណាដែលមានចំណាត់ថ្នាក់ ក្រោមស្តង់ដា សង្ស័យ និងបាត់បង់។

<u>ការចាត់ថ្នាក់ហានិភ័យឥណទាន</u>

ក្រុមហ៊ុនបានបែងចែកការប៉ះពាល់ទៅតាមការចាត់ថ្នាក់ហានិភ័យឥណទាន ស្របទៅតាមនិយមន័យរបស់ធនាគារជាតិនៃកម្ពុជា ដោយផ្អែកទៅតាមចំនួនថ្ងៃនៃការហួសកំណត់សង ដែលជាលក្ខណៈវិនិច្ឆ័យដោយប្រុងប្រយ័ត្ន ដូចខាងក្រោម៖

1. ធម្មតា
2. ឃ្លាំមើល
3. ក្រោមស្តង់ដា
4. សង្ស័យ
5. បាត់បង់

ការប៉ះពាល់ត្រូវបានតាមដានជាប្រចាំ ដែលការប៉ះពាល់អាចធ្វើឱ្យមានការផ្លាស់ប្តូរដល់ការចាត់ថ្នាក់ហានិភ័យឥណទាន។ ជាទូទៅ ការតាមដាននេះជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ទិន្នន័យដូចខាងក្រោម៖

- ប្រវត្តិទូទាត់សង
- ស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី
- ចក្ខុវិស័យអាជីវកម្ម និងការព្យាករណ៍លំហូរសាច់ប្រាក់
- លទ្ធភាព និងឆន្ទៈទូទាត់សង
- ស្ថានភាពសេដ្ឋកិច្ច និង
- គុណភាពនៃសំណុំឯកសារ

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.1 ហានិភ័យឥណទាន (ត)

### 36.1.4 ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL (ត)

*(i) ការកើនឡើងជាសំខាន់នូវហានិភ័យឥណទាន*

ក្រុមហ៊ុនពិចារណាអំពីការកើនឡើងជាសំខាន់នូវហានិភ័យឥណទានជាពីរដំណាក់កាលដូចខាងក្រោម៖

*<u>ការកើនឡើងជាសំខាន់នូវហានិភ័យឥណទានស្ថិតក្នុងដំណាក់កាលទី2</u>*

ការផ្លាស់ប្តូរកម្រិតនៃហានិភ័យឥណទានទៅលើអាយុកាលដែលរំពឹងទុក នៃឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃតាមរយៈការប្រៀបធៀបហានិភ័យឥណទានតាមកាលបរិច្ឆេទរាយការណ៍នីមួយៗ ជាមួយនឹងហានិភ័យឥណទាន នៃឧបករណ៍ហិរញ្ញវត្ថុនៅពេលទទួលស្គាល់លើកដំបូង។ ការវាស់វែងទៅលើគុណភាព និងបរិមាណក្នុងការកំណត់ថាតើ ការកើនឡើងជាសំខាន់នូវហានិភ័យឥណទានដែលបានកើតឡើង ត្រូវបានបង្ហាញដូចខាងក្រោម៖

- ការខកខានសងចំនួន 30ថ្ងៃ ជាបង្គោល (backstop)
- ការប្រើសូចនាករបរិមាណ (ការផ្លាស់ប្តូរ PD នាកាលបរិច្ឆេទរាយការណ៍ចាប់ពីកាលបរិច្ឆេទដើម)

ក្រុមហ៊ុនប្រើប្រាស់ការខកខានសងចំនួន 30ថ្ងៃ ជាបង្គោល និងអនុវត្តការសន្មត់ដែលអាចបដិសេធបាន ដោយកំណត់ថាហានិភ័យឥណទានលើទ្រព្យសម្បត្តិហិរញ្ញវត្ថុ បានកើនឡើងជាសំខាន់ចាប់តាំងពីការទទួលស្គាល់លើកដំបូង នៅពេលដែលការទូទាត់តាមកិច្ចសន្យា មានការខកខានសងលើសពី 30ថ្ងៃ។ លើសពីនេះទៀត ឥណទានផ្តល់ដល់អតិថិជនដែលត្រូវបានរៀបចំឡើងវិញ និងត្រូវបានចាត់ថ្នាក់ក្នុង ឃ្លាំមើល ត្រូវបានផ្លាស់ប្តូរពីដំណាក់កាលទី1 ទៅដំណាក់កាលទី2។

*<u>ការកើនឡើងជាសំខាន់នូវហានិភ័យឥណទានស្ថិតក្នុងដំណាក់កាលទី3</u>*

ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានចាត់ទុកជាឥណទានមានការថយចុះតម្លៃចាប់តាំងពីពេលដំបូង ឬពីពេលទិញ ត្រូវចាត់ថ្នាក់ដោយស្វ័យប្រវត្តិ ជាឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី3។ ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានការថយចុះតម្លៃ ដោយផ្អែកទៅតាមទិន្នន័យដែលអាចអង្កេតបានទាក់ទងទៅនឹងព្រឹត្តិការណ៍ដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដោយសារតែបញ្ហាហិរញ្ញវត្ថុ ដូចជាស្ថានភាពជំនួញកូនបំណុលស្ថិតក្នុងដំណើរការវិវាទ ភាពញឹកញាប់នៃការរៀបចំបំណុលឡើងវិញជាដើម។
- កូនបំណុលដែលក្លែងបន្លំ
- ការលក់ ឬការលុបដោយចោលឥណទានខូចដោយផ្អែក
- មរណៈភាព
- ការរៀបចំឡើងវិញនូវបំណុលដែលមានបញ្ហា (Trouble Debt Restructuring) ដោយមិនជោគជ័យ

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.1 ហានិភ័យឥណទាន (ត)

### 36.1.4 ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL (ត)

*(i) ការកើនឡើងជាសំខាន់នូវហានិភ័យឥណទាន (ត)*

ក្រុមហ៊ុនបានអនុវត្តការខកខានសងចំនួន 90ថ្ងៃ ជាបង្គោល ក្នុងការផ្លាស់ប្តូរឧបករណ៍ហិរញ្ញវត្ថុ ពីដំណាក់កាលទី2 ទៅដំណាក់កាលទី3 និងចាត់ទុកឧបករណ៍ហិរញ្ញវត្ថុនោះថាមានការថយចុះតម្លៃ។ លើសពីនេះទៀត ឥណទានផ្តល់ដល់អតិថិជនដែលត្រូវបានរៀបចំឡើងវិញ និងបានចាត់ថ្នាក់ក្នុង ក្រោមស្តង់ដា សង្ស័យ និងបាត់បង់ ត្រូវបានផ្លាស់ប្តូរពីដំណាក់កាលទី2 ទៅដំណាក់កាលទី3។

*(ii) និយមន័យនៃការខកខានសង*

ក្រុមហ៊ុនចាត់ទុកទ្រព្យសម្បត្តិហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុងមកវិញ ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- អ្នកខ្ចីមានការខកខានសងច្រើនជាង 90ថ្ងៃ លើកាតព្វកិច្ចសងឥណទានមកក្រុមហ៊ុនជាសារវន្ត ឬ
- អ្នកខ្ចីនឹងកែសំរួលទ្រព្យសម្បត្តិរបស់ខ្លួនដែលជាលទ្ធផលនៃការក្ស័យធន ដោយសារមិនមានលទ្ធភាពសងកាតព្វកិច្ចឥណទានរបស់ខ្លួន។

*(iii) ការបញ្ចូលព័ត៌មានព្យាករណ៍នាពេលអនាគត*

ក្រុមហ៊ុនវិភាគព័ត៌មានព្យាករណ៍នាពេលអនាគត ដោយប្រើម៉ូឌែលស្ថិតិនៃនិន្នាការនាពេលអនាគត ក្នុងការវាយតម្លៃថាតើហានិភ័យឥណទានលើឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើងជាសំខាន់ ដើម្បីធ្វើការវាស់វែង ECL។

ក្រុមហ៊ុនបានបង្កើតសេណារីយ៉ូសេដ្ឋកិច្ចចំនួនបី៖ កម្រិតមូលដ្ឋាន ដែលជាសេណារីយ៉ូមធ្យម ត្រូវបានផ្តល់ 65.92% នៃប្រូបាប៊ីលីតេនៃការកើតឡើង និងសេណារីយ៉ូពីរទៀតដែលមានប្រូបាប៊ីលីតេនៃការកើតឡើងតិចតួចចំនួន 17.04% សម្រាប់សេណារីយ៉ូនីមួយៗ (មួយជាកម្រិតឡើង និងមួយទៀតជាកម្រិតចុះ)។ កម្រិតមូលដ្ឋាននេះ មានភាពស៊ីសង្វាក់ជាមួយនឹងពត៌មាន ដែលបានប្រើប្រាស់ដោយក្រុមហ៊ុនសម្រាប់គោលបំណងផ្សេងទៀត ដូចជាការរៀបចំផែនការយុទ្ធសាស្ត្រ និងគំរោងថវិកា។ ព័ត៌មានខាងក្រៅត្រូវបានពិចារណា ដោយរួមបញ្ចូលទិន្នន័យសេដ្ឋកិច្ច និងការព្យាករណ៍ផ្សេងៗ ដែលបានចេញផ្សាយដោយស្ថាប័នរដ្ឋាភិបាល និងអាជ្ញាធររូបិយវត្ថុនៅក្នុងប្រទេសដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ និងដែលបានចេញដោយស្ថាប័នអន្តរជាតិ ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ។

ក្រុមហ៊ុនបានកំណត់អត្តសញ្ញាណ និងកត់ត្រានូវកត្តាជម្រុញសំខាន់ៗនៃហានិភ័យឥណទាន និងការខាតបង់ឥណទានសម្រាប់សំពៀតឧបករណ៍ហិរញ្ញវត្ថុនីមួយៗ ដោយប្រើប្រាស់ការវិភាគប្រវត្តិទិន្នន័យអតីតកាល ព្រមទាំងបានធ្វើការព្យាករណ៍នូវទំនាក់ទំនងរវាងកត្តាប្រែប្រួលម៉ាក្រូសេដ្ឋកិច្ច ជាមួយហានិភ័យឥណទាន និងការខាតបង់ឥណទាន។

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.1 ហានិភ័យឥណទាន (ត)

### 36.1.4 ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL (ត)

*(iii) ការបញ្ចូលព័ត៌មានព្យាករណ៍នាពេលអនាគត (ត)*

កត្តាជម្រុញសំខាន់សម្រាប់ហានិភ័យសំពៀតឥណទាន រួមមាន អត្រាផលិតផលក្នុងស្រុកសរុប (GDP) ក្នុងមនុស្សម្នាក់គិតជាដុល្លារអាមេរិក អត្រាប្តូរប្រាក់ និងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI)។ ផ្អែកលើការវិភាគការសម្របសម្រួល ក្រុមហ៊ុនបានសម្រេចប្រើប្រាស់ GDP ក្នុងមនុស្សម្នាក់គិតជាដុល្លារអាមេរិក ទៅក្នុងម៉ូឌែល។

| GDP ក្នុងមនុស្សម្នាក់គិតជាដុល្លារអាមេរិក | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|
| កម្រិតដើម | 1520 | 1593 | 1667 | 1740 | 1814 |
| កម្រិតឡើង | 1791 | 1877 | 1964 | 2051 | 2138 |
| កម្រិតចុះ | 1482 | 1554 | 1626 | 1698 | 1769 |

យោងតាមការវិភាគព័ត៌មានព្យាករណ៍នាពេលអនាគត ផលប៉ះពាល់នៃម៉ាក្រូសេដ្ឋកិច្ចទៅលើការគណនា ECL គឺមានចំនួនតិចតួចបំផុត ដូច្នេះក្រុមហ៊ុនបានសម្រេចបញ្ចូលនូវការកែប្រែ សូន្យភាគរយ (0%) ទៅក្នុង PD ព្យាករណ៍នាពេលអនាគត។

*(iv) ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ*

ក្រុមហ៊ុនធ្វើការចរចាឡើងវិញនូវឥណទានផ្តល់ដល់អតិថិជនដែលមានផលលំបាកផ្នែកហិរញ្ញវត្ថុ (សំដៅដល់សកម្មភាពរៀបចំឥណទានឡើងវិញ) ដើម្បីបង្កើនឱកាសអតិបរិមាក្នុងការប្រមូលត្រលប់វិញ និងកាត់បន្ថយហានិភ័យនៃការខកខានសង។ ផ្អែកទៅតាមគោលនយោបាយរបស់ក្រុមហ៊ុន ឥណទានរៀបចំឡើងវិញ ត្រូវបានផ្តល់ជូនដោយផ្អែកលើមូលដ្ឋានជ្រើសរើស ប្រសិនបើកូនបំណុលមានការខកខានសងនាពេលបច្ចុប្បន្ន ឬប្រសិនបើមានហានិភ័យ ខ្ពស់នៃការខកខានសង និងមានភស្តុតាងបង្ហាញថាកូនបំណុលពិតជាបានខិតខំប្រឹងប្រែងសងទូទាត់បំណុលទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាដើម និងរំពឹងថាកូនបំណុលនឹងអាចបំពេញតាមលក្ខខណ្ឌដែលបានកែប្រែ។ លក្ខខណ្ឌដែលបានកែប្រែ ជាធម្មតារួមបញ្ចូលទាំងការពន្យារពេលកំណត់ ការផ្លាស់ប្តូររយៈពេលនៃការទូទាត់សងការប្រាក់ និងការកែប្រែលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឥណទាន។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ ទៅតាមគោលនយោបាយនៃការរៀបចំឥណទានឡើងវិញរបស់ក្រុមហ៊ុន ការព្យាករណ៍ PD ឆ្លុះបញ្ចាំងការកែប្រែត្រូវបានកែលម្អ ឬស្តារឡើងវិញនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការប្រមូលការប្រាក់ និងប្រាក់ដើម ទៅតាមបទពិសោធន៍ក្រុមហ៊ុនធ្លាប់មាន។ ជាផ្នែកមួយនៃដំណើរការនេះ ក្រុមហ៊ុនធ្វើការវាយតម្លៃលទ្ធភាពទូទាត់សងរបស់កូនបំណុល ធៀបទៅនឹងលក្ខខណ្ឌកិច្ចសន្យាដែលបានកែប្រែ និងពិចារណាទៅលើសូចនាករអាកប្បកិរិយាជាច្រើនផ្សេងទៀត។

ជាទូទៅការរៀបចំឡើងវិញ គឺជាសូចនាករគុណភាពនៃការកើនឡើងជាសំខាន់នូវហានិភ័យឥណទាន ដែលការរៀបចំឡើងវិញត្រូវបានចាត់ទុកថាមានភស្តុតាងដែលបញ្ជាក់ពីផលប៉ះពាល់នៃឥណទានមានការថយចុះតម្លៃ។ អតិថិជនត្រូវបង្ហាញឥរិយាបថបង់ប្រាក់ល្អជាប់លាប់ក្នុងរយៈពេលមួយ មុនពេលដែលការប៉ះពាល់មិនត្រូវបានចាត់ទុកថាមានការថយចុះតម្លៃ/មិនមានលទ្ធភាពសង ឬ PD ត្រូវបានចាត់ទុកថាបានថយចុះ ដោយសមវិធានធនការខាតបង់ត្រូវបានវាស់វែងតាមចំនួនទឹកប្រាក់ដូចក្នុងដំណាក់កាលទី1។

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.1 ហានិភ័យឥណទាន (ត)

### 36.1.4 ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL (ត)

*(v) ការវាស់វែង ECL*

ECL គឺជាការប៉ាន់ស្មានប្រូបាប៊ីលីតេទម្ងន់នៃការបាត់បង់ឥណទាន។ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានការថយចុះតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលជំពាក់ក្រុមហ៊ុនស្របតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលក្រុមហ៊ុនរំពឹងទុកថានឹងទទួលបាន)។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការថយចុះតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃដុល និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងទុកនាពេលអនាគត។
- កិច្ចសន្យាឥណទានដែលនៅសល់៖ ការខាតបង់ឥណទានគឺជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជំពាក់ក្រុមហ៊ុន ប្រសិនបើអ្នកកាន់កាប់កិច្ចសន្យាឥណទានបានដកឥណទានប្រើ និងលំហូរសាច់ប្រាក់ដែលរំពឹងនឹងទទួលបាន ប្រសិនបើឥណទានត្រូវបានដកប្រើ។

ក្រុមហ៊ុនគណនា ECL ដោយយកតម្លៃដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ គុណនឹង PD សរុប ពី ប្រូតេស្តម៉ូឌែល (Proxy Model) ទៅតាមដំណាក់កាលនីមួយៗ ជាមួយកត្តាកែតម្រូវហានិភ័យមួយចំនួន។

- ការខាតបង់ឥណទានដែលរំពឹងទុក (Expected Credit Loss ឬ ECL) គឺជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ក្នុងរយៈអាយុកាលដែលនៅសល់ ដោយប្រើអប្បហារ EIR។ សម្រាប់ឆ្នាំនីមួយៗនៃអាយុកាលពេញរបស់ឧបករណ៍ហិរញ្ញវត្ថុ ក្រុមហ៊ុនបានធ្វើការប៉ាន់ស្មានលើ PD ដែលបានបញ្ចូលការព្យាករណ៍នាពេលអនាគត LGD និង EAD។ ការប៉ាន់ស្មានត្រូវបានយកមកគុណជាមួយគ្នា ដើម្បីធ្វើការប៉ាន់ស្មានការខាតបង់សម្រាប់រយៈពេលនីមួយៗ។ បន្ទាប់មកការប៉ាន់ស្មានត្រូវបានធ្វើអប្បហារត្រលប់មកក្នុងកាលបរិច្ឆេទរាយការណ៍ ដោយប្រើ EIR ជាអត្រាការប្រាក់អប្បហារ។
- ក្រុមហ៊ុនបានដាក់ឱ្យប្រើប្រាស់ឥណទានខ្នាតតូចនិងមធ្យម និងឥណទានគេហដ្ឋាន ដើម្បីជាសំពៀតឥណទានគម្រូ ដោយសារមានចរិតលក្ខណៈដូចគ្នា។ ឥណទានទាំងនេះ ជាឥណទានរយៈពេលដែលមានកាលវសានកំណត់ និងកាលបរិច្ឆេទកំណត់ក្នុងការសងប្រាក់ដើម និងការប្រាក់។
- ECL ត្រូវបានគណនាដោយប្រើរូបមន្តខាងក្រោម៖

| ដំណាក់កាល | ការគណនា ECL ផ្អែកលើ Proxy |
|---|---|
| 1 | សរុបតម្លៃដុល$_{\text{ដំណាក់កាលទី1}}$ × អនុបាតក្របខ័ណ្ឌ$_{\text{ដំណាក់កាលទី1}}$ × ការកែតម្រូវហានិភ័យ$_{\text{ដំណាក់កាលទី1}}$ |
| 2 | សរុបតម្លៃដុល$_{\text{ដំណាក់កាលទី2}}$ × អនុបាតក្របខ័ណ្ឌ$_{\text{ដំណាក់កាលទី2}}$ × ការកែតម្រូវហានិភ័យ$_{\text{ដំណាក់កាលទី2}}$ |
| 3 | សរុបតម្លៃដុល$_{\text{ដំណាក់កាលទី3}}$ × អនុបាតក្របខ័ណ្ឌ$_{\text{ដំណាក់កាលទី3}}$ × ការកែតម្រូវហានិភ័យ$_{\text{ដំណាក់កាលទី3}}$ |

អនុបាតក្របខ័ណ្ឌរួមមាន PD និង LGD ដែល PD យកមកអនុវត្តត្រូវបានផ្អែកលើ % ECL មកពីក្រុមហ៊ុនមេ។ វាត្រូវបានគណនាដោយប្រើរូបមន្តខាងក្រោម៖

PD យកមកអនុវត្ត = ចំនួន ECL / (EAD x LGD%)

ECL ត្រូវបានគណនាពីក្រុមហ៊ុនមេ ដោយមានការពិចារណាទៅលើតម្លៃនៃពេលវេលា។

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.1 ហានិភ័យឥណទាន (ត)

### 36.1.4 ចំនួនទឹកប្រាក់ដែលកើតឡើងពី ECL (ត)

#### (ខ) ការបាត់បង់នៃសំវិធានធន

តារាងខាងក្រោមនេះសង្ខេបសំវិធានលើការបាត់បង់នាកាលបរិច្ឆេទចុងគ្រា/ចុងឆ្នាំ ទៅតាមថ្នាក់នៃការប៉ះពាល់/ទ្រព្យសកម្មនីមួយៗ។

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ការខាតបង់តាមថ្នាក់ | | | | |
| សមតុល្យនៅធនាគារនានា | 72,466 | 294,647 | 38,545 | 154,874 |
| ឥណទានផ្តល់ដល់អតិថិជន | 6,940,571 | 28,220,362 | 8,272,928 | 33,240,625 |
| កិច្ចសន្យាឥណទាន | 26,422 | 107,432 | 3,599 | 14,461 |
| | 7,039,459 | 28,622,441 | 8,315,072 | 33,409,960 |

ទឹកប្រាក់ជាប់កិច្ចសន្យានៃទ្រព្យសម្បត្តិហិរញ្ញវត្ថុ ដែលត្រូវបានលុបចោលក្នុងអំឡុងពេលនៃរបាយការណ៍ និងនៅតែស្ថិតក្រោមការអនុវត្តច្បាប់គឺមានចំនួន 1,961,179 ដុល្លារអាមេរិក នាថ្ងៃទី30 ខែមិថុនា ឆ្នាំ 2019។

ក្រោមនីតិវិធីត្រួតពិនិត្យរបស់ក្រុមហ៊ុន ការកើនឡើងជាសំខាន់នូវហានិភ័យឥណទានត្រូវបានកំណត់ មុនពេលមានការប៉ះពាល់និងនៅចុងបញ្ចប់នៅពេលដែលការប៉ះពាល់កើតឡើងដល់30ថ្ងៃ។ នេះគឺជាករណីចម្បងសម្រាប់ការផ្តល់ឥណទានដល់អតិថិជន។ តារាងខាងក្រោមផ្តល់នូវការវិភាគទៅលើចំនួនសរុបនៃឥណទានផ្តល់ដល់អតិថិជន តាមកាលកំណត់ដែលមានកន្លងមក។

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | សរុបតម្លៃយោង | ការខាតបង់ | សរុបតម្លៃយោង | ការខាតបង់ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ឥណទានផ្តល់ដល់អតិថិជន** | | | | |
| 0-29 ថ្ងៃ | 868,205,818 | 3,102,170 | 744,924,987 | 3,245,387 |
| 30-59 ថ្ងៃ | 411,250 | 235,205 | 129,561 | 81,559 |
| 60-89 ថ្ងៃ | 275,532 | 162,187 | 351,872 | 240,446 |
| 90-180 ថ្ងៃ | 933,684 | 925,832 | 995,317 | 995,317 |
| ច្រើនជាង 180ថ្ងៃ | 2,515,177 | 2,515,177 | 3,710,219 | 3,710,219 |
| សរុប | 872,341,461 | 6,940,571 | 750,111,956 | 8,272,928 |
| សមមូលជាពាន់រៀល | 3,546,940,381 | 28,220,362 | 3,013,949,840 | 33,240,625 |

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.1 ហានិភ័យឥណទាន (ត)

#### 36.1.5 ការផ្តោតលើហានិភ័យឥណទាន

ក្រុមហ៊ុនបានធ្វើការត្រួតពិនិត្យការផ្តោតលើហានិភ័យឥណទានតាមវិស័យនីមួយៗ។ ការវិភាគការផ្តោតលើហានិភ័យឥណទានផ្តល់ដល់អតិថិជន និងកិច្ចសន្យាឥណទាន ត្រូវបានបង្ហាញនៅក្នុងតារាងដូចខាងក្រោម៖

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | | | |
|---|---|---|---|---|---|
| | សមតុល្យនៅធនាគារនានា | ឥណទានផ្តល់ដល់អតិថិជន | កិច្ចសន្យាឥណទាន | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| តម្លៃយោង | 65,121,824 | 865,400,890 | (26,422) | 930,496,292 | 3,783,397,923 |
| ចំនួនទឹកប្រាក់តាមកិច្ចសន្យា | - | - | 1,199,852 | - | - |
| **ការផ្តោតលើហានិភ័យតាមវិស័យ** | | | | | |
| អតិថិជនខាងក្រៅ | | | | | |
| ឥណទានគេហដ្ឋាន | - | 70,637,911 | 312,703 | 70,950,614 | 288,485,195 |
| ឥណទានផ្ទាល់ខ្លួន | - | 789,467,393 | 837,149 | 790,304,542 | 3,213,378,269 |
| ឥណទានបុគ្គលិក | - | 5,295,586 | 50,000 | 5,345,586 | 21,735,153 |
| | - | 865,400,890 | 1,199,852 | 866,600,742 | 3,523,598,617 |

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | | | | |
|---|---|---|---|---|---|
| | សមតុល្យនៅធនាគារនានា | ឥណទានផ្តល់ដល់អតិថិជន | កិច្ចសន្យាឥណទាន | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| តម្លៃយោង | 39,594,315 | 741,839,028 | (3,599) | 781,429,744 | 3,139,784,711 |
| ចំនួនទឹកប្រាក់តាមកិច្ចសន្យា | - | - | 1,114,630 | 1,114,630 | 4,478,583 |
| **ការផ្តោតលើហានិភ័យតាមវិស័យ** | | | | | |
| អតិថិជនខាងក្រៅ | | | | | |
| ឥណទានគេហដ្ឋាន | - | 70,837,551 | 318,751 | 71,156,302 | 285,906,021 |
| ឥណទានផ្ទាល់ខ្លួន | - | 666,212,638 | 718,239 | 666,930,877 | 2,679,728,264 |
| ឥណទានបុគ្គលិក | - | 4,788,839 | 77,640 | 4,866,479 | 19,553,513 |
| | - | 741,839,028 | 1,114,630 | 742,953,658 | 2,985,187,798 |

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.2 ហានិភ័យសន្ទនីយភាព

ហានិភ័យសន្ទនីយភាពសំដៅទៅលើហានិភ័យដែលក្រុមហ៊ុនមិនអាចបំពេញកាតព្វកិច្ចហិរញ្ញវត្ថុ ឬមិនអាចសងបំណុល ឬដោះស្រាយជំហរ ក្នុងស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាក់លាក់ និងស្ថានភាពទីផ្សារ។ ហានិភ័យសន្ទនីយភាពកើតឡើងពីភាពមិនត្រូវគ្នានៃកាលកំណត់ និងបរិមាណលំហូរសាច់ប្រាក់ ដែលមានជាប់ជាមួយប្រតិបត្តិការ និងការវិនិយោគរបស់ក្រុមហ៊ុន។

### 36.2.1 ការគ្រប់គ្រងហានិភ័យសន្ទនីយភាព

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនកំណត់យុទ្ធសាស្រ្ត របស់ក្រុមហ៊ុនក្នុងការគ្រប់គ្រង ហានិភ័យសន្ទនីយភាព និង ការប្រតិបត្តិការ គ្រប់គ្រងដោយARBC។ ARBC អនុម័តលើគោលការណ៍សន្ទនីយភាពរបស់ក្រុមហ៊ុន ដែលបង្កើតឡើងដោយអគ្គនាយកដ្ឋានគ្រប់គ្រងហានិភ័យ និងត្រូវបានទទួលស្គាល់ដោយ ALRMC។ នាយកដ្ឋានរតនាភិបាលគ្រប់គ្រងស្ថានភាពសន្ទនីយភាពរបស់ក្រុមហ៊ុនជារៀងរាល់ថ្ងៃ ហើយពិនិត្យរបាយការណ៍ប្រចាំថ្ងៃដែលគ្របដណ្តប់លើចរន្តសាច់ប្រាក់របស់ការិយាល័យកណ្តាល និងសាខា។ របាយការណ៍សង្ខេបរួម និងការចាត់វិធានការដោះស្រាយត្រូវបានបញ្ចូលយ៉ាងទៀងទាត់នៅក្នុងរបាយការណ៍ ARBC។

វិធីសាស្រ្តរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងលំហូរសាច់ប្រាក់ គឺត្រូវធានាឱ្យបានគ្រប់គ្រាន់តាមលទ្ធភាពដែលអាចធ្វើទៅបាន ថានឹងមានសាច់ប្រាក់គ្រប់គ្រាន់ដើម្បីបំពេញតាមសេចក្តីត្រូវការដោយកម្រិតស្ថិតក្រោមលក្ខខណ្ឌធ្វើយ៉ាងណាមិនឱ្យរងការខាតបង់ និងមិនឱ្យមានការខូចខាតដល់កេរ្តិ៍ឈ្មោះក្រុមហ៊ុន។ ធាតុសំខាន់ៗនៃយុទ្ធសាស្រ្តរបស់ក្រុមហ៊ុនគឺមានដូចខាងក្រោមៈ

- រក្សានូវមូលដ្ឋានហិរញ្ញប្បទានចម្រុះ ដែលរួមមានប្រាក់បញ្ញើរបស់អតិថិជន (ទាំងបុគ្គល និងសហគ្រាស) និងរក្សាយហ្វាស៊ីលីធីយថាភាព។
- អនុវត្តនូវសំពៀតទ្រព្យសកម្មដែលមានសន្ទនីយភាពខ្ពស់ដែលចម្រុះដោយរូបិយប័ណ្ណ និងកាលកំណត់។
- តាមដាននូវភាពមិនស៊ីគ្នានៃកាលកំណត់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងវិសាលភាពដែលទ្រព្យសកម្មរបស់ក្រុមហ៊ុនត្រូវបានជាប់បន្ទុក និងដែលមិនអាចយកទៅប្រើជាវត្ថុបញ្ចាំដើម្បីទទួលហិរញ្ញប្បទានបាន។
- ធ្វើស្រ្តេសតេស្តនូវស្ថានភាពសន្ទនីយភាពរបស់ក្រុមហ៊ុនធៀបនឹងហានិភ័យផ្សេងៗ និងព្រឹត្តិការណ៍ជាក់លាក់របស់ប្រទេស។
- កាត់បន្ថយនូវការបាត់បង់ចំណូលពីសន្ទនីយភាពដែលមិនបានប្រើ។

នាយកដ្ឋានរតនាភិបាលទទួលបានព័ត៌មានពីផ្នែកអាជីវកម្មដទៃទៀត ទាក់ទងនឹងសន្ទនីយភាព នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ និងព័ត៌មានលម្អិតនៃលំហូរសាច់ប្រាក់រំពឹងទុកផ្សេងទៀត ដែលបានពីការព្យាករណ៍អាជីវកម្មនាពេលអនាគត។ បន្ទាប់មកនាយកដ្ឋានរតនាភិបាលបានរក្សានូវសំពៀតនៃសាច់ប្រាក់រយៈពេលខ្លី ដែលភាគច្រើនជាហ្វាស៊ីលីធីអន្តរធនាគារ ដើម្បីធានាថាសាច់ប្រាក់គ្រប់គ្រាន់ត្រូវបានរក្សាទុកនៅក្នុងក្រុមហ៊ុនទាំងមូល។ តម្រូវការសន្ទនីយភាពរបស់សាខា ត្រូវបានបំពេញតាមរយៈមូលនិធិពីនាយកដ្ឋានរតនាភិបាល ដើម្បីជួយសម្រួលដល់ការប្រែប្រួលរយៈពេលខ្លី និងការផ្តល់មូលនិធិរយៈពេលវែង ដើម្បីដោះស្រាយតម្រូវការសាច់ប្រាក់ដែល គ្រោងទុកណាមួយ។

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.2 ហានិភ័យសន្ទនីយភាព (ត)

#### 36.2.1 ការគ្រប់គ្រងហានិភ័យសន្ទនីយភាព (ត)

នាយកដ្ឋានរតនាភិបាលតាមដានជាប្រចាំខែ នូវការអនុលោមតាមដែនកំណត់បទប្បញ្ញត្តិច្បាប់។

ការធ្វើស្ត្រេសតេស្តសន្ទនីយភាព ត្រូវបានធ្វើឡើងនៅក្រោមសេណារីយ៉ូផ្សេងៗ ដែលគ្របដណ្តប់ទាំងលក្ខខណ្ឌទីផ្សារធម្មតា និងធ្ងន់ធ្ងរ។ សេណារីយ៉ូត្រូវបានបង្កើតឡើងដោយពិចារណាលើព្រឹត្តិការណ៍ជាក់លាក់របស់ក្រុមហ៊ុន (ឧទាហរណ៍ ការបន្ទាបចំណាត់ថ្នាក់) និងព្រឹត្តិការណ៍ទាក់ទងនឹងទីផ្សារ (ឧទាហរណ៍ ភាពមិនច្បាស់លាស់លើទីផ្សារ ការកាត់បន្ថយរូបិយប័ណ្ណ គ្រោះមហន្តរាយធម្មជាតិ ឬគ្រោះមហន្តរាយផ្សេងៗទៀត)។ លើសពីនេះទៀត សេណារីយ៉ូភាពតានតឹង អាចផ្អែកលើព្រឹត្តិការណ៍នាពេលកន្លងមក (historical scenario) ដែលបានកត់សម្គាល់ ចំពោះស្ថាប័នផ្ទាល់ ឬទូទៅ លើស្ថានភាពវិបត្តិសេដ្ឋកិច្ចដែលត្រូវបានអង្កេតដោយស្ថាប័នផ្សេងទៀត ដែលមានទំហំ ម៉ូឌែល និងតំបន់អាជីវកម្មស្រដៀងគ្នា។ ជាញឹកញាប់ ក្រុមហ៊ុនក៏បានបញ្ចូលធាតុនៃវិបត្តិនានាពីព្រឹត្តិការណ៍នា ពេលកន្លងមក ដើម្បីបង្កើតជាសម្មតិកម្ម ប៉ុន្តែជាសេណារីយ៉ូវិបត្តិដែលអាចជឿជាក់បាន ដែលសមស្របទៅនឹងម៉ូឌែល អាជីវកម្ម និងទម្រង់ការប៉ះពាល់បច្ចុប្បន្នរបស់ក្រុមហ៊ុន។

#### 36.2.2 ការប៉ះពាល់ពីហានិភ័យសន្ទនីយភាព

ឧបករណ៍សំខាន់ ដែលក្រុមហ៊ុនប្រើប្រាស់សម្រាប់គ្រប់គ្រងហានិភ័យសន្ទនីយភាពគឺ អនុបាតក្របខ័ណ្ឌហានិភ័យសន្ទនីយភាព។ អនុបាតនេះឆ្លុះបញ្ចាំងអំពីលំហូរចូលសាច់ប្រាក់ (រួមមានឥណទានដែលត្រូវប្រមូលសមតុល្យនៅធនាគារនានា) លំហូរចេញសាច់ប្រាក់ក្នុងកំឡុង៣០ថ្ងៃ (រួមមានទឹកប្រាក់ដែលត្រូវទូទាត់ទៅឱ្យអ្នកផ្តល់កម្ចី ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុន) និងប្រាក់បញ្ញើរាយដែលត្រូវបានកែតម្រូវ ព្រមទាំងបរិមាណទ្រព្យសកម្មសន្ទនីយភាពដែលអាចទទួលយកបាន (សាច់ប្រាក់ក្នុងដៃ គណនីចរន្ត និងទុនបម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជា)។

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 |
|---|---|---|
| នាចុងគ្រា/ឆ្នាំ | 144.80% | 177.17% |
| ជាមធ្យមសម្រាប់គ្រា/ឆ្នាំ | 128.83% | 156.52% |
| អតិបរមាសម្រាប់គ្រា/ឆ្នាំ | 144.80% | 238.29% |
| អប្បបរមាសម្រាប់គ្រា/ឆ្នាំ | 100.49% | 115.04% |

#### 36.2.3 ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ

តារាងខាងក្រោមបង្ហាញពីអាយុកាលទៅតាមកិច្ចសន្យាជាក់ស្តែងដែលនៅសល់ នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

# 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 36.2 ហានិភ័យសន្ទនីយភាព (ត)

### 36.2.3 ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

| | តម្លៃយោង | តម្លៃដុល លំហូរចូល/(ចេញ) | រហូតដល់ 1 ខែ | >1–3 ខែ | > 3–12 ខែ | > 1–5 ឆ្នាំ | លើសពី 5 ឆ្នាំ | មិនមានអាយុកាល |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019** | | | | | | | | |
| **បំណុលហិរញ្ញវត្ថុតាមប្រភេទ** | | | | | | | | |
| បំណុលមិនមែននិស្សន្ទ | | | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 574,045,523 | (606,281,944) | (180,491,174) | (97,356,982) | (297,913,212) | (29,723,702) | (796,874) | - |
| មូលបត្របំណុល | 29,122,787 | (35,400,484) | - | - | (2,840,401) | (32,560,083) | - | - |
| ប្រាក់កម្ចី | 241,369,509 | (272,633,828) | (4,608,892) | (6,969,282) | (72,586,396) | (188,216,513) | - | (252,745) |
| អនុបំណុល | 15,548,256 | (18,292,056) | (1,631,172) | (9,141) | (7,238,411) | (8,524,413) | (888,919) | - |
| បំណុលភតិសន្យា | 12,817,656 | (12,817,656) | (207,976) | (411,855) | (1,793,166) | (7,354,768) | (3,049,891) | - |
| បំណុលផ្សេងៗ | 4,767,096 | (4,767,096) | (74,885) | (872,250) | (3,789,278) | (30,683) | - | - |
| | 877,670,827 | (950,193,064) | (187,014,099) | (105,619,510) | (386,160,864) | (266,410,162) | (4,735,684) | (252,745) |
| បំណុលនិស្សន្ទ | | | | | | | | |
| ការគ្រប់គ្រងហានិភ័យ | | | | | | | | |
| លំហូរចេញ | | (504,538) | - | - | (268,376) | (236,162) | - | - |
| លំហូរចូល | | 5,928 | - | - | 5,928 | - | - | - |
| | 902,068 | (498,610) | - | - | (262,448) | (236,162) | - | - |
| កិច្ចសន្យាឥណទាន | - | (1,199,852) | - | - | (1,199,852) | - | - | - |
| សរុប | 878,572,895 | (951,891,526) | (187,014,099) | (105,619,510) | (387,623,164) | (266,646,324) | (4,735,684) | (252,745) |
| សមមូលជាពាន់រៀល | 3,572,277,391 | (3,870,390,945) | (760,399,327) | (429,448,928) | (1,576,075,785) | (1,084,183,953) | (19,255,291) | (1,027,661) |

## ហត្ថាកសិករ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

### 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.2 ហានិភ័យសន្ទនីយភាព (ត)

### 36.2.3 ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

| | តម្លៃយោង | តម្លៃដុល លំហូរចូល/(ចេញ) | រហូតដល់ 1ខែ | >1–3 ខែ | > 3–12ខែ | > 1–5 ឆ្នាំ | លើសពី 5 ឆ្នាំ | មិនមានអាយុកាល |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | | | | | | | |
| ទ្រព្យសកម្មហិរញ្ញវត្ថុតាមប្រភេទ | | | | | | | | |
| ទ្រព្យសកម្មមិនមែននិស្សន្ទ | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 26,268,257 | 26,268,257 | 26,268,257 | - | - | - | - | - |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 74,607,763 | 74,667,456 | 6,903,799 | 5,171,964 | 4,236,918 | - | 58,354,775 | - |
| សមតុល្យនៅធនាគារនានា | 65,121,823 | 65,121,823 | 65,121,823 | - | - | - | - | - |
| ឥណទានផ្តល់ដល់អតិថិជន | 865,400,890 | 1,145,086,716 | 27,880,725 | 62,902,518 | 273,997,997 | 731,787,889 | 45,085,686 | 3,431,901 |
| វិនិយោគលើមូលបត្រ | 20,000 | 20,000 | - | - | - | - | - | 20,000 |
| ទ្រសកម្មផ្សេងៗ | 1,601,192 | 1,601,192 | - | 264,013 | - | 1,337,179 | - | - |
| | 1,033,019,925 | 1,312,765,444 | 126,174,604 | 68,338,495 | 278,234,915 | 733,125,068 | 103,440,461 | 3,451,901 |
| ទ្រព្យសកម្មនិស្សន្ទ | | | | | | | | |
| ការគ្រប់គ្រងហានិភ័យ | | | | | | | | |
| លំហូរចេញ | | - | - | - | - | - | - | - |
| លំហូរចូល | | 7,654 | - | - | 6,203 | 1,451 | - | - |
| | - | 7,654 | - | - | 6,203 | 1,451 | - | - |
| កិច្ចសន្យាទទួលកម្ចី | - | 55,049,188 | - | 5,049,188 | 15,000,000 | - | 35,000,000 | - |
| សរុប | 1,033,019,925 | 1,367,822,286 | 126,174,604 | 73,387,683 | 293,241,118 | 733,126,519 | 138,440,461 | 3,451,901 |
| សមមូលជាពាន់រៀល | 4,200,259,015 | 5,561,565,415 | 513,025,940 | 298,394,319 | 1,192,318,386 | 2,980,892,426 | 562,898,914 | 14,035,429 |

## ហត្ថាកសិករ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

### 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.2 ហានិភ័យសន្ទនីយភាព (ត)

### 36.2.3 ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

| | តម្លៃយោង | តម្លៃដុល លំហូរចូល/(ចេញ) | រហូតដល់ 1 ខែ | >1–3 ខែ | > 3–12 ខែ | > 1–5 ឆ្នាំ | លើសពី 5 ឆ្នាំ | មិនមានអាយុកាល |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | | | | | | | | |
| **បំណុលហិរញ្ញវត្ថុតាមប្រភេទ** | | | | | | | | |
| បំណុលមិនមែននិស្សន្ទ | | | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 491,353,390 | (507,814,922) | (121,805,764) | (93,919,082) | (266,660,080) | (24,635,022) | (794,974) | - |
| មូលបត្របំណុល | 29,325,252 | (37,014,518) | - | - | (2,380,797) | (34,633,721) | - | - |
| ប្រាក់កម្ចី | 191,725,158 | (217,879,268) | (507,657) | (8,058,955) | (59,704,566) | (149,315,267) | - | (292,823) |
| អនុបំណុល | 23,236,296 | (26,732,806) | (401,311) | (1,008,842) | (11,664,455) | (12,742,004) | (916,194) | - |
| បំណុលភតិសន្យា | 13,172,448 | (16,516,948) | (281,810) | (557,744) | (2,393,894) | (9,314,922) | (3,968,578) | - |
| បំណុលផ្សេងៗ | 4,488,231 | (4,488,231) | (260,222) | (781,213) | (3,417,738) | (29,058) | - | - |
| | 753,300,775 | (810,446,693) | (123,256,764) | (104,325,836) | (346,221,530) | (230,669,994) | (5,679,746) | (292,823) |
| បំណុលនិស្សន្ទ | | | | | | | | |
| ការគ្រប់គ្រងហានិភ័យ | | | | | | | | |
| លំហូរចេញ | | - | - | - | - | - | - | - |
| លំហូរចូល | | 341,840 | - | - | 166,695 | 175,145 | - | - |
| | 27,794 | 341,840 | - | - | 166,695 | 175,145 | - | - |
| កិច្ចសន្យាឥណទាន | - | (1,114,630) | - | - | (1,114,630) | - | - | - |
| សរុប | 753,328,569 | (811,219,483) | (123,256,764) | (104,325,836) | (347,169,465) | (230,494,849) | (5,679,746) | (292,823) |
| សមមូលជាពាន់រៀល | 3,024,614,203 | (3,257,046,224) | (494,875,907) | (418,868,232) | (1,393,885,402) | (925,436,819) | (22,804,180) | (1,175,684) |

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.2 ហានិភ័យសន្ទនីយភាព (ត)

#### 36.2.3 ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

| | តម្លៃយោង | តម្លៃដុល លំហូរចូល/(ចេញ) | រហូតដល់ 1ខែ | >1–3 ខែ | > 3–12ខែ | > 1–5 ឆ្នាំ | លើសពី 5 ឆ្នាំ | មិនមានអាយុកាល |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | | | | | | | | |
| ទ្រព្យសកម្មហិរញ្ញវត្ថុតាមប្រភេទ | | | | | | | | |
| ទ្រព្យសកម្មមិនមែននិស្សន្ទ | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 37,211,155 | 37,211,155 | 37,211,155 | - | - | - | - | - |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 77,602,188 | 77,653,503 | 25,808,687 | 4,350,199 | 111,305 | - | 47,383,312 | - |
| សមតុល្យនៅធនាគារនានា | 39,594,315 | 39,644,091 | 31,630,154 | 8,013,937 | - | - | - | - |
| ឥណទានផ្តល់ដល់អតិថិជន | 741,839,028 | 968,005,254 | 24,513,667 | 60,893,663 | 241,959,627 | 616,004,337 | 19,570,437 | 5,063,523 |
| វិនិយោគលើមូលបត្រ | 20,000 | 20,000 | - | - | - | - | - | 20,000 |
| ទ្រព្យសកម្មផ្សេងៗ | 1,504,182 | 1,504,182 | - | 205,338 | - | 1,298,844 | - | - |
| | 897,770,868 | 1,124,038,185 | 119,163,663 | 73,463,137 | 242,070,932 | 617,303,181 | 66,953,749 | 5,083,523 |
| ទ្រព្យសកម្មនិស្សន្ទ | | | | | | | | |
| ការគ្រប់គ្រងហានិភ័យ | | | | | | | | |
| លំហូរចេញ | | - | - | - | - | - | - | - |
| លំហូរចូល | | - | - | - | - | - | - | - |
| | - | - | - | - | - | - | - | - |
| កិច្ចសន្យាទទួលកម្ចី | - | 35,000,000 | - | - | - | - | 35,000,000 | - |
| សរុប | 897,770,868 | 1,159,038,185 | 119,163,663 | 73,463,137 | 242,070,932 | 617,303,181 | 101,953,749 | 5,083,523 |
| សមមូលជាពាន់រៀល | 3,604,550,037 | 4,653,538,313 | 478,442,107 | 294,954,495 | 971,914,792 | 2,478,472,272 | 409,344,302 | 20,410,345 |

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.2 ហានិភ័យសន្ទនីយភាព (ត)

### 36.2.3 ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ចំនួនទឹកប្រាក់ក្នុងតារាងខាងលើត្រូវបានចងក្រងដូចខាងក្រោម៖

| ប្រភេទនៃឧបករណ៍ហិរញ្ញវត្ថុ | វិធានដែលបរិមាណត្រូវបានចងក្រង |
|---|---|
| បំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ មិនមែន និស្សន្ទ | លំហូរសាច់ប្រាក់ពុំបានអប្បហារ ដែលរួមបញ្ចូលនូវការប្រាក់ប៉ាន់ស្មានដែលត្រូវទូទាត់ |
| កិច្ចសន្យាឥណទាន | តាមអាយុកាលនៃកិច្ចសន្យាដែលនឹងកើតមានយ៉ាងឆាប់បំផុត |
| បំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | លំហូរសាច់ប្រាក់ទៅតាមកិច្ចសន្យាដែលពុំបានធ្វើអប្បហារ។ ចំនួនដែលបានបង្ហាញជាចំនួនលំហូរចូល និងលំហូរចេញដុល សម្រាប់និស្សន្ទដែលការទូទាត់កើតមានតំណាលគ្នា (ឧទាហរណ៍ ការដោះដូរអត្រាការប្រាក់ និង ការដោះដូររូបិយប័ណ្ណ) និងចំនួនសុទ្ធសម្រាប់និស្សន្ទ ដែលត្រូវបានទូទាត់តម្លៃសុទ្ធ។ |

ជាផ្នែកមួយនៃការគ្រប់គ្រងហានិភ័យសន្ទនីយភាពដែលកើតចេញពីបំណុលហិរញ្ញវត្ថុ ក្រុមហ៊ុនមានទ្រព្យសកម្មដែលអាចប្តូរជាសាច់ប្រាក់ងាយស្រួលបាន រួមមានសាច់ប្រាក់ និងសាច់ប្រាក់សមមូល ដែលមានភាពងាយស្រួលក្នុងការបំពេញតាមតម្រូវការ។ លើសពីនេះទៀត ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងលើកម្រិតឥណទានជាមួយធនាគារផ្សេងទៀត។

តារាងខាងក្រោមកំណត់ពីតម្លៃតាមកិច្ចសន្យា របស់ទ្រព្យសកម្មហិរញ្ញវត្ថុមិនមែននិស្សន្ទ និងបំណុលហិរញ្ញវត្ថុមិនមែននិស្សន្ទ ដែលរំពឹងថានឹងត្រូវទទួលបាន ឬទូទាត់ក្នុងរយៈពេលតិចជាង12ខែ គិតចាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នេះ។

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.2 ហានិភ័យសន្ទនីយភាព (ត)

#### 36.2.3 ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| សាច់ប្រាក់ក្នុងដៃ | 26,268,257 | 106,806,733 | 37,211,155 | 149,402,787 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 16,312,681 | 66,327,361 | 30,270,191 | 121,534,817 |
| សមតុល្យនៅធនាគារនានា | 65,121,823 | 264,785,332 | 39,644,091 | 159,171,025 |
| ឥណទានផ្តល់ដល់អតិថិជន | 364,781,240 | 1,483,200,522 | 327,366,957 | 1,314,378,332 |
| វិនិយោគលើមូលបត្រ | - | - | - | - |
| ទ្រព្យសកម្មផ្សេងៗ | 264,013 | 1,073,477 | 205,338 | 824,432 |
| | 472,748,014 | 1,922,193,425 | 434,697,732 | 1,745,311,393 |
| កិច្ចសន្យាទទួលកម្ចី | 20,049,188 | 81,519,998 | - | - |
| | 492,797,202 | 2,003,713,423 | 434,697,732 | 1,745,311,393 |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 575,761,368 | 2,341,045,722 | 482,384,926 | 1,938,222,633 |
| មូលបត្របំណុល | 2,840,401 | 11,549,070 | 2,380,797 | 9,566,042 |
| ប្រាក់កម្ចី | 84,164,570 | 342,213,142 | 68,271,178 | 274,313,593 |
| អនុបំណុល | 8,878,724 | 36,100,892 | 13,074,608 | 52,533,775 |
| បំណុលភតិសន្យា | 2,412,997 | 9,811,246 | 3,233,448 | 12,991,994 |
| បំណុលផ្សេងៗ | 4,736,413 | 19,258,255 | 4,459,173 | 17,916,957 |
| | 678,794,473 | 2,759,978,327 | 573,804,130 | 2,305,544,994 |
| កិច្ចសន្យាឥណទាន | 1,199,852 | 4,878,598 | 1,114,630 | 4,478,583 |
| | 679,994,325 | 2,764,856,925 | 574,918,760 | 2,310,023,577 |

## 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.2 ហានិភ័យសន្ទនីយភាព (ត)

### 36.2.3 ការវិភាគតាមអាយុកាលនៃបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

តារាងខាងក្រោមបង្ហាញតម្លៃតាមកិច្ចសន្យា នៃទ្រព្យសកម្មហិរញ្ញវត្ថុមិនមែននិស្សន្ទ និងបំណុលហិរញ្ញវត្ថុមិនមែននិស្សន្ទ ដែលរំពឹងនឹងត្រូវទទួលបាន ឬទូទាត់ក្នុងរយៈលើសពី12ខែ គិតចាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នេះ។

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 58,354,775 | 237,270,515 | 47,383,312 | 190,243,998 |
| សមតុល្យនៅធនាគារនានា | - | - | - | - |
| ឥណទានផ្តល់ដល់អតិថិជន | 780,305,476 | 3,172,722,065 | 640,638,297 | 2,572,162,762 |
| វិនិយោគលើមូលបត្រ | 20,000 | 81,320 | 20,000 | 80,300 |
| ទ្រព្យសកម្មផ្សេងៗ | 1,337,179 | 5,436,970 | 1,298,844 | 5,214,859 |
| | 840,017,430 | 3,415,510,870 | 689,340,453 | 2,767,701,919 |
| កិច្ចសន្យាទទួលកម្ចី | 35,000,000 | 142,310,000 | 35,000,000 | 140,525,000 |
| | 875,017,430 | 3,557,820,870 | 724,340,453 | 2,908,226,919 |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 30,520,576 | 124,096,662 | 25,429,996 | 102,101,434 |
| មូលបត្របំណុល | 32,560,083 | 132,389,297 | 34,633,721 | 139,054,390 |
| ប្រាក់កម្ចី | 188,469,258 | 766,316,003 | 149,608,090 | 600,676,481 |
| អនុបំណុល | 9,413,332 | 38,274,608 | 13,658,198 | 54,837,665 |
| បំណុលភតិសន្យា | 10,404,659 | 42,305,343 | 13,283,500 | 53,333,253 |
| បំណុលផ្សេងៗ | 30,683 | 124,757 | 29,058 | 116,668 |
| | 271,398,591 | 1,103,506,670 | 236,642,563 | 950,119,891 |
| កិច្ចសន្យាឥណទាន | - | - | - | - |
| | 271,398,591 | 1,103,506,670 | 236,642,563 | 950,119,891 |

# 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 36.2 ហានិភ័យសន្ទនីយភាព (ត)

### 36.2.4 ប្រាក់បម្រុងសន្ទនីយភាព

តារាងខាងក្រោមបង្ហាញពីសមាសធាតុនៃប្រាក់បម្រុងសន្ទនីយភាពរបស់ក្រុមហ៊ុន។

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | តម្លៃយោង | តម្លៃសមស្រប | តម្លៃយោង | តម្លៃសមស្រប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| សាច់ប្រាក់ក្នុងដៃ | 26,268,257 | 26,268,257 | 37,211,155 | 37,211,155 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 74,607,763 | 74,607,763 | 77,602,188 | 77,602,188 |
| សមតុល្យនៅធនាគារនានា | 65,121,823 | 65,121,823 | 39,594,315 | 39,594,315 |
| កម្រិតឥណទានមិនបានប្រើប្រាស់ | 35,049,188 | 35,049,188 | 35,000,000 | 35,000,000 |
| ប្រាក់បម្រុងសន្ទនីយភាពសរុប | 201,047,031 | 201,047,031 | 189,407,658 | 189,407,658 |
| សមមូលជាពាន់រៀល | 817,457,228 | 817,457,228 | 761,039,970 | 761,039,970 |

### 36.2.5 ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់ឆ្លើយតបទៅនឹងតម្រូវការមូលនិធិនាពេលអនាគត

តារាងខាងក្រោមបង្ហាញអំពីទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ឆ្លើយតបទៅនឹងតម្រូវការមូលនិធិនាពេលអនាគត។

| | ជាប់បន្ទុក | | មិនជាប់បន្ទុក | | | |
|---|---|---|---|---|---|---|
| | បានដាក់ជាទ្រព្យធានា | ផ្សេងៗ* | សម្រាប់ដាក់ជាទ្រព្យធានា | ផ្សេងៗ** | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019** | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | 26,268,257 | 26,268,257 | 106,806,733 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 9,367,966 | 58,381,552 | | 6,917,938 | 74,667,456 | 303,597,876 |
| សមតុល្យនៅធនាគារនានា | - | - | - | 65,121,823 | 65,121,823 | 264,785,332 |
| ឥណទានផ្តល់ដល់អតិថិជន | - | - | - | 1,145,086,716 | 1,145,086,716 | 4,655,922,587 |
| វិនិយោគលើមូលបត្រ | - | - | - | 20,000 | 20,000 | 81,320 |
| បំណុលផ្សេងៗ | - | - | - | 1,601,192 | 1,601,192 | 6,510,447 |
| | 9,367,966 | 58,381,552 | - | 1,245,015,926 | 1,312,765,444 | 5,337,704,295 |

# 36. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 36.2 ហានិភ័យសន្ទនីយភាព (ត)

### 36.2.5 ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់ឆ្លើយតបទៅនឹងតម្រូវការមូលនិធិនាពេលអនាគត (ត)

| | ជាប់បន្ទុក | | មិនជាប់បន្ទុក | | | |
|---|---|---|---|---|---|---|
| | បានដាក់ជាទ្រព្យធានា | ផ្សេងៗ* | សម្រាប់ដាក់ជាទ្រព្យធានា | ផ្សេងៗ** | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | 37,211,155 | 37,211,155 | 149,514,421 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 4,319,117 | 47,404,384 | - | 77,653,503 | 77,653,503 | 312,011,775 |
| សមតុល្យនៅធនាគារនានា | - | - | - | 39,644,091 | 39,644,091 | 159,289,958 |
| ឥណទានផ្ដល់ដល់អតិថិជន | - | - | - | 968,005,254 | 968,005,254 | 3,889,445,111 |
| វិនិយោគលើមូលបត្រ | - | - | - | 20,000 | 20,000 | 80,360 |
| បំណុលផ្សេងៗ | - | - | - | 1,504,182 | 1,504,182 | 6,043,803 |
| | 4,319,117 | 47,404,384 | - | 1,124,038,185 | 1,124,038,185 | 4,516,385,428 |

* បង្ហាញពីទ្រព្យសកម្មដែលមិនត្រូវបានដាក់ជាទ្រព្យធានា ប៉ុន្តែក្រុមហ៊ុនជឿថាទ្រព្យសកម្មនេះមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដាក់ធានាដើម្បីទទួលបានមូលនិធិនោះទេ ដោយសារហេតុផលផ្លូវច្បាប់ ឬហេតុផលណាមួយផ្សេងទៀត។

** បង្ហាញពីទ្រព្យសកម្មដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាទ្រព្យធានា ប៉ុន្តែក្រុមហ៊ុនមិនចាត់ទុកទ្រព្យសកម្មនេះសម្រាប់ដាក់ជាទ្រព្យធានា ដើម្បីទទួលបានមូលនិធិ នៅក្នុងស្ថានភាពប្រតិបត្តិការអាជីវកម្មធម្មតានោះទេ។

## 36.3 ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ គឺជាហានិភ័យដែលផ្លាស់ប្ដូរតាមតម្លៃទីផ្សារ (ឧទាហរណ៍ដូចជាអត្រាការប្រាក់ និងអត្រាប្ដូរប្រាក់បរទេស) ដែលអាចធ្វើឱ្យប៉ះពាល់ចំណូលរបស់ក្រុមហ៊ុន ឬតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុដែលក្រុមហ៊ុនកាន់កាប់។ គោលបំណងនៃការគ្រប់គ្រងហានិភ័យទីផ្សារ គឺក្រុមហ៊ុនត្រូវគ្រប់គ្រង និងត្រួតពិនិត្យការប៉ះពាល់នៃហានិភ័យទីផ្សារនៅក្នុងប៉ារ៉ាម៉ែត្រដែលអាចទទួលយកបាន ដើម្បីធានាបានសាធនភាព ក៏ដូចជាកាត់បន្ថយហានិភ័យរបស់ក្រុមហ៊ុន។

## 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.3 ហានិភ័យទីផ្សារ (ត)

### 36.3.1 ការគ្រប់គ្រងហានិភ័យទីផ្សារ

សិទ្ធិអំណាចទូទៅសម្រាប់ការគ្រប់គ្រងហានិភ័យទីផ្សារ ត្រូវបានផ្តល់ទៅឱ្យគណៈកម្មាធិការទ្រព្យសកម្ម អកម្ម និងហានិភ័យ នៅថ្នាក់ក្រុមប្រឹក្សាភិបាល (ARBC) និង នៅថ្នាក់គ្រប់គ្រង (ALRMC)។ ARBC បង្កើតកម្រិតសម្រាប់ប្រភេទហានិភ័យសមូហភាព និងសម្រាប់សំពៀតឥណទាននីមួយៗ (ទាំងអស់ជាសំពៀតមិនជួញដូរ)។ នាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន និងទីផ្សារទទួលខុសត្រូវចំពោះការអភិវឌ្ឍន៍គោលនយោបាយលម្អិតនៃការគ្រប់គ្រងហានិភ័យ (ត្រួតពិនិត្យដោយ ARBC និងអនុម័តដោយក្រុមប្រឹក្សាភិបាល)។ មុខងាររបស់រតនាភិបាលត្រូវអនុវត្ត និងគ្រប់គ្រងហានិភ័យទីផ្សារនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ។

ក្រុមហ៊ុនប្រើប្រាស់ឧបករណ៍មួយចំនួនដើម្បីត្រួតពិនិត្យ និងដាក់ដែនកំណត់នៃផលប៉ះពាល់លើហានិភ័យទីផ្សារ។

តារាងខាងក្រោមបង្ហាញពីការកំណត់ទ្រព្យសកម្ម និងបំណុលដែលទទួលរងហានិភ័យទីផ្សារ។

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្មទទួលរងហានិភ័យទីផ្សារ** | | | | |
| សាច់ប្រាក់ក្នុងដៃ | 26,268,257 | 106,806,733 | 37,211,155 | 149,514,421 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 74,607,763 | 303,355,164 | 77,602,188 | 311,805,591 |
| សមតុល្យនៅធនាគារនានា | 65,121,823 | 264,785,332 | 39,594,315 | 159,089,958 |
| ឥណទានផ្តល់ដល់អតិថិជន | 865,400,890 | 3,518,720,019 | 741,839,028 | 2,980,709,215 |
| វិនិយោគលើមូលបត្រ | 20,000 | 81,320 | 20,000 | 80,360 |
| បំណុលផ្សេងៗ | 1,601,192 | 6,510,447 | 1,504,182 | 6,043,803 |
| | 1,033,019,925 | 4,200,259,015 | 897,770,868 | 3,607,243,348 |
| **បំណុលទទួលរងហានិភ័យទីផ្សារ** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 574,045,523 | 2,334,069,097 | 491,353,390 | 1,974,257,921 |
| មូលបត្របំណុល | 29,122,787 | 118,413,252 | 29,325,252 | 117,828,863 |
| ប្រាក់កម្ចី | 241,369,509 | 981,408,424 | 191,725,158 | 770,351,685 |
| អនុបំណុល | 15,548,256 | 63,219,209 | 23,236,296 | 93,363,437 |
| បំណុលភតិសន្យា | 12,817,656 | 52,116,589 | 13,172,448 | 52,926,896 |
| បំណុលផ្សេងៗ | 4,767,096 | 19,383,012 | 4,488,231 | 18,033,712 |
| និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | 902,068 | 3,667,808 | 27,794 | 111,676 |
| | 878,572,895 | 3,572,277,391 | 753,328,569 | 3,026,874,190 |

ហត្ថាកសិករ លីមីតធីត

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

# 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 36.3 ហានិភ័យទីផ្សារ (ត)

### 36.3.2 ការប៉ះពាល់ពីហានិភ័យទីផ្សារ

(i) *ហានិភ័យអត្រាការប្រាក់*

ហានិភ័យចម្បងដែលសំពៀតមិនជួញដូរងការប៉ះពាល់ គឺហានិភ័យនៃការបាត់បង់ទទួលពីការប្រែប្រួលនៃលំហូរសាច់ប្រាក់នាពេលអនាគត ឬតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ ឬតម្លៃសេដ្ឋកិច្ចនៃភាគហ៊ុនរបស់ក្រុមហ៊ុនដោយសារតែការផ្លាស់ប្តូរអត្រាការប្រាក់ទីផ្សារ។ ហានិភ័យអត្រាការប្រាក់ ត្រូវបានគ្រប់គ្រងតាមរយៈការត្រួតពិនិត្យតាមដាននូវគម្លាតទ្រព្យសកម្ម និងបំណុល ដែលមានការប្រាក់ជាមួយនឹងកម្រិតកំណត់ដែលបានអនុម័តដោយគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល។ ដោយសារតែកម្ចីខ្លះរបស់ក្រុមហ៊ុនមានអត្រាការប្រាក់ផ្លាស់ប្តូរទៅតាមអត្រាទីផ្សារ ក្រុមហ៊ុនប្រើប្រាស់កិច្ចព្រមព្រៀងការដោះដូរអត្រាការប្រាក់ (Interest rate swap) និងមូលនិធិប្រាក់កម្ចីរយៈពេលវែងដើម្បីបញ្ចៀសហានិភ័យនេះ។ ALRMC មានតួនាទីក្នុងការត្រួតពិនិត្យតាមដាននូវអនុលោមភាពនៃការគ្រប់គ្រងកម្រិតកំណត់ និងទទួលបានការគាំទ្រពីនាយកដ្ឋានរតនាភិបាល ក្នុងសកម្មភាពគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការប្រចាំថ្ងៃ។ សកម្មភាពនេះរួមមាន ការគ្រប់គ្រងការប្រែប្រួលអត្រាហានិភ័យការប្រាក់ ដែលរួមមាន ផលប៉ះពាល់ នៃកាតព្វកិច្ចបំណុលជាក់ស្តែង ឬដែលបានព្យាករណ៍។

ARBC និង ALRMC ទទួលខុសត្រូវក្នុងការរៀបចំយុទ្ធសាស្ត្រជារួម ខណៈដែលនាយកដ្ឋានរតនាភិបាលត្រូវអនុវត្តយុទ្ធសាស្ត្រ ដោយដាក់ចេញជាការរៀបចំការពារហានិភ័យ។

តារាងខាងក្រោមសង្ខេបអំពីចំហគម្លាតអត្រាការប្រាក់របស់ក្រុមហ៊ុន។ តារាងគម្លាតកំណត់តម្លៃអត្រាការប្រាក់ធ្វើការវិភាគទៅលើរចនាសម្ព័ន្ធពេញលេញនៃអត្រាការប្រាក់មិនស៊ីគ្នា រវាងធាតុនៅក្នុងតារាងតុល្យការរបស់ក្រុមហ៊ុន ផ្អែកលើ (i) កាលបរិច្ឆេទកំណត់តម្លៃឡើងវិញបន្ទាប់ ឬអាយុកាលកំណត់ ប្រសិនបើអត្រាការប្រាក់ប្រែប្រួល ឬ (ii) អាយុកាលកំណត់ ប្រសិនបើអត្រាការប្រាក់ថេរ។

## 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.3 ហានិភ័យទីផ្សារ (ត)

### 36.3.2 ផលប៉ះពាល់ពីហានិភ័យទីផ្សារ (ត)

*(i) ហានិភ័យអត្រាការប្រាក់ (ត)*

| | តម្លៃយោង | រហូតដល់ 3 ខែ | > 3 – 6 ខែ | > 6 – 12 ខែ | >1 – 5 ឆ្នាំ | លើសពី 5 ឆ្នាំ | ពុំមានការប្រាក់ |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | | | | | | | |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 26,268,257 | - | - | - | - | - | 26,268,257 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 74,607,763 | - | 5,178,778 | 15,715,966 | - | - | 53,713,019 |
| សមតុល្យនៅធនាគារនានា | 65,121,823 | 16,327,255 | - | - | - | - | 48,794,568 |
| ឥណទានផ្តល់ដល់អតិថិជន | 865,400,890 | 374,254 | 1,039,085 | 22,239,917 | 616,276,066 | 237,829,488 | (12,357,920) |
| វិនិយោគលើមូលបត្រ | 20,000 | - | - | - | - | - | 20,000 |
| បំណុលផ្សេងៗ | 1,601,192 | - | - | - | - | - | 1,601,192 |
| | 1,033,019,925 | 16,701,509 | 6,217,863 | 37,955,883 | 616,276,066 | 237,829,488 | 118,039,116 |
| បំណុលហិរញ្ញវត្ថុ | | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 574,045,523 | 168,596,840 | 93,535,659 | 284,555,404 | 27,298,168 | 59,452 | - |
| មូលបត្របំណុល | 29,122,787 | - | - | - | 28,793,465 | - | 329,322 |
| ប្រាក់កម្ចី | 241,369,509 | 2,000,000 | 4,918,839 | 62,891,115 | 169,930,968 | - | 1,628,587 |
| អនុបំណុល | 15,548,256 | - | - | 7,500,000 | 7,000,000 | 729,319 | 318,937 |
| បំណុលភតិសន្យា | 12,817,656 | - | - | - | - | - | 12,817,656 |
| បំណុលផ្សេងៗ | 4,767,096 | - | - | - | - | - | 4,767,096 |
| | 877,670,827 | 170,596,840 | 98,454,498 | 354,946,519 | 233,022,601 | 788,771 | 19,861,598 |
| និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | 902,068 | - | - | - | - | - | 902,068 |
| សរុប | 154,447,030 | (153,895,331) | (92,236,635) | (316,990,636) | 383,253,465 | 237,040,717 | 97,275,450 |
| សមមូលជាពាន់រៀល | 627,981,624 | (625,738,416) | (375,034,158) | (1,288,883,926) | 1,558,308,589 | 963,807,555 | 395,521,980 |

## ហត្ថាកសិករ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង6ខែ គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2019

### 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.3 ហានិភ័យទីផ្សារ (ត)

### 36.3.2 ផលប៉ះពាល់ហានិភ័យទីផ្សារ (ត)

*(i) ហានិភ័យអត្រាការប្រាក់ (ត)*

| | តម្លៃយោង | រហូតដល់ 3 ខែ | > 3 – 6 ខែ | > 6 – 12 ខែ | >1 – 5 ឆ្នាំ | លើសពី 5 ឆ្នាំ | ពុំមានការប្រាក់ |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 37,211,155 | - | - | - | - | - | 37,211,155 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 77,602,187 | - | 4,230,000 | 7,610,189 | - | - | 65,761,998 |
| សមតុល្យនៅធនាគារនានា | 39,594,315 | 4,795,586 | 7,964,161 | - | - | - | 26,834,568 |
| ឥណទានផ្តល់ដល់អតិថិជន | 741,839,028 | 537,990 | 1,832,696 | 19,976,362 | 636,605,601 | 93,310,571 | (10,424,192) |
| វិនិយោគលើមូលបត្រ | 20,000 | - | - | - | - | - | 20,000 |
| បំណុលផ្សេងៗ | 1,504,182 | - | - | - | - | - | 1,504,182 |
| | 897,770,867 | 5,333,576 | 14,026,857 | 27,586,551 | 636,605,601 | 93,310,571 | 120,907,711 |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 491,353,390 | 119,629,404 | 88,808,236 | 249,241,903 | 21,688,070 | 725,927 | 11,259,850 |
| មូលបត្របំណុល | 29,325,252 | - | - | - | 29,865,605 | - | (540,353) |
| ប្រាក់កម្ចី | 191,725,158 | - | 7,192,131 | 48,721,608 | 136,178,370 | 292,823 | (659,774) |
| អនុបំណុល | 23,236,296 | - | 1,000,000 | 10,000,000 | 11,000,000 | 729,319 | 506,977 |
| បំណុលភតិសន្យា | 13,172,448 | - | - | - | - | - | 13,172,448 |
| បំណុលផ្សេងៗ | 4,488,231 | - | - | - | - | - | 4,488,231 |
| | 753,300,775 | 119,629,404 | 97,000,367 | 307,963,511 | 198,732,045 | 1,748,069 | 28,227,379 |
| និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | 27,794 | - | - | - | - | - | 27,794 |
| សរុប | 144,442,298 | (114,295,828) | (82,973,510) | (280,376,960) | 437,873,556 | 91,562,502 | 92,652,538 |
| សមមូលជាពាន់រៀល | 580,369,154 | (459,240,637) | (333,387,563) | (1,126,554,625) | 1,759,375,948 | 367,898,133 | 372,277,898 |

# 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 36.3 ហានិភ័យទីផ្សារ (ត)

### 36.3.2 ផលប៉ះពាល់ហានិភ័យទីផ្សារ (ត)

*(i) ហានិភ័យអត្រាការប្រាក់ (ត)*

ការគ្រប់គ្រងហានិភ័យអត្រាការប្រាក់ ធៀបទៅនឹងដែនកំណត់គម្លាតអត្រាការប្រាក់ ត្រូវបានអនុវត្តបន្ថែមតាមរយៈការតាមដានលើបម្រែបម្រួលនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ចំពោះសេណារីយ៉ូអត្រាការប្រាក់ដែលមានស្តង់ដា និងមិនមានស្តង់ដា។ សេណារីយ៉ូស្តង់ដាដែលផ្អែកទៅលើមូលដ្ឋានគ្រឹះជាប្រចាំខែ គឺសំដៅទៅលើការធ្លាក់ចុះ ឬកើនស្របគ្នា 100 និង50 basis point (bp) ដើម្បីពិនិត្យមើលលើផលប៉ះពាល់ទៅលើចំណូលអត្រាការប្រាក់សុទ្ធ (Net Interes Income) នៅក្នុងចន្លោះរយៈពេល 12ខែ និងការធ្លាក់ចុះ ឬកើនស្របគ្នា 100 និង50 (bp) ដើម្បីពិនិត្យមើលលើផលប៉ះពាល់ទៅលើតម្លៃយោងនៃមូលធន (Book Value to Equity)។

តារាងខាងក្រោមគឺជាការវិភាគទៅលើបម្រែបម្រួលនៃការកើនឡើង ឬការថយចុះនៃអត្រាការប្រាក់ទីផ្សាររបស់ក្រុមហ៊ុន ដោយសន្មត់ថាមិនមានបម្រែបម្រួលអត្រាការប្រាក់ខុសគ្នាទេ។

| | 100bp កើនឡើង ស្របគ្នា | 100bp ធ្លាក់ចុះ ស្របគ្នា | 50bp កើនឡើង លើសពី1ឆ្នាំ | 50bp ធ្លាក់ចុះ លើសពី1ឆ្នាំ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **បម្រែបម្រួលនៃចំណូលការប្រាក់សុទ្ធ ដែលបានព្យាករណ៍** | | | | |
| **ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019** | | | | |
| ថ្ងៃទី30 មិថុនា | (2,061,886) | 2,061,886 | (1,030,943) | 1,030,943 |
| អំឡុងពេលមធ្យម | (1,771,499) | 1,771,499 | (885,750) | 885,750 |
| អំឡុងពេលអតិបរមា | (2,061,886) | 2,061,886 | (1,030,943) | 1,030,943 |
| អំឡុងពេលអប្បបរមា | (738,884) | 738,884 | (369,442) | 369,442 |
| **ថ្ងៃទី30 ខែមិថុនា ឆ្នាំ 2018** | | | | |
| ថ្ងៃទី30 មិថុនា | (1,217,401) | 1,217,401 | (608,700) | 608,700 |
| អំឡុងពេលមធ្យម | (1,245,406) | 1,245,406 | (622,703) | 622,703 |
| អំឡុងពេលអតិបរមា | (1,380,073) | 1,380,073 | (690,037) | 690,037 |
| អំឡុងពេលអប្បបរមា | (1,104,211) | 1,104,211 | (552,105) | 552,105 |

## 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.3 ហានិភ័យទីផ្សារ (ត)

### 36.3.2 ផលប៉ះពាល់ហានិភ័យទីផ្សារ (ត)

*(i) ហានិភ័យអត្រាការប្រាក់ (ត)*

| | 100bp កើនឡើង ស្របគ្នា | 100bp ធ្លាក់ចុះ ស្របគ្នា | 50bp កើនឡើង លើសពី1ឆ្នាំ | 50bp ធ្លាក់ចុះ លើសពី1ឆ្នាំ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| បម្រែបម្រួលនៃមូលធន ដែលមកពីបម្រែបម្រួល អត្រាការប្រាក់ | | | | |
| **ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019** | | | | |
| ថ្ងៃទី30 មិថុនា | (10,061,085) | 10,061,085 | (5,030,543) | 5,030,543 |
| អំឡុងពេលមធ្យម | (9,099,820) | 9,099,820 | (4,549,910) | 4,549,910 |
| អំឡុងពេលអតិបរមា | (10,061,085) | 10,061,085 | (5,030,543) | 5,030,543 |
| អំឡុងពេលអប្បបរមា | (8,089,221) | 8,089,221 | (4,044,610) | 4,044,610 |
| **ថ្ងៃទី30 ខែមិថុនា ឆ្នាំ2018** | | | | |
| ថ្ងៃទី30 មិថុនា | (5,172,001) | 5,172,001 | (2,586,000) | 2,586,000 |
| អំឡុងពេលមធ្យម | (4,959,196) | 4,959,196 | (2,479,598) | 2,479,598 |
| អំឡុងពេលអតិបរមា | (5,349,952) | 5,349,952 | (2,674,976) | 2,674,976 |
| អំឡុងពេលអប្បបរមា | (4,683,247) | 4,683,247 | (2,341,623) | 2,341,623 |

ចំហរហានិភ័យអត្រាការប្រាក់សរុបទាំងឡាយ ត្រូវបានត្រួតពិនិត្យដោយផ្នែករតនាភិបាល តាមរយៈការប្រើប្រាស់សមតុល្យនៅធនាគារនានា បញ្ញើពីធនាគារផ្សេងៗ និងឧបករណ៍និស្សន្ទ ដើម្បីគ្រប់គ្រងចំហរទាំងនោះ។

*__កិច្ចសន្យាដោះដូរអត្រាការប្រាក់ (Interest Rate Swap)__*

នៅក្នុងកិច្ចសន្យាដោះដូរអត្រាការប្រាក់ ក្រុមហ៊ុនយល់ព្រមធ្វើការដោះដូររវាងចំនួនដែលមានអត្រាការប្រាក់ប្រែប្រួល និងចំនួនដែលមានអត្រាការប្រាក់ថេរ ដោយគណនាលើទឹកប្រាក់ដើមមាននៅក្នុងកិច្ចសន្យា។ កិច្ចសន្យាទាំងនេះអាចឱ្យក្រុមហ៊ុនកាត់បន្ថយហានិភ័យនៃការប្រែប្រួលអត្រាការប្រាក់ លើលំហូរសាច់ប្រាក់នៃបំណុលដែលមានការប្រាក់ប្រែប្រួល។ តម្លៃសមស្របកិច្ចសន្យាដោះដូរអត្រាការប្រាក់នាកាលបរិច្ឆេទរាយការណ៍ គឺត្រូវបានកំណត់តាមរយៈការធ្វើអប្បហារលំហូរសាច់ប្រាក់អនាគត ដោយប្រើអត្រាការប្រាក់នាកាលបរិច្ឆេទរាយការណ៍ដែលបានធ្វើនិយ័តកម្មសម្រាប់ហានិភ័យឥណទានដែលមាននៅក្នុងកិច្ចសន្យា និងត្រូវបានបង្ហាញដូចខាងក្រោម៖

## 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.3 ហានិភ័យទីផ្សារ (ត)

#### 36.3.2 ផលប៉ះពាល់ហានិភ័យទីផ្សារ (ត)

*(i) ហានិភ័យអត្រាការប្រាក់ (ត)*

| | កិច្ចសន្យាអត្រាការប្រាក់ប្រែប្រួល | | តម្លៃដើម | | តម្លៃសមស្រប | |
|---|---|---|---|---|---|---|
| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 |
| | % | % | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| សមតុល្យទទួលតាមអត្រាប្រែប្រួលទូទាត់តាមអត្រាថេរនៃកិច្ចសន្យា | | | | | | |
| រហូតដល់1ឆ្នាំ | | | - | - | - | - |
| >1 ដល់ 2 ឆ្នាំ | | 8.1050% | - | 24,000,000 | - | 15,672 |
| >2 ដល់ 5 ឆ្នាំ | 6.56838%- 11.58763% | 7.15088%- 11.855% | 66,072,000 | 85,000,000 | (907,996) | (43,466) |
| លើសពី 5 ឆ្នាំ | | | - | - | - | - |
| សរុប | | | 66,072,000 | 109,000,000 | (907,996) | (27,794) |
| សមមូលជាពាន់រៀល | | | 268,648,752 | 437,962,000 | (3,691,912) | (111,676) |

ការដោះដូរអត្រាការប្រាក់ជាទូទៅត្រូវបានទូទាត់នៅរៀងរាល់ 6ខែម្តង។ អត្រាការប្រាក់ប្រែប្រួលទៅលើការដោះដូរអត្រាការប្រាក់ ជាទូទៅត្រូវបានកំណត់ទៅតាម LIBOR 6ខែម្តង។

*(ii) ហានិភ័យលើការប្តូររូបិយប័ណ្ណបរទេស*

ក្រុមហ៊ុនធ្វើប្រតិបត្តិការជារូបិយប័ណ្ណបរទេស ដែលទទួលរងហានិភ័យពីការផ្លាស់ប្តូរអត្រាប្តូរប្រាក់។ ការប៉ះពាល់នៃហានិភ័យលើអត្រាប្តូរប្រាក់ ត្រូវបានគ្រប់គ្រងនៅក្នុងគោលនយោបាយប៉ារ៉ាម៉ែត្រដែលបានអនុម័ត ដោយប្រើប្រាស់ការដោះដូររូបិយប័ណ្ណ។

# 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 36.3 ហានិភ័យទីផ្សារ (ត)

### 36.3.2 ផលប៉ះពាល់ហានិភ័យទីផ្សារ (ត)

*(ii) ហានិភ័យលើការប្តូររូបិយប័ណ្ណបរទេស (ត)*

តម្លៃយោងនៃរូបិយប័ណ្ណបរទេសរបស់ក្រុមហ៊ុន ដែលត្រូវបានកំណត់ជាទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ មានដូចខាងក្រោម៖

| | សមមូលជាដុល្លារអាមេរិក | | | សរុប | |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | រៀល | បាត | ដុល្លារអាមេរិក | ពាន់រៀល |
| **ថ្ងៃទី30 ខែមិថុនា ឆ្នាំ 2019** | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 19,795,941 | 5,357,834 | 1,114,482 | 26,268,257 | 106,806,733 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 69,319,814 | 5,287,949 | - | 74,607,763 | 303,355,164 |
| សមតុល្យនៅធនាគារនានា | 58,967,562 | 6,140,235 | 14,026 | 65,121,823 | 264,785,332 |
| ឥណទានផ្តល់ដល់អតិថិជន | 701,896,091 | 129,875,256 | 33,629,543 | 865,400,890 | 3,518,720,019 |
| វិនិយោគលើមូលបត្រ | 20,000 | - | - | 20,000 | 81,320 |
| បំណុលផ្សេងៗ | 1,467,663 | 133,529 | - | 1,601,192 | 6,510,447 |
| | 851,467,071 | 146,794,803 | 34,758,051 | 1,033,019,925 | 4,200,259,015 |
| **បំណុលហិរញ្ញវត្ថុ** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 530,288,605 | 34,113,997 | 9,642,921 | 574,045,523 | 2,334,069,097 |
| មូលបត្របំណុល | - | 29,122,787 | - | 29,122,787 | 118,413,252 |
| ប្រាក់កម្ចី | 152,438,817 | 73,084,605 | 15,846,087 | 241,369,509 | 981,408,424 |
| អនុបំណុល | 15,548,256 | - | - | 15,548,256 | 63,219,209 |
| បំណុលភតិសន្យា | 12,817,656 | - | - | 12,817,656 | 52,116,589 |
| បំណុលផ្សេងៗ | 4,344,910 | 319,222 | 102,964 | 4,767,096 | 19,383,012 |
| | 715,438,244 | 136,640,611 | 25,591,972 | 877,670,827 | 3,568,609,583 |

# 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 36.3 ហានិភ័យទីផ្សារ (ត)

### 36.3.2 ផលប៉ះពាល់ហានិភ័យទីផ្សារ (ត)

*(ii) ហានិភ័យលើការប្តូររូបិយប័ណ្ណបរទេស (ត)*

| | សមមូលជាដុល្លារអាមេរិក | | | សរុប | |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | រៀល | បាត | ដុល្លារអាមេរិក | ពាន់រៀល |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 30,607,038 | 5,376,438 | 1,227,679 | 37,211,155 | 149,514,421 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 63,770,817 | 13,831,371 | - | 77,602,188 | 311,805,591 |
| សមតុល្យនៅធនាគារនានា | 22,605,136 | 13,882,733 | 3,106,446 | 39,594,315 | 159,089,958 |
| ឥណទានផ្តល់ដល់អតិថិជន | 642,453,228 | 72,206,985 | 27,178,815 | 741,839,028 | 2,980,709,215 |
| វិនិយោគលើមូលបត្រ | 20,000 | - | - | 20,000 | 80,360 |
| បំណុលផ្សេងៗ | 1,404,129 | 100,053 | - | 1,504,182 | 6,043,803 |
| | 760,860,348 | 105,397,580 | 31,512,940 | 897,770,868 | 3,607,243,348 |
| **បំណុលហិរញ្ញវត្ថុ** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 424,678,594 | 56,329,958 | 10,344,838 | 491,353,390 | 1,974,257,921 |
| មូលបត្របំណុល | - | 29,325,252 | - | 29,325,252 | 117,828,863 |
| ប្រាក់កម្ចី | 174,257,807 | 9,557,817 | 7,909,534 | 191,725,158 | 770,351,685 |
| អនុបំណុល | 23,236,296 | - | - | 23,236,296 | 93,363,437 |
| បំណុលភតិសន្យា | 13,172,448 | - | - | 13,172,448 | 52,926,896 |
| បំណុលផ្សេងៗ | 4,066,406 | 277,645 | 144,180 | 4,488,231 | 18,033,712 |
| | 639,411,551 | 95,490,672 | 18,398,552 | 753,300,775 | 3,026,762,514 |

## 36 **ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ** (ត)

### 36.3 **ហានិភ័យទីផ្សារ** (ត)

### 36.3.2 **ផលប៉ះពាល់ហានិភ័យទីផ្សារ** (ត)

*(ii) ហានិភ័យលើការប្តូររូបិយប័ណ្ណបរទេស (ត)*

*កិច្ចសន្យាដោះដូររូបិយប័ណ្ណ (Currency Swap)*

ក្នុងអំឡុងពេលបច្ចុប្បន្ន ក្រុមហ៊ុនបានចុះកិច្ចសន្យាដោះដូររូបិយប័ណ្ណ ដោយក្រុមហ៊ុនយល់ព្រមដោះដូររូបិយប័ណ្ណខ្មែររៀល ជាមួយរូបិយប័ណ្ណដុល្លារអាមេរិក ដើម្បីគ្រប់គ្រងចំហររូបិយប័ណ្ណបរទេស។

តារាងខាងក្រោមបង្ហាញលម្អិតពីសមតុល្យតាមកិច្ចសន្យាដោះដូររូបិយប័ណ្ណនៅចុងកាលបរិច្ឆេទ៖

| | អត្រាប្តូរប្រាក់ | | រូបិយប័ណ្ណបរទេស | | តម្លៃដើម | | តម្លៃសមស្រប | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2019 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 |
| | [អត្រា] | [អត្រា] | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| សមតុល្យតាមកិច្ចសន្យា | | | | | | | | |
| ទិញ | | | | | | | | |
| តិចជាង 3ខែ | - | - | - | - | | - | - | - |
| 3 ដល់ 6ខែ | 4,066 | - | 12,198,000,000 | - | 3,000,000 | - | 3,000,000 | - |
| លក់ | | | | | | | | |
| តិចជាង 3ខែ | - | - | - | - | - | - | - | - |
| 3 ដល់ 6ខែ | 4,066 | - | 12,173,898,000 | - | 2,994,072 | - | 2,994,072 | - |
| | | | 24,102,000 | - | 5,928 | - | 5,928 | - |

# 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 36.4 ហានិភ័យប្រតិបត្តិការ

### 36.4.1 ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការគឺហានិភ័យនៃការបាត់បង់ផ្សេងៗដោយផ្ទាល់ ឬដោយប្រយោល ដែលកើតចេញពីដំណើរការផ្ទៃក្នុង ធនធានមនុស្ស បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងកត្តាហានិភ័យខាងក្រៅផ្សេងៗ ក្រៅពីហានិភ័យឥណទាន ហានិភ័យទីផ្សារ និងហានិភ័យសន្ទនីយភាព មានដូចជាហានិភ័យដែលកើតចេញពីការតម្រូវផ្នែកច្បាប់ និងបទប្បញ្ញត្តិ និងស្តង់ដាសាជីវកម្មដែលទទួលស្គាល់។ ហានិភ័យប្រតិបត្តិការ គឺអាចកើតចេញពីរាល់សកម្មភាពប្រតិបត្តិការទាំងអស់របស់ក្រុមហ៊ុន។

គោលបំណងរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិការ គឺដើម្បីរក្សាតុល្យភាពពីការបញ្ចៀសការបាត់បង់ហិរញ្ញវត្ថុ និងការខូចខាតកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ប្រកបដោយប្រសិទ្ធភាព និងភាពច្នៃប្រឌិត។ រាល់គោលនយោបាយរបស់ក្រុមហ៊ុនទាំងអស់ គឺត្រូវអនុលោមទៅតាមការតម្រូវផ្នែកច្បាប់ និងបទប្បញ្ញត្តិ។

អគ្គនាយដ្ឋានហានិភ័យទទួលខុសត្រូវក្នុងការបង្កើត និងអនុវត្តក្នុងការត្រួតពិនិត្យតាមដាន ដើម្បីដោះស្រាយហានិភ័យប្រតិបត្តិការ។ ទំនួលខុសត្រូវនេះត្រូវបានគាំទ្រដោយការអភិវឌ្ឍបទដ្ឋានទូទៅរបស់ក្រុមហ៊ុន សម្រាប់ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ទៅលើចំនុចមួយចំនួនដូចខាងក្រោម៖

- ការតម្រូវឱ្យមានការបែងចែកតួនាទីដាច់ឡែកពីគ្នាឱ្យបានច្បាស់លាស់ ដោយរួមបញ្ចូលទាំងសិទ្ធិក្នុងការអនុម័តនៃប្រតិបត្តិការនីមួយៗដោយឯករាជ្យ
- ការតម្រូវឱ្យមានការផ្ទៀងផ្ទាត់ និងការត្រួតពិនិត្យតាមដានប្រតិបត្តិការទាំងឡាយ
- ការទាមទារឱ្យមានអនុលោមភាពទៅតាមការតម្រូវផ្នែកច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ
- ការរៀបចំឯកសារត្រួតពិនិត្យ និងនីតិវិធីផ្សេងៗ
- ការតម្រូវឱ្យមានការវាយតម្លៃឱ្យបានទៀងទាត់ទៅលើហានិភ័យប្រតិបត្តិការដែលបានរកឃើញ និងភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីដើម្បីដោះស្រាយលើហានិភ័យដែលបានកំណត់
- ការតម្រូវឱ្យមានការរាយការណ៍រាល់ប្រតិបត្តិការនៃការបាត់បង់ និងបង្កើតសកម្មភាពដើម្បីកែលម្អ
- ការបង្កើតឱ្យមានផែនការយថាភាព
- ការបង្កើតឱ្យមានវគ្គបណ្តុះបណ្តាល និងការអភិវឌ្ឍន៍វិជ្ជាជីវៈ
- ការការពារហានិភ័យព័ត៌មានវិទ្យា និងអ៊ីនធឺណែត និង
- យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ រួមទាំងការចំណាយលើការទិញធានារ៉ាប់រងឱ្យមានប្រសិទ្ធភាព។

## 36.5 ហានិភ័យដើមទុន

ហានិភ័យដើមទុន គឺជាហានិភ័យដែលក្រុមហ៊ុនមិនមានធនធានដើមទុនគ្រប់គ្រាន់ ដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ ក្នុងការគាំទ្រចំណាត់ថ្នាក់ឥណទាន និងការរៀបចំផែនការយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន។

យុទ្ធសាស្ត្ររបស់ក្រុមហ៊ុន គឺរក្សាឱ្យបានមូលដ្ឋានដើមទុនឱ្យរឹងមាំ ដើម្បីរក្សាទំនុកចិត្តទីផ្សារ និងដើម្បីរក្សានិរន្តរភាពនៃការអភិវឌ្ឍន៍បន្ថែមលើអាជីវកម្ម។ ផលប៉ះពាល់នៃកម្រិតដើមទុនលើប្រាក់ចំណូលរបស់ម្ចាស់ភាគហ៊ុនត្រូវបានទទួលស្គាល់ និងរក្សាឱ្យមានតុល្យភាពរវាងប្រាក់ចំណូលខ្ពស់ដែលនឹងអាចធ្វើទៅបាន មានការគ្រប់គ្រងដើមទុនល្អ និងមានសុវត្ថិភាព ដែលមានជំហរដើមទុនរឹងមាំ។

ធនាគារជាតិនៃកម្ពុជា ដែលជានិយ័តករសំខាន់ជាងគេ បានកំណត់ និងតាមដានការតម្រូវលើដើមទុនសម្រាប់ក្រុមហ៊ុនទាំងមូល។

## 36 ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 36.5 ហានិភ័យដើមទុន (ត)

#### 36.5.1 ការគ្រប់គ្រងហានិភ័យដើមទុន

ដូចទៅនឹងហានិភ័យសន្ទនីយភាព និងហានិភ័យទីផ្សារ ARBC និង ALRMC ទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព លើហានិភ័យដើមទុនរបស់ក្រុមហ៊ុនទាំងមូល។

ហានិភ័យដើមទុន ត្រូវបានវាស់វែង និងត្រួតពិនិត្យតាមដាន ដោយកម្រិតកំណត់ដែលត្រូវបានគណនាស្របតាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។

នៅថ្ងៃទី22 ខែកុម្ភៈ ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជា បានចេញប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុន (Capital Buffer) សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ យោងតាមមាត្រា22 នៃប្រកាសនេះ គ្រឹះស្ថានទាំងអស់ត្រូវគោរពតាមបទប្បញ្ញត្តិទាក់ទងនឹងការរក្សាទ្រនាប់ដើមទុនយ៉ាងហោចណាស់ឱ្យបាន 50% នៃដើមទុនសរុបគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2019 និងអនុវត្តឱ្យបានយ៉ាងពេញលេញ គិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2020។

នៅថ្ងៃទី7 ខែមីនា ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបានកំណត់អនុបាតនៃទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital Buffer) ចំនួន 0% រហូតដល់មានការជូនដំណឹងជាថ្មី។

ក្រុមហ៊ុនបានអនុលោមទៅតាមការតម្រូវដើមទុនដែលត្រូវបានកំណត់យ៉ាងពេញលេញ។

## 37. រយៈពេលខ្លី និងរយៈពេលវែង

គណៈគ្រប់គ្រងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុផ្អែកលើសន្ទនីយភាព។ ព័ត៌មានអំពីរយៈពេលខ្លី ឬវែង របស់ទ្រព្យសកម្ម និងបំណុល ត្រូវបានបង្ហាញនៅក្នុងផ្នែកនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ។ ទ្រព្យសម្បត្តិ និងបរិក្ខារ សិទ្ធក្នុងការប្រើទ្រព្យសកម្ម ទ្រព្យសកម្មអរូបី និងពន្ធពន្យារជាទ្រព្យសកម្ម ជាទ្រព្យសកម្មរយៈពេលវែង។ សំវិធានធនជាបំណុលរយៈពេលវែង។